00847663

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 14 / 09 / 2012
ម៉ោង (Time/Heure) : 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

E176/2/1/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (១៥)

Case File/Dossier N°. 002/19-09-2007-ECCC-TC/SC (15)

នៅចំពោះមុខ៖

ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម **Motoo Noguchi**
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម **Agniezska KLONOWIECKAMILART**
ចៅក្រម មុំង មុន្នីចរិយា
ចៅក្រម **Chandra Nihal Jayasinghe**
ចៅក្រម យ៉ា ណារិន

| | |
|---|---|
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ |
| ភាសាដើម៖ | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ |

---

# សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង

---

អង្គជំនុំជម្រះតុលាការកំពូល
SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME
E.C.C.C * C.E.T.C

**ជនជាប់ចោទ៖**

នួន ជា

**សហមេធាវីការពារក្តីជនជាប់ចោទ៖**

សុន អរុណ

Michiel PESTMAN
Victor KOPPE
Jasper PAUW
Andrew IANUZZI
Scarlet WANGER

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew CAYLEY

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួលបណ្តឹងសាទុក្ខភ្លាមៗដែលបានដាក់នៅថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២ ("បណ្តឹងសាទុក្ខ") ដោយសហមេធាវីការពារក្តីជនជាប់ចោទ នួន ជា ("មេធាវីការពារក្តី")[1] ប្រឆាំងនឹង "សេចក្តីសម្រេចលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង"របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១២ ("សេចក្តីសម្រេចដែលត្រូវបានជំទាស់")[2]។

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ មេធាវីការពារក្តីបានដាក់សំណើផ្ទាល់មាត់ទៅអង្គជំនុំជម្រះសាលាដំបូង ជាដំបូងឱ្យផ្តន្ទាទោសជាផ្លូវការដល់សេចក្តីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងសារព័ត៌មាន ហើយ ទីពីរ បានស្នើសុំឱ្យគាត់បញ្ឈប់ការធ្វើអត្ថាធិប្បាយប្រហាក់ប្រហែលគ្នានេះទៀត នាពេលអនាគត ("សំណើផ្ទាល់មាត់លើកទីមួយ")[3]។ សេចក្តីថ្លែងការណ៍ទាំងនេះដែលបានចាត់ទុក នួន ជា ថាជា "ឃាតករ" និង ជា"ចារីនៃអំពើប្រល័យពូជសាសន៍"។ ដោយរំលឹកឡើងវិញនូវគោលការណ៍នៃការសន្មតថាជាជនឥតទោស ដែលបានធានានៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") អង្គជំនុំជម្រះសាលាដំបូងបានប្រកាសផ្ទាល់មាត់នៅក្នុង"សេចក្តីសម្រេច"[4]របស់ខ្លួនចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២ ថា អង្គជំនុំជម្រះនឹងមិនពិចារណាទៅលើសេចក្តីថ្លែងការណ៍សាធារណៈណាមួយចំពោះពិរុទ្ធភាពរបស់ជនជាប់ចោទ ដើម្បីចេញសាលក្រមស្តាពររបស់ខ្លួននោះទេ ("សេចក្តីសម្រេចផ្ទាល់មាត់")[5]។

---

[1] បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹង សេចក្តីសម្រេចលើសំណើសុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹង ហ៊ុន សែន អនុលោមតាមវិធាន ៣៥, ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២, ឯកសារ E176/2/1/1។

[2] សេចក្តីសម្រេចលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១២, ឯកសារ E176/2។

[3] ប្រតិចារឹក, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២, ឯកសារ E1/24.1, ទំព័រ ១-២។

[4] អង្គជំនុំជម្រះសាលាដំបូងយោងថាជា"សេចក្តីសម្រេច"របស់ខ្លួន។ ប្រតិចារឹក ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២, ឯកសារលេខ E1/38.1 ទំព័រ ៩៤។

[5] ប្រតិចារឹក, ថ្ងៃទី ០២ កុម្ភៈ ឆ្នាំ ២០១២, ឯកសារ E1/38.1, ទំព័រ ៩៤។



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME * E.C.C.C * C.E.T.C *

00847666



2. ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ មេធាវីការពារក្តី ប៊ុនប៉ុង[6] លើកទឡ្ហីករណ៍ថា សេចក្តីសម្រេចផ្ទាល់មាត់ មិនមែនជាសេចក្តីសម្រេចជាក់ស្តែងទៅលើសំណើផ្ទាល់មាត់លើកទីមួយនោះទេ[7]។ ប្រធានអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា បញ្ហានេះបានដោះស្រាយរួចហើយ។ ដោយបដិសេធនូវសារណាបន្ថែម[8]នោះ ប្រធានបានសង្កេតថា មេធាវីការពារក្តីមានសិទ្ធិប្តឹងសាទុក្ខទៅលើសេចក្តីសម្រេចផ្ទាល់មាត់នេះ ប្រសិនបើខ្លួនមិនពេញចិត្តនឹងការសម្រេចបែបនេះ[9]។ មេធាវីការពារក្តីលើកឡើងថា សេចក្តីសម្រេចផ្ទាល់មាត់ អាចជំទាស់បានតែនៅពេលបណ្តឹងសាទុក្ខចុងក្រោយប្រឆាំងនឹងសាលក្រម[10] ដែលអង្គជំនុំជម្រះសាលាដំបូងមិនបានបដិសេធ[11]។

3. នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២ មេធាវីការពារក្តីបានដាក់សំណើជាលាយលក្ខណ៍អក្សរមួយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយយោងយ៉ាងច្បាស់ទៅលើវិធាន ៣៥ នៃវិធានផ្ទៃក្នុង ហើយបានសំអាងទៅលើកាលៈទេសៈអង្គហេតុដូចគ្នា ដែលនាំឱ្យមានសំណើផ្ទាល់មាត់នេះ ("សំណើជាលាយលក្ខណ៍អក្សរ")[12]។ មេធាវីការពារក្តីបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ការរំលោភលើសិទ្ធិរបស់ជនជាប់ចោទ ដែលត្រូវបានសន្មតថាជាមនុស្សឥតទោស ដរាបណាតុលាការ មិនទាន់កាត់ទោសជាស្ថាពរ។ ទាក់ទងនឹងការដាក់ទណ្ឌកម្ម មេធាវីការពារក្តីបានស្នើសុំអង្គជំនុំជម្រះសាលាដំបូង ថ្កោលទោសជាសាធារណៈនូវសេចក្តីថ្លែងការណ៍របស់

---

[6] ប្រតិចារឹក, ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១២, ឯកសារ E1/40.1, ទំព័រ ៣ (បន្ទាត់ ១៨-២១), ទំព័រ ៤ (បន្ទាត់ ២០-២១), ទំព័រ ៥ (បន្ទាត់ ១-៩) និង ៦ (បន្ទាត់ ៧-៩)។

[7] ប្រតិចារឹក, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២, ឯកសារ E1/40.1, ទំព័រ ៥ (បន្ទាត់៩-១២), ទំព័រ ៦ (បន្ទាត់ ២-៥)។

[8] ប្រតិចារឹក, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២, ឯកសារ E1/40.1, ទំព័រ ៤ (បន្ទាត់៣), ទំព័រ ៥ (បន្ទាត់ ១៥) ទំព័រ ៤ (បន្ទាត់ ២៤-២៥)។

[9] ប្រតិចារឹក, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២, ឯកសារ E1/40.1, ទំព័រ ៣ និង៤ (បន្ទាត់ ២៤-៤), ទំព័រ ៤ (បន្ទាត់ ១៤-១៨)។

[10] ប្រតិចារឹក, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២, ឯកសារ E1/40.1, ទំព័រ ៤ (បន្ទាត់ ៩-១២)។

[11] ប្រតិចារឹក, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២, ឯកសារ E1/40.1, ទំព័រ ៣ (បន្ទាត់ ១៥-១៨)។

[12] សំណើសុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹង ហ៊ុន សែន អនុលោមតាមវិធាន ៣៥, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២, ឯកសារ E176។



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME E.C.C.C * C.E.T.C

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងសុំឱ្យចេញការព្រមានមួយប្រឆាំងនឹងការធ្វើសេចក្តីថ្លែងការណ៍បន្ថែមទៀត ដែលមានប្រហាក់ប្រហែលគ្នានេះ[13]។

4. នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចដែលរងការជំទាស់“ដើម្បីបញ្ជាក់បំភ្លឺអំពីសេចក្តីសម្រេចដោយផ្ទាល់មាត់របស់ខ្លួន ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២ បញ្ជាក់បំភ្លឺនូវសំអាងហេតុនៃសេចក្តីសម្រេចដើមរបស់ខ្លួន”[14]។ នៅក្នុងសេចក្តីសម្រេចដដែលនោះ អង្គជំនុំជម្រះសាលាដំបូងក៏បានសម្រេចបដិសេធសំណើបន្ថែម តាមវិធាន ៣៥[15] ដែលមេធាវីការពារក្តីបានដាក់ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ នៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ ហើយបានសំអាងលើអង្គហេតុដាច់ដោយឡែក តែពាក់ព័ន្ធគ្នា (“សំណើផ្ទាល់មាត់លើកទីពីរ”)[16]។

5. នៅថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២ មេធាវីការពារក្តីបានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចដែលត្រូវបានជំទាស់។ នៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានដាក់សារណាតបរបស់ខ្លួន[17] ដែលត្រូវបានជូនដំណឹងនៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១២។ មេធាវីការពារក្តីមិនដាក់ការឆ្លើយតបទៅនឹងសារណាតបនោះទេ។ ដោយសារថា អង្គជំនុំជម្រះតុលាការកំពូលបានទទួលសំណុំរឿងនេះពីអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២ កាលបរិច្ឆេទចុងក្រោយសម្រាប់ឱ្យអង្គជំនុំជម្រះតុលាការកំពូលចេញសេចក្តីសម្រេចនេះ (ឬសេចក្តីសង្ខេបនៃសំអាងហេតុនានា) គឺនៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២[18]។

---

[13] សំណើជាលាយលក្ខណ៍អក្សរ, កថាខណ្ឌ ១-២, ២២-២៤។

[14] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ២៣។

[15] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ៣២។

[16] ប្រតិចារឹក, ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២, ឯកសារ E1/46.1, ទំព័រ ៦២-៧៣។

[17] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ពាក់ព័ន្ធនឹង “ការអនុវត្តវិធានការដោយសង្ខេបអនុលោមតាមវិធាន ៣៥” ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១២, ឯកសារ E176/2/1/2 (“ចម្លើយតប”)។

[18] វិធាន ១០៤(៤)*(ស្ទួន)*(ក) និង ១០៨(២) (វិសោធនកម្មលើកទី ៨) នៃវិធានផ្ទៃក្នុង; *សូមមើល* សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំទទួលយកការដាក់ឯកសារយឺតយ៉ាវ អនុលោមតាមវិធាន ៣៩(៤), ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១២, ឯកសារលេខ ៣, ទំព័រ ៤; សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* របស់មន្ត្រីច្បាប់ជាន់ខ្ពស់, ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២; *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង*

## II. ប្រវត្តិអង្គហេតុ

6. សំណើជាលាយលក្ខណ៍អក្សរដែលមួយភាគធំផ្ទុះបញ្ចាំងសំណើផ្ទាល់មាត់លើកទីមួយ ជាប់ពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលកាសែតវៀតណាមបានរាយការណ៍ នៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២ ។ សេចក្តីថ្លែងការណ៍ទាំងនេះ ដែលជាប្រសាសន៍របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើឡើងនៅប្រទេសវៀតណាម ក្នុងពិធីសម្ពោធវិមានអបអរសាទរដល់ការបង្កើតអង្គភាព ១២៥ ជាក្រុមយុទ្ធជនដែលបានចូលរួមក្នុងចលនាតស៊ូពីដំបូងប្រឆាំងនឹងរបប ប៉ុល ពត។ បទសម្ភាសន៍នោះបានផ្តោតទៅលើទំនាក់ទំនងរវាងវៀតណាម និងកម្ពុជា និងជាពិសេសលើសំណួរថា តើកងទ័ពវៀតណាមត្រូវបានគេចាត់ទុកថាជាអ្នកលុកលុយ ឬជាអ្នករំដោះ នៅក្នុងព្រឹត្តិការណ៍នានាជុំវិញការដួលរលំនៃរបបខ្មែរក្រហមនោះ[19]។ មេធាវីការពារក្តីបានចោទប្រកាន់ពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ដោយសំអាងលើការធ្វើអត្ថាធិប្បាយរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដូចតទៅ៖

> **កាសែត Quan Doi Nhan Dan** ៖ នាពេលថ្មីៗនេះ នៅតុលាការកាត់ទោសខ្មែរក្រហម នួន ជា បាននិយាយពីអ្វីដែលផ្ទុយនឹងប្រវត្តិសាស្ត្រ ដោយធ្វើការចោទប្រកាន់មួលបង្កាច់ប្រឆាំងនឹងកងទ័ពស្ម័គ្រចិត្តវៀតណាម។ តើលោកយល់យ៉ាងណាដែរ ?
>
> **នាយករដ្ឋមន្ត្រី៖** ខ្ញុំបានឮពីចម្លើយរបស់ នួន ជា ដែលជាបុគ្គលមានតួនាទីសំខាន់នៅក្នុងរបបខ្មែរក្រហម ជាអ្នកដែលត្រូវបានតុលាការយកមកកាត់ទោសកាលពីប៉ុន្មានសប្តាហ៍កន្លងទៅ។ គាត់មិនបានទទួលស្គាល់កំហុសរបស់ខ្លួនទេ តែបែរជានិយាយកុហកអំពី

---

ឯកសារ E154/1/1/4, កថាខណ្ឌ ២; សេចក្តីសង្ខេបសំអាងហេតុនៃសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២, ឯកសារ E116/1/6, ជើងទំព័រ ៧។

[19] ជុំ សុផា, "វៀតណាមជួយកម្ពុជាឲ្យរស់រានមានជីវិតឡើងវិញ៖ ហ៊ុន សែន" ("Vietnam helps revitalize Cambodia: Hun Sen"), *កាសែត TuoiTreNews*, ចេញផ្សាយថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២, គេហទំព័រ៖ http://tuoitrenews.vn/cmlink/tuoitrenews/politics/vietnam-helps-revitalize-cambodia-hun-sen-1.57467; Minh Nam, Tan Tu និង An Dien, "វៀតណាមមិនបានលុកលុយទេ តែបានជួយសង្គ្រោះកម្ពុជាឲ្យរស់រានឡើងវិញ៖ ហ៊ុន សែន" ("Vietnam did not invade, but revived Cambodia: Hun Sen"), *កាសែត Thanh Nien Daily*, ចុះផ្សាយថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២, គេហទំព័រ៖ http://www.thanhniennews.com/index/pages/20120105-vietnam-did-not-invade--but-revived-cambodia--hun-sen.aspx។

បញ្ហាកងទ័ពស្ម័គ្រចិត្តវៀតណាមទៅវិញ។ ខ្ញុំចាត់ទុកចម្លើយទាំងនោះគឺជាការកុហក ដែលចេញពីមាត់ឃាតករ។

ពួកមនុស្សអាក្រក់តែងមានលេសដោះសារជានិច្ច ដើម្បីគេចវេះពីកំហុសរបស់ខ្លួន។ គាត់និយាយបែបនេះគឺដើម្បីសម្រាលបាបកម្មរបស់ខ្លួន ដូច្នេះយើងពុំចាំបាច់ឆ្លើយតបទេ ទុកឱ្យតុលាការវិនិច្ឆ័យចុះ។ ការពិតដែលបានកើតខុសពីអ្វីដែល នួន ជា បាននិយាយ។ ការពិតគឺថា កងទ័ពស្ម័គ្រចិត្តវៀតណាមបានជួយរំដោះប្រជាជនកម្ពុជាចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត។

**កាសែត VnExpress៖** ពីមុនលោកបានបង្ហាញកំហឹងក្រេវក្រោធ នៅពេលមានគេនិយាយថា កងទ័ពស្ម័គ្រចិត្តវៀតណាមបានលុកលុយចូលប្រទេសកម្ពុជា។ ហេតុអ្វីក៏មានរឿងយ៉ាងនេះ?

**នាយករដ្ឋមន្ត្រី៖** ខ្ញុំមានប្រតិកម្មយ៉ាងខ្លាំងក្លាចំពោះសេចក្តីថ្លែងការណ៍បែបនេះ ពីព្រោះសកម្មភាពរបស់កងទ័ពស្ម័គ្រចិត្តវៀតណាមនៅប្រទេសកម្ពុជា គឺផ្តើមចេញពីសំណើសុំរបស់ប្រជាជនកម្ពុជា។ តើមានប្រទេសណាមួយនៅលើលោកនេះដែលបានមកជួយប្រជាជនកម្ពុជា ជាពិសេស ជួយរំដោះពួកគាត់ចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត និងរារាំងមិនឱ្យពួកនេះវិលត្រឡប់មកវិញនោះ? ចម្លើយគឺថា មានតែប្រជាជន និងកងទ័ពវៀតណាមតែប៉ុណ្ណោះ[20]។

7. យោងតាមសេចក្តីថ្លែងការណ៍ទាំងនេះ មេធាវីការពារក្តីដាក់សំណើផ្ទាល់មាត់លើកទីមួយ។ បន្ទាប់ពីសំណើលើកទីមួយនេះ និងសេចក្តីសម្រេចផ្ទាល់មាត់ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន "បានជំរុញឱ្យមេធាវីរដ្ឋាភិបាលឆ្លើយតបទៅនឹងការចោទប្រកាន់ដែលបានធ្វើឡើងដោយមេធាវីការពារក្តី នួន ជា ម្នាក់"[21]។ មានរាយការណ៍ផងដែរថា៖

---

[20] ជុំ សុធា, "វៀតណាមជួយកម្ពុជាឱ្យរស់រានមានជីវិតឡើងវិញ៖ ហ៊ុន សែន" ("Vietnam helps revitalize Cambodia: Hun Sen"), *កាសែត TuoiTreNews*, ចេញផ្សាយថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២, គេហទំព័រ៖ http://tuoitrenews.vn/cmlink/tuoitrenews/politics/vietnam-helps-revitalize-cambodia-hun-sen-1.57467។

[21] "លោក ហ៊ុន សែន អំពាវនាវឱ្យរដ្ឋាភិបាលឆ្លើយតបទៅនឹងការចោទប្រកាន់របស់មេធាវី នួន ជា" ("Hun Sen calls for government response to accusations by Nuon Chea's lawyer"), *កាសែត The Cambodia Herald*, ថ្ងៃទី ខែ កុម្ភៈ



E.C.C.C * C.E.T.C * SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME

> [...] លោក ហ៊ុន សែន បានធ្វើសេចក្តីថ្លែងការណ៍នៅឯវេទិកាស្តីពីទឹកជំនន់ កាលពីថ្ងៃសុក្រថា យោបល់របស់គាត់ក្នុងពេលបំពេញទស្សនកិច្ចនៅប្រទេសវៀតណាមនោះពុំមានឥទ្ធិពលទៅលើការជំនុំជម្រះនោះទេ។ គាត់បាននិយាយថា "ខ្ញុំចង់ធ្វើការប្រកាសជាសាធារណៈមួយអំពីមេធាវីបងធំទីពីរ នួន ជា ដែលចង់ប្តឹងខ្ញុំ" ដោយឱ្យឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈមន្ត្រី សុខ អាន ធ្វើការឆ្លើយតប។
>
> "នៅប្រទេសវៀតណាម គេបានសួរខ្ញុំពីអំពើឧក្រិដ្ឋកម្មរបស់ ប៉ុល ពត ក្នុងរបបខ្មែរក្រហម តែមេធាវី នួន ជា ចោទថា ខ្ញុំបានជ្រៀតជ្រែកចូលក្នុងកិច្ចការតុលាការកាត់ទោសខ្មែរក្រហម។ សេចក្តីថ្លែងការណ៍របស់ខ្ញុំទៅលើ ប៉ុល ពត, នួន ជា, ខៀវ សំផន និង អៀង សារី ពុំមានឥទ្ធិពលទៅលើតុលាការបច្ចុប្បន្ននេះទេ។ តុលាការអាចធ្វើអ្វីតាមតែខ្លួនចង់បាន តែខ្ញុំមានសិទ្ធិផ្តន្ទាទោសមេដឹកនាំខ្មែរក្រហម"[22]។

សេចក្តីថ្លែងការណ៍ទាំងនេះ គឺជាមូលដ្ឋាននៅក្នុងសំណើសុំផ្ទាល់មាត់លើកទីពីរ។

## III. សេចក្តីសម្រេចដែលត្រូវបានជំទាស់

8. នៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២ ប្រធានអង្គជំនុំជម្រះសាលាដំបូង បានប្រកាសសេចក្តីសម្រេចផ្ទាល់មាត់ដូចខាងក្រោម៖

> នេះគឺជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើការជំទាស់របស់មេធាវីការពារក្តី មេធាវីអន្តរជាតិការពារក្តី នួន ជា ទាក់ទិនទៅនឹងការអត្ថាធិប្បាយជាសាធារណៈ អំពីអត្ថិភាពនៃពិរុទ្ធភាពលើកូនក្តីរបស់ខ្លួន។ អង្គជំនុំជម្រះបានកត់សម្គាល់នូវការជំទាស់របស់មេធាវីការពារក្តី ទៅនឹងសេចក្តីអត្ថាធិប្បាយជាសាធារណៈ តាមអត្ថបទសារព័ត៌មាន ដោយបានចោទប្រកាន់ នួន ជា កូនក្តីរបស់ខ្លួនថា មានពិរុទ្ធភាពចំពោះបទល្មើសដែលជនជាប់ចោទរូបនេះកំពុងត្រូវបានជំនុំជម្រះ។
>
> អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ថា តាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា៖ "ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោស ដរាបណា

---

ឆ្នាំ ២០១២, គេហទំព័រ៖ ,<http://www.thecambodiaherald.com/cambodia/detail/1?page=11&token=MWJlMWYxM2E4MzEyODVlMTllNzYzYTRmMWQ2ZWFj>។

[22] ដូចខាងលើ។

តុលាការមិនទាន់កាត់ទោសជាស្ថាពរ"។ ដូច្នេះ ការកំណត់ថាមានពិរុទ្ធភាព ឬគ្មានទោស ដល់ជនជាប់ចោទណាម្នាក់ គឺជាភារកិច្ចរបស់អង្គជំនុំជម្រះ ដែលនឹងត្រូវសម្រេចនៅពេលបញ្ចប់សវនាការ ដោយផ្អែកលើកិច្ចពិភាក្សាដេញដោលលើអង្គហេតុ និងភស្តុតាងនានា ដែលត្រូវបានបង្ហាញនៅក្នុងសវនាការ និងផ្អែកតាមច្បាប់ជាធរមានដែលអនុវត្តនៅ អ.វ.ត.ក តែប៉ុណ្ណោះ។

ដូច្នេះ អង្គជំនុំជម្រះមិនយកសេចក្ដីអត្ថាធិប្បាយសាធារណៈណាមួយ ពាក់ព័ន្ធនឹងអត្ថិភាព ឬនត្ថិភាពនៃពិរុទ្ធភាពរបស់ជនជាប់ចោទណាម្នាក់ មកពិចារណានៅពេលខ្លួនពិចារណាចេញសាលក្រមនោះឡើយ[23]។

9. ដូចដែលបានលើកឡើងខាងលើ សេចក្ដីសម្រេចដែលរងការជំទាស់ "ដែលបានបញ្ជាក់បំភ្លឺ" នៅក្នុងផ្នែកសំអាងហេតុនៃសេចក្ដីសម្រេចផ្ទាល់មាត់ បានលើកឡើងពីច្បាប់ជាធរមានដែលពាក់ព័ន្ធនឹងគោលការណ៍សន្មតទុកជាមុនថាគ្មានទោស និងរៀបរាប់លម្អិតនូវក្របខ័ណ្ឌច្បាប់នៅ អ.វ.ត.ក ស្ដីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ។ អង្គជំនុំជម្រះសាលាដំបូងបានសង្កេតឃើញថា សិទ្ធិរបស់ជនជាប់ចោទ ដែលត្រូវបានសន្មតថាជាជនគ្មានទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ គឺជាគោលការណ៍សារវ័ន្តនៃនីតិវិធីព្រហ្មទណ្ឌ ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញកម្ពុជា និងមានចែងនៅក្នុងសន្ធិសញ្ញាស្ដីពីសិទ្ធិមនុស្សអន្តរជាតិមួយចំនួន[24]។ ដោយសំអាងលើយុត្តិសាស្ត្រស្ដីពីសិទ្ធិមនុស្សអន្តរជាតិ ជាពិសេសទៅលើច្បាប់យុត្តិសាស្ត្រនៃតុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស ("ECtHR") អង្គជំនុំជម្រះសាលាដំបូងសម្រេចថា "ការប្រកាសណាមួយអំពីការទទួលខុសត្រូវរបស់ជនជាប់ចោទពីសំណាក់មន្ត្រីសាធារណៈ នៅមុនពេលតុលាការចេញសាលក្រមគឺមិនស៊ីសង្វាក់ទៅនឹងគោលការណ៍នៃការសន្មតទុកជាមុនថាគ្មានទោស ទេ"[25]។

10. ពាក់ព័ន្ធនឹងក្របខ័ណ្ឌច្បាប់ជាធរមាននៅ អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូង បានរំឮកទៅដល់អំណាចឆន្ទានុសិទ្ធិរបស់តុលាការក្នុងការដោះស្រាយករណីនៃការជ្រៀតជ្រែកនានា តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង[26]។ អង្គជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា ទោះបីជាមានការតម្រូវឱ្យមាន

---

[23] ប្រតិចារឹក, ថ្ងៃទី ២ កុម្ភៈ ឆ្នាំ ២០១២, ឯកសារ E1/38.1, ទំព័រ ៩៣ ដល់ ៩៤ (បន្ទាត់ ២៤ ដល់ ១៣)។

[24] សេចក្ដីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១៦។

[25] សេចក្ដីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១៨។

[26] សេចក្ដីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ២០។

00847672



"បទដ្ឋាននៃជំនឿសមហេតុផល" អប្បបរមា ដើម្បីយកបញ្ហាណាមួយមកពិចារណានោះក៏ដោយ ការចោទប្រកាន់ពីការទទួលខុសត្រូវព្រហ្មទណ្ឌតម្រូវឱ្យមានបទដ្ឋានកម្រិតខ្ពស់ជាងនេះ ដើម្បីឱ្យអង្គជំនុំជម្រះធ្វើអន្តរាគមន៍តាមផ្លូវតុលាការបាន[27]។ អាចចាត់ទុកថាស្របទៅតាមកម្រិតនៃជំនឿសមហេតុផលតាមវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង បាន នៅពេលមានមូលដ្ឋានសម្ភារៈដែលបង្ហាញថា ការចោទប្រកាន់ពុំមែនជាការស្មានៗទេ ហេតុនេះ "នាំឱ្យមានការស៊ើបអង្កេតបន្ថែម"[28]។ អង្គជំនុំជម្រះពុំមានភារកិច្ចក្នុងការបន្តកិច្ចដំណើរការសួរដេញដោលពិស្តារ ឬកិច្ចស៊ើបសួរផ្នែកព្រហ្មទណ្ឌណាមួយ ទៅលើអង្គហេតុដែលរងការចោទប្រកាន់នោះទេ[29]។ នៅពេលមានការចោទប្រកាន់ពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ តាមវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង នោះ អង្គជំនុំជម្រះសាលាដំបូងបានរំឭកថា វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង និងយុត្តិសាស្ត្រអន្តរជាតិដែលពាក់ព័ន្ធតម្រូវថា (១) ត្រូវមានចេតនាជាក់លាក់ក្នុងការជ្រៀតជ្រែកចូលក្នុងកិច្ចការយុត្តិធម៌[30] និង (២) ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌអាចធ្វើឡើងបន្ទាប់ពីមានការវាយតម្លៃថា ឧក្រិដ្ឋកម្មនោះត្រូវបានធ្វើឡើងហួសពីវិមតិសង្ស័យ[31]។

11. អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការធ្វើអត្ថាធិប្បាយរបស់នាយករដ្ឋមន្ត្រីដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ នួន ជា នោះ ប្រសិនបើជាការរាយការណ៍ត្រឹមត្រូវមែននោះ វាមិនស្របទៅនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការសន្មតទុកជាមុនថាគ្មានទោស រហូតទាល់តែមានការបញ្ជាក់ថាមានពិរុទ្ធភាពទេ[32]។ ថ្វីត្បិតតែយ៉ាងណានេះក៏ដោយ អង្គជំនុំជម្រះបានបញ្ជាក់ជាថ្មីថា ការធ្វើអត្ថាធិប្បាយដែលបានលើកឡើង ព្រមទាំងការសម្តែងយោបល់ជាសាធារណៈទាំងឡាយអំពីពិរុទ្ធភាព ឬភាពគ្មានទោសរបស់ជនជាប់ចោទ នឹងមិនមានឥទ្ធិពលលើចៅក្រមនៃអង្គជំនុំជម្រះ ដែល

[27] សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ២០, ២២, ២៨។

[28] សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ២០។

[29] សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ២០, ៣០។

[30] សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ២២ (នៅក្នុងនោះអង្គជំនុំជម្រះសាលាដំបូងបានស្របទៅនឹងការបកស្រាយ *ចេតនាឧក្រិដ្ឋ* ដែលទាក់ទិននឹងការប្រមាថតុលាការដែលបានផ្តល់ដោយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY") ក្នុងសំណុំរឿងចំនួន ២)។

[31] សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ៣០ (ដោយយោងទៅដល់គោលការណ៍នានាដែលបានបញ្ចូលតាមវិធាន ៨៧(១) និងយុត្តិសាស្ត្រអន្តរជាតិដែលពាក់ព័ន្ធ)។

[32] សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ២៦។



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME E.C.C.C * C.E.T.C

មានលក្ខណៈសម្បត្តិតាមផ្លូវច្បាប់ និងត្រូវបានសន្មតថាអាចបំពេញការងាររបស់ខ្លួនដោយឯករាជ្យនោះទេ[33]។

12. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ការប្រើឥទ្ធិពលមិនសមរម្យទៅលើចៅក្រម ឬ"ធ្វើសកម្មភាពដែលអាចឱ្យគេយល់បានថា ជាការប៉ុនប៉ងធ្វើដូច្នោះនោះ" ស្ថិតក្នុងវិសាលភាពនៃការអនុវត្តវិធាន ៣៥ នៃវិធានផ្ទៃក្នុង[34]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ដោយពុំនិយាយពីចេតនាក្នុងការថ្លែងការណ៍ ការបញ្ចេញយោបល់ដែលបានរាយការណ៍មកនោះស្របទៅនឹងបទដ្ឋាននៃជំនឿសមហេតុផលអប្បបរមា ដែលអាចធ្វើអន្តរាគមន៍បានតាមវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង[35]។ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងពុំបានបើកកិច្ចស៊ើបសួរផ្នែកព្រហ្មទណ្ឌដោយសំអាងថា មេធាវីការពារក្តីពុំបានផ្តល់ភស្តុតាងគ្រប់គ្រាន់នោះ អង្គជំនុំជម្រះបានសម្រេច ឆ្លើយតបនឹងបញ្ហានេះដោយសង្ខេប អនុលោមតាមវិធាន ៣៥(២)(ក) នៃវិធានផ្ទៃក្នុង[36]។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូង "សូមបញ្ជាក់ជាថ្មីអំពីគោលការណ៍នៃឯករាជភាពរបស់តុលាការ និងគោលការណ៍នៃការសន្មតទុកជាមុនថាគ្មានទោស" និង "បានចេញសេចក្តីប្រកាសយ៉ាងច្បាស់លាស់ជាសាធារណៈអំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការសន្មតទុកជាមុនថាគ្មានទោស និងភាពចាំបាច់ដែលមន្ត្រីនានាគប្បីចៀសវាងការធ្វើអត្ថាធិប្បាយណាមួយ ដែលមិនស្របទៅនឹងគោលការណ៍នេះ"[37]។

13. សំណើជាលាយលក្ខណ៍អក្សរដែលត្រូវបានចាត់ទុកថាជា "ការដាក់ឯកសារច្រំដែល ឬជាបណ្តឹងសាទុក្ខក្លែងភេទ" ត្រូវបានសម្រេចថាមិនអាចទទួលយកបាន[38]។ ចំពោះសំណើផ្ទាល់មាត់លើកទីពីរវិញ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលលើអង្គសេចក្តី ដោយសារពុំមានភស្តុតាង

[33] សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ២៧។

[34] សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ២០-២១។

[35] សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ២៩-៣០។

[36] សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ៣០-៣១។

[37] សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ៣០-៣១។

[38] សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ២៣។

និងមិនបានបំពេញទៅតាមលក្ខខណ្ឌនៃការបង្ហាញភស្តុតាងដែលស្របទៅនឹងបទដ្ឋាននៃជំនឿសមហេតុផល[39]។

## IV. សារណា

### ក. បណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ

14. ជាបញ្ហាទូទៅ មេធាវីការពារក្ដីបានលើកឡើងថា សេចក្ដីសម្រេចដែលត្រូវបានជំទាស់ពុំបានបង្ហាញឱ្យបានច្បាស់ពីភារកិច្ចរបស់អង្គជំនុំជម្រះក្នុងការបើកកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង[40]។ ដោយពុំមានការពន្យល់បន្ថែម ទោះបីអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ជំនឿសមហេតុផលដែលថា ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការដែលអាចកើតឡើង "នាំឱ្យមានការស៊ើបអង្កេតបន្ថែម" ក្ដី តែអង្គជំនុំជម្រះបានបដិសេធមិនបើកកិច្ចស៊ើបសួរទៅលើការចោទប្រកាន់របស់មេធាវីការពារក្ដីទេ[41]។ មេធាវីការពារក្ដីមិនពេញចិត្តត្រង់ថា ការមិនបើកកិច្ចស៊ើបសួរគឺ អង្គជំនុំជម្រះសាលាដំបូងបានកម្រិតវិធានការរបស់ខ្លួនត្រឹមការចេញសេចក្ដីរំឭកមួយដែល "ជាការគ្មានតម្លៃ ដែលមិនអាចទៅរួច"[42]។ ជាងនេះទៀត មេធាវីការពារក្ដីនៅតែលើកឡើងថា សេចក្ដីសម្រេចដែលរងការជំទាស់បានផ្ដោត ដោយពុំមានភាពចាំបាច់ ទៅលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងលក្ខខណ្ឌចាំបាច់នៃភស្តុតាង ទោះបីនេះពុំមែនជាកម្មវត្ថុនៃសំណើជាលាយលក្ខណ៍អក្សរនោះទេ[43]។ ផ្ទុយទៅវិញ សំណើជាលាយលក្ខណ៍អក្សរត្រូវបានកំហិតត្រឹមតែការលើកឡើងចំពោះការរំលោភសិទ្ធិមនុស្ស និងបង្ហាញអំពីកម្រិតអប្បបរមានៃ*សេចក្ដីបញ្ជាក់ដំបូង* ដែលតម្រូវឱ្យមានកិច្ចស៊ើបសួរបន្ថែមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង តែប៉ុណ្ណោះ[44]។

---

[39] សេចក្ដីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ៣២។

[40] បណ្ដឹងសាទុក្ខ, កថាខណ្ឌ ៥-៦។

[41] បណ្ដឹងសាទុក្ខ, កថាខណ្ឌ ៥-៦។

[42] បណ្ដឹងសាទុក្ខ, កថាខណ្ឌ ៦។

[43] បណ្ដឹងសាទុក្ខ, កថាខណ្ឌ ៧។

[44] បណ្ដឹងសាទុក្ខ, កថាខណ្ឌ ៧។



C.C*C.E.T.C. CHAMBRE CHAMBRE DE LA COUR SUPREME

15. បើតាមទឡ្ហីករណ៍ទីមួយនៃបណ្តឹងសាទុក្ខ មេធាវីការពារក្តីលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង បានប្រព្រឹត្តកំហុសលើអង្គច្បាប់ ដែលនាំឲ្យមោឃភាពសេចក្តីសម្រេច ដោយខ្លួនមិនបានផ្តល់ដំណោះស្រាយសមរម្យ បន្ទាប់ពីបានយល់ឃើញថា មានការរំលោភបំពានលើសិទ្ធិរបស់ជនជាប់ចោទ[45]។ ទឡ្ហីករណ៍ទីពីរនៃបណ្តឹងសាទុក្ខបានចោទប្រកាន់កំហុសជាក់ស្តែង របស់អង្គជំនុំជម្រះសាលាដំបូងក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន[46]។ ក្នុងចំណុចនេះ មេធាវីការពារក្តីជំទាស់ថា ការក្រើនរំឭកជាសាធារណៈដែលចេញដោយអង្គជំនុំជម្រះសាលាដំបូង គឺជា "សកម្មភាពតូចតាចបំផុត"[47] ហេតុនេះវាមិនគ្រប់គ្រាន់ដើម្បីទប់ស្កាត់មិនឲ្យមានការរំលោភនាពេលអនាគតទេ[48]។ មេធាវីការពារក្តីលើកទឡ្ហីករណ៍ថា អង្គជំនុំជម្រះសាលាដំបូងគួរតែផ្តន្ទាទោសនាយករដ្ឋមន្ត្រីដោយផ្ទាល់ តាមរយៈការព្រមានរូបគាត់មិនឲ្យធ្វើសេចក្តីថ្លែងការណ៍ដែលមានលក្ខណៈស្រដៀងគ្នា និងបើកកិច្ចស៊ើបសួរដើម្បីបង្ហាញពីចេតនារបស់គាត់[49]។ ចំពោះមូលដ្ឋានទីបីនៃបណ្តឹងសាទុក្ខវិញ មេធាវីការពារក្តីលើកឡើងថា សេចក្តីសម្រេចដែលរងការជំទាស់មានកំហុស ដោយបានបដិសេធសំណើជាលាយលក្ខណ៍អក្សរថា មិនអាចទទួលយកបាន[50]។ ថ្វីត្បិតតែយ៉ាងនេះក្តី ក្នុងចំណុចនេះ មេធាវីការពារក្តីទទួលស្គាល់ថា "កំហុសដូចនេះមិនមែនជាកំហុសដែលបណ្តាលឲ្យមានព្យសនកម្មនោះទេ ដរាបអង្គជំនុំជម្រះសាលាដំបូងពិតជាបានដោះស្រាយបញ្ហាអង្គសេចក្តីនៃ [សំណើជាលាយលក្ខណ៍អក្សរ] *ទាំងមូល*"[51]។

16. ហេតុនេះ មេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះតុលាការកំពូល៖ ទទួលយកបណ្តឹងសាទុក្ខ បើកសវនាការមួយជាសាធារណៈ មោឃៈសេចក្តីសម្រេចដែលរងការជំទាស់ និងអនុវត្តឆន្ទានុសិទ្ធិ

---

[45] បណ្តឹងសាទុក្ខ, កថាខណ្ឌ ១៣។

[46] បណ្តឹងសាទុក្ខ, កថាខណ្ឌ ១៥។

[47] បណ្តឹងសាទុក្ខ, កថាខណ្ឌ ១៥។

[48] បណ្តឹងសាទុក្ខ, កថាខណ្ឌ ១៧។

[49] បណ្តឹងសាទុក្ខ, កថាខណ្ឌ ១៥-១៨។

[50] បណ្តឹងសាទុក្ខ, កថាខណ្ឌ ១៩។

[51] បណ្តឹងសាទុក្ខ, កថាខណ្ឌ ១៩។

របស់ខ្លួន ដោយផ្តល់ដំណោះស្រាយមួយសមស្រប និងចាត់វិធានការទៅតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង[52]។

## ខ. សារណាតបរបស់សហព្រះរាជអាជ្ញា

17. ជាបឋម សហព្រះរាជអាជ្ញាអះអាងថា បណ្តឹងសាទុក្ខត្រង់ចំណុចដែលនិយាយអំពីបញ្ហានានាដែលបានលើកនៅក្នុងសំណើជាលាយលក្ខណ៍អក្សរ មួយផ្នែកពុំមានលក្ខណៈអាចឱ្យទទួលយកបានឡើយ ដោយហេតុថា បណ្តឹងសាទុក្ខនេះពុំត្រូវបានដាក់ទាន់ពេលវេលា[53]។ ដោយសារសេចក្តីសម្រេចដោយផ្ទាល់មាត់បានចាត់ការជាស្ថាពរ ប៉ុន្តែយ៉ាងទាន់ហន់លើសំណើផ្ទាល់មាត់លើកទីមួយ ហើយសំណើជាលាយលក្ខណ៍អក្សរ និងសំណើផ្ទាល់មាត់លើកទីមួយមានចំណុចដូចគ្នាច្រើន ទើបសហព្រះរាជអាជ្ញាអះអាងថា ពេលវេលាកំណត់ចំនួន ៣០ ថ្ងៃដើម្បីដាក់បណ្តឹងសាទុក្ខភ្លាមៗ ដោយអនុលោមតាមវិធាន ១០៧(១) នៃវិធានផ្ទៃក្នុង បានចាប់ផ្តើមគិតនៅថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១២ ដែលជាកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេចដោយផ្ទាល់មាត់នេះ[54]។ ហេតុដូច្នេះ យោងតាមសហព្រះរាជអាជ្ញា មេធាវីការពារក្តីគួរតែបានដាក់បណ្តឹងសាទុក្ខនេះត្រឹមថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១២ ឬស្នើសុំការពន្យារពេល ឬលើកពីករណីពិសេសចំពោះការដាក់បណ្តឹងសាទុក្ខយឺតយ៉ាវ[55]។ បន្ទាប់ពីខកខានពុំបានអនុវត្តដូចខាងលើ បើទោះបីជាមានការបញ្ជាក់របស់ប្រធានអង្គជំនុំជម្រះសាលាដំបូងថា សេចក្តីសម្រេចដោយផ្ទាល់មាត់ បើកផ្លូវប្តឹងសាទុក្ខក៏ដោយ ក៏សហព្រះរាជអាជ្ញាអះអាងថា មេធាវីការពារក្តីពុំបានគោរពតាមបញ្ញត្តិពាក់ព័ន្ធស្តីពីពេលវេលាកំណត់នេះដែរ។

18. ម្យ៉ាងទៀត សហព្រះរាជអាជ្ញាអះអាងថា បណ្តឹងសាទុក្ខទាំងមូលគួរត្រូវបានបដិសេធ ដោយហេតុថា បណ្តឹងនេះពុំបានបំពេញបទដ្ឋានជាធរមាននៃការពិនិត្យបណ្តឹងសាទុក្ខឡើងវិញឡើយ[56]។ ជាបឋម សេចក្តីសម្រេចដែលត្រូវបានជំទាស់ស្របជាមួយវិធាន ៣៥(២) និងយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្ស ក្នុងការចាត់ទុកសំណងទូទាត់ប្រកាសសិទ្ធិតែមួយមុខ ជាទម្រង់នៃសំណងគ្រប់

---

[52] បណ្តឹងសាទុក្ខ, កថាខណ្ឌ ២០-២១។

[53] សារណាតប, កថាខណ្ឌ ៧-១២។

[54] សារណាតប, កថាខណ្ឌ ៤,៧,១០។

[55] សារណាតប, កថាខណ្ឌ ៨, ១១។

[56] សារណាតប, កថាខណ្ឌ ៣០, ៣៦។

គ្រាន់សម្រាប់ការរំលោភជាហូរហែលើការសន្និដ្ឋានជាមុនអំពីភាពគ្មានទោស[57]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងពុំបានប្រព្រឹត្តកំហុសអង្គច្បាប់ ដែលនាំឱ្យមានមោឃភាពចំពោះសេចក្ដីសម្រេចនេះឡើយ[58]។ ទីពីរ សហព្រះរាជអាជ្ញាអះអាងថា មេធាវីការពារក្ដីខកខានពុំបានបង្ហាញអំពីកំហុសអង្គច្បាប់ ពាក់ព័ន្ធនឹងសេចក្ដីប្រកាសរបស់អង្គជំនុំជម្រះសាលាដំបូងបដិសេធមិនទទួលសំណើជាលាយលក្ខណ៍អក្សរ ដោយសារជាការដាក់សំណើត្រួតជាន់គ្នានោះទេ។ កំណត់ត្រាអង្គហេតុបង្ហាញយ៉ាងច្បាស់អំពីចរិតលក្ខណៈតម្រូវ នៃការចេញសេចក្ដីសម្រេចដោយផ្ទាល់មាត់តែប៉ុណ្ណោះ[59]។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់លើចំណុចនេះក៏ដោយ ក៏កំហុសទាំងនេះ ពុំធ្វើឱ្យសេចក្ដីសម្រេចនេះមានមោឃភាពឡើយ ដោយហេតុថាដូចដែលមេធាវីការពារក្ដីបានទទួលស្គាល់ វាជាកំហុសដែលគ្មានផលប៉ះពាល់ យោងទៅលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីចាត់ការសំណើជាលាយលក្ខណ៍អក្សរលើអង្គសេចក្ដី និងចេញសេចក្ដីសម្រេចមួយ ដែលមានសំអាងហេតុពេញលេញ[60]។ ទីបី សេចក្ដីសម្រេចដែលត្រូវបានជំទាស់ពុំបង្ហាញឱ្យឃើញអំពីកំហុសជាក់ស្ដែង ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីធ្វើឱ្យសេចក្ដីសម្រេចនេះ "ពុំមានភាពសមហេតុផល ឬពុំមានយុត្តិធម៌" ឡើយ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងត្រូវបានប្រគល់ឱ្យនូវឆន្ទានុសិទ្ធិទូលំទូលាយ ក្នុងការបង្កើតវិធានការសមស្រប ដើម្បីរក្សាបាននូវឯករាជ្យភាព និងសុចរិតភាពរបស់ពួកគាត់[61]។ តាមសំអាងហេតុទាំងអស់នេះ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា បណ្ដឹងសាទុក្ខ រួមទាំងសំណើសុំឱ្យមានសវនាការជាសាធារណៈ[62] គួរត្រូវបានបដិសេធ។

## V. បទដ្ឋាននៃការពិនិត្យមើលឡើងវិញ

19. អនុលោមតាមវិធាន ១០៤(១) និង ១០៥(២) បណ្ដឹងសាទុក្ខភ្លាមៗអាចផ្អែកលើមូលដ្ឋានមួយ ឬច្រើនក្នុងចំណោមមូលដ្ឋានទាំង ៣ ខាងក្រោម៖

---

[57] សារណាតប, កថាខណ្ឌ ២៣-២៨។

[58] សារណាតប, កថាខណ្ឌ ២៨។

[59] សារណាតប, កថាខណ្ឌ២៩។

[60] សារណាតប, កថាខណ្ឌ ២៩។

[61] សារណាតប, កថាខណ្ឌ ៣១-៣៦។

[62] សារណាតប, កថាខណ្ឌ ៦, ៣៧។



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPREME E.C.C.C * C.E.T.C

00847678



- កំហុសលើអង្គច្បាប់ដែលនាំឲ្យមោឃៈសេចក្ដីសម្រេច
- កំហុសនៃអង្គហេតុដែលនាំឲ្យសេចក្ដីសម្រេចនោះមានភាពមិនយុត្តិធម៌ និង
- ការភ័ន្តច្រឡំដែលស្ដែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្ដឹងសាទុក្ខ

20. ដោយហេតុថា អង្គជំនុំជម្រះនេះធ្លាប់បានបញ្ជាក់បំភ្លឺពីដំបូងថា មូលដ្ឋានទាំងនេះនៃបណ្ដឹងសាទុក្ខ "នឹងត្រូវអានដាច់ដោយឡែក" ដែលមានន័យថា ដើម្បីបំពេញមូលដ្ឋានចំនួន ២ ដំបូង ម្ចាស់បណ្ដឹងសាទុក្ខពុំចាំបាច់បង្ហាញថា កំហុសដែលត្រូវបានចោទប្រកាន់ ក៏បានធ្វើឲ្យខូចប្រយោជន៍ដល់សិទ្ធិរបស់ខ្លួនឡើយ[63]។

## VI. ការពិភាក្សា

### ក. ភាពអាចទទួលយកបាននៃបណ្ដឹងសាទុក្ខ

#### *i. ចំណាត់ការរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើផ្ទាល់មាត់លើកទីមួយ*

21. ពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃបណ្ដឹងសាទុក្ខ ប្រវត្តិនីតិវិធីដែលកើតឡើងមុនសេចក្ដីសម្រេចដែលរងការជំទាស់នេះ មានការរៀបរាប់យ៉ាងពិសេស។ មុនពេលចេញសេចក្ដីសម្រេចដោយផ្ទាល់មាត់ ហើយរហូតដល់មានការចេញសេចក្ដីសម្រេចដែលរងការជំទាស់នេះ មេធាវីការពារក្ដីបានលើកឡើងម្ដងហើយម្ដងទៀត អំពីបញ្ហាដែលជាមូលដ្ឋាននៃសំណើផ្ទាល់មាត់លើកទីមួយ[64]។ អង្គជំនុំជម្រះសាលាដំបូងក្រោយមកបានពិចារណាលើទង្វើនេះ ដោយរួមជាមួយការចោទប្រកាន់ផ្សេងៗ ក្នុងការបង្កើតជាភស្ដុតាងនៃ"លំនាំមួយដដែលៗនៃកំហុសឆ្គងវិជ្ជាជីវៈ" និងបានបញ្ជូនកំហុសឆ្គងទៅគណៈមេធាវីដែលមានសមត្ថកិច្ច[65]។ ប៉ុន្តែ នៅពេលមានការពិនិត្យមើលឡើងវិញទៅលើប្រតិចារឹកពាក់ព័ន្ធ ជាភាសាខ្មែរ និងភាសាអង់គ្លេស អង្គជំនុំជម្រះតុលាការកំពូល

---

[63] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្ដីពីសំណើសុំដោះលែងជាបន្ទាន់, អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារ E50/3/1/4, កថាខណ្ឌ ២០។

[64] *សូមមើល ខាងក្រោម*។

[65] កំហុសវិជ្ជាជីវៈរបស់មេធាវីនៃគណៈមេធាវីរបស់លោក, ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១២, ឯកសារ E214/1, ទំព័រ ១-១១, ផ្នែក ៦.២។



E.C.C.C * C.E.T.C. SUPREME COURT CHAMBER CHAMBRE DE LA COUR SUPREME

00847679



យល់ឃើញថា ការមាននះនេះ មានភាពសមហេតុផល ដោយយោងទៅលើការខ្វះភាពច្បាស់លាស់នៅក្នុងចំណាត់ការរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងសំណើរបស់មេធាវីការពារក្តី។

22. នៅថ្ងៃទី ១០ ខែ មករា បន្ទាប់ពីមានសំណើផ្ទាល់មាត់លើកទីមួយរបស់មេធាវីការពារក្តី អង្គជំនុំជម្រះសាលាដំបូង ពុំបានផ្តល់សេចក្តីអត្ថាធិប្បាយ ឬការទទួលស្គាល់ណាមួយឡើយ ហើយបានត្រឹមតែបន្តនីតិវិធីជាមួយរបៀបវារៈដែលបានគ្រោងទុកបន្ទាប់ប៉ុណ្ណោះ[66]។ នៅថ្ងៃទី ១៩ ខែ មករា មេធាវីការពារក្តីបានស្នើសុំពិនិត្យតាមដានលើសំណើផ្ទាល់មាត់លើកទីមួយ[67]។ ជាការឆ្លើយតប ប្រធានអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថាអង្គជំនុំជម្រះ "បានកត់សម្គាល់នូវមតិយោបល់របស់មេធាវីរួចហើយ" "មិនធ្វើអត្ថាធិប្បាយអ្វីចំពោះការលើកឡើងរបស់មេធាវីការពារក្តី នួន ជា នេះទេ" និង "បានរំឭក" មេធាវីការពារក្តីថា អង្គជំនុំជម្រះមិនអនុញ្ញាតឱ្យលើកបញ្ហានេះតទៅទៀតរបៀបនេះដែរ[68]។ កាលពីថ្ងៃទី ២៣ ខែ មករា មេធាវីការពារក្តីបានព្យាយាមម្តងទៀត ដើម្បីទទួលបានការបញ្ជាក់ជាក់លាក់អំពីចំណាត់ការណាមួយ ប្រសិនបើមានទៅលើសំណើផ្ទាល់មាត់លើកទីមួយ។ ជាពិសេស មេធាវីការពារក្តីបានសួរថា តើនឹងមានសេចក្តីសម្រេចណាមួយលើសំណើនេះ ដែរ ឬយ៉ាងណា[69]។ ជាការឆ្លើយតប អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា "បញ្ហានេះនឹងត្រូវយកទៅពិចារណានាពេលសមស្របខាងមុខ" ទោះបីជាអង្គជំនុំជម្រះបានបញ្ជាក់ជាថ្មីថា មេធាវីការពារក្តីគប្បីបញ្ឈប់ការលើកឡើងបញ្ហានេះតទៅទៀត[70]។

23. អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា "ការបានឃើញ" សំណើផ្ទាល់មាត់លើកទីមួយរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី ១៩ ខែ មករា និងបានបញ្ជាក់ដល់មេធាវីការពារក្តីនៅថ្ងៃទី ២៣ ខែ មករា ថា "បញ្ហានឹងត្រូវបានយកទៅពិចារណានាពេលសមស្របខាងមុខ" ប្រធានអង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ថា អង្គជំនុំជម្រះនឹងងាកមកពិចារណាលើបញ្ហានេះនៅពេលណាមួយ។ ប៉ុន្តែ ទោះបីប្រវត្តិនីតិវិធីដូចដែលបានកត់ត្រា មានភាពត្រឹមត្រូវ និងពេញ

[66] ប្រតិចារឹក, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២, ឯកសារ E1/24.1, ទំព័រ ៣; *សូមមើលផងដែរ* ប្រតិចារឹក, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២, E1/24.1, ទំព័រ ៦ (ដែលបានគូសបញ្ជាក់ថាទង្វើដែលបានកើតមានបន្ទាប់ ពីមានសេចក្តីថ្លែងរបស់សហព្រះរាជអាជ្ញាតបទៅនឹងសំណើផ្ទាល់មាត់លើកទីមួយ)។

[67] ប្រតិចារឹក, ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២, ឯកសារ E1/30.1, ទំព័រ ៧៧-៧៩។

[68] ប្រតិចារឹក, ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២, ឯកសារ E1/30.1, ទំព័រ ១១៣ (បន្ទាត់ ១៦-២០)។

[69] ប្រតិចារឹក, ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១២, ឯកសារ E1/31.1, ទំព័រ ១-២។

[70] ប្រតិចារឹក, ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១២, ឯកសារ E1/31.1, ទំព័រ ២-៣។



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME E.C.C.C * C.E.T.C

លេញក៏ដោយ ក៏សំណើផ្ទាល់មាត់លើកទីមួយរបស់មេធាវីការពារក្តី ពុំដោះស្រាយដោយមានភាពច្បាស់លាស់នោះទេ។ ការប្រកាសរបស់អង្គជំនុំជម្រះ ពុំមានភាពប្រាកដប្រជា ឬជាក់លាក់ឡើយ និងពុំបានបញ្ជាក់អំពីវិធានការដែលអង្គជំនុំជម្រះមានបំណងអនុវត្ត។ នៅពេលបកស្រាយជាមួយនឹងការព្រមានជាថ្មីរបស់អង្គជំនុំជម្រះសាលាដំបូង ដល់មេធាវីការពារក្តី ការណែនាំបានបញ្ជាក់ដដែលៗមិនឱ្យលើកបញ្ហានេះជាថ្មី និងបញ្ហាដែលនឹងមានលក្ខណៈរសើប ការប្រកាសដែលមិនមានភាពច្បាស់លាស់ទាំងនេះ អាចត្រូវបានបកស្រាយយ៉ាងសមហេតុផលថា ជាសញ្ញាមួយដែលបង្ហាញថា អង្គជំនុំជម្រះបានទុកបញ្ហានេះមួយឡែក ពិសេសដោយយល់ឃើញថា បញ្ហានេះអាចជាបញ្ហារសើប។ ប្រការនេះញ៉ាំងឱ្យកិច្ចខិតខំរបស់មេធាវីការពារក្តី ក្នុងការបញ្ជាក់បំភ្លឺអំពីស្ថានភាពនៃសំណើផ្ទាល់មាត់លើកទីមួយនេះ ហាក់ដូចជាពុំខុសឆ្គងឡើយ[71]។

---

[71] អង្គជំនុំជម្រះតុលាការកំពូលកត់សំគាល់បន្ថែមទៀតថានៅពេលធ្វើការប្រៀបធៀបទៅនឹងអង្គជំនុំជម្រះនៅក្នុងតុលាការICTY និង ICTR ដែលក្នុងនោះ មេធាវីការពារក្តីទទួលរងការព្រមាន ឬការដាក់វិន័យចំពោះសំណើសុំច្រំដែរនោះ សំណើរបស់មេធាវីការពាក្តីសុំការបំភ្លឺនៅក្នុងរឿងក្តីបច្ចុប្បន្ននេះ ពុំមានលក្ខណៈធ្ងន់ធ្ងរចំពោះពេលវេលា ឬចំនួននៃសំណើនោះទេ។ ការដាក់វិន័យ និងការព្រមានរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តីនៅតុលាការ ICTY និង ICTR ធ្វើឡើងបន្ទាប់ពីមានការដាក់សំណើលាយលក្ខណ៍អក្សរច្រំដែរដោយមេធាវីការពារក្តីស្តីពីបញ្ហា ដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរលើកមុនដោយអង្គជំនុំជម្រះ។ *សូមមើល ឧទាហរណ៍ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Prlić និងជនដទៃទៀត*, សំណុំរឿងលេខ IT-04-74-T, "សេចក្តីសម្រេចស្តីពីសំណើសុំធ្វើការពិចារណាឡើងវិញ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១០ និងសំណើលើវិធាន ៧៣ (ឃ) នៃវិធានផ្ទៃក្នុង ចំពោះមេធាវីការពារក្តីរបស់ Prlić", អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១០, ទំព័រ ៤ដល់ ៥ (ការយល់ឃើញអំពីការរំលោភនីតិវិធីដោយមេធាវីការពារក្តីចំពោះការដាក់សំណួរមកលើអង្គជំនុំជម្រះអំពីភាពអាចទទួលយកបាននៃកំណត់ត្រាជាវីដេអូដែលមានរយៈពេលជាងមួយឆ្នាំ និងបណ្តាលឱ្យអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចចំនួនប្រាំបីលើបញ្ហាតែមួយ); *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Prlić និងជនដទៃទៀត*, សំណុំរឿងលេខ IT-04-74-T, "សេចក្តីសម្រេចស្តីពីសំណើរបស់មេធាវីការពារក្តី Prlić សុំការបញ្ជាក់ដើម្បីធ្វើបណ្តឹងសាទុក្ខ", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៩, ទំព័រ ២ ដល់ ៣ (ព្រមានដល់មេធាវីការពារក្តីថា នឹងដាក់ទណ្ឌកម្មចំពោះ "ភាពមានះរឹងរូសឥតហេតុ" ចំពោះបញ្ហាដែលអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរចំនួនប្រាំកាលពីលើកមុន); *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Nyiramasuhuko និងជនដទៃទៀត*, សំណុំរឿងលេខ ICTR-97-21-T និងលេខ ICTR-98-42-T, "សេចក្តីសម្រេចលើសំណើរបស់ Nyiramasuhuko សុំឱ្យដំណើរការនីតិវិធីដាច់ពីគ្នា, ការជំនុំជម្រះក្តីថ្មីមួយ, និងផ្អាកដំណើរការនីតិវិធីតាមវិធាន ៨២(ខ) និង ៧២(ឃ) នៃវិធានស្តីពីនីតិវិធី និងភស្តុតាង", អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦, កថាខណ្ឌ ៨១ ដល់ ៨៤ (ដាក់ទណ្ឌកម្ម មេធាវីការពារក្តីដោយបានលើកឡើងក្នុងសំណើសុំចុះថ្ងៃទី ខែ កុម្ភៈ ឆ្នាំ ២០០៦ នូវការចោទប្រកាន់អំពីភាពប៉ះពាល់ដល់សិទ្ធិ ដែលមេធាវីការពារក្តីបានលើកឡើងការពីមុន ហើយអង្គជំនុំជម្រះបានដោះស្រាយរួចហើយជាលាយលក្ខណ៍អក្សរនៅក្នុងឆ្នាំ ២០០០ និងសារជាថ្មីម្តងទៀតក្នុងឆ្នាំ ២០០៤។ លើសពីនេះទៀត ក្នុងឆ្នាំ ២០០៤ *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង*

SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME * E.C.C.C * C.E.T.C

*ii. ចរិតលក្ខណៈគតិយុត្តនៃសេចក្ដីសម្រេចដោយផ្ទាល់មាត់ និងសំណើជាលាយលក្ខណ៍អក្សរ*

24. មេធាវីការពារក្ដីពុំបានពេញចិត្តទៅនឹងសេចក្ដីសម្រេចផ្ទាល់មាត់ ដោយបានអះអាងថាសេចក្ដីសម្រេចនេះ"តាមពិត ពុំមែនជាសេចក្ដីសម្រេចលើសំណើរបស់ខ្លួនឡើយ"[72]។ ផ្អែកលើមូលហេតុនេះ មេធាវីការពារក្ដីបានដាក់សំណើជាលាយលក្ខណ៍អក្សរ ដោយទំនងជាជឿថាសេចក្ដីសម្រេចដោយផ្ទាល់មាត់នេះពុំបើកផ្លូវសម្រាប់បណ្ដឹងសាទុក្ខភ្លាមៗឡើយ[73]។ នៅពេលយល់ថា សំណើជាលាយលក្ខណ៍អក្សរ "បានត្រឹមតែពង្រីកវិសាលភាពបន្ថែម" ពីលើសំណើផ្ទាល់មាត់កាលពីពេលមុន ដែលត្រូវបានសេចក្ដីសម្រេចដោយផ្ទាល់មាត់ចាត់ការរួចរាល់ហើយនោះ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសនៅក្នុងសេចក្ដីសម្រេចដែលត្រូវបានជំទាស់របស់ខ្លួនថា ខ្លួនមិនទទួលយកសំណើខាងលើនេះឡើយ ដោយហេតុថា សំណើខាងលើគឺជា "ការដាក់ឯកសារច្រំដែល ឬ បណ្ដឹងសាទុក្ខក្លែងភេទ"[74]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញានៅតែប្រកាន់ជំហាថាបណ្ដឹងសាទុក្ខជំទាស់នឹងសេចក្ដីសម្រេចនេះ ដែលពាក់ព័ន្ធនឹងបញ្ហាទាំងប៉ុន្មានដែលត្រូវបានលើកក្នុងសំណើជាលាយលក្ខណ៍អក្សរ គួរត្រូវបានបដិសេធ ដោយសារវាជាបណ្ដឹងសាទុក្ខយឺតយ៉ាវ[75] ដោយហេតុថា ពេលវេលាកំណត់សម្រាប់ការដាក់បណ្ដឹងសាទុក្ខ បានចាប់ផ្ដើមគិតពីពេលអង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចដោយផ្ទាល់មាត់ ហើយសេចក្ដីសម្រេចដែលត្រូវបានជំទាស់នេះគ្រាន់តែជា "ការរៀបរាប់លម្អិត" ប៉ុណ្ណោះ[76]។

25. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា *ជាបឋម* សេចក្ដីសម្រេចរបស់តុលាការត្រូវតែបង្ហាញ *ការបញ្ជាក់ណាមួយ* អំពីចំណាត់ការតាមផ្លូវតុលាការមួយដែលច្បាប់អនុញ្ញាត។ ត្រង់

---

អង្គជំនុំជម្រះ បានព្រមានយ៉ាងច្បាស់ដល់មេធាវីការពារក្ដីថា ការតវ៉ាក្ដីឡើងវិញចំពោះបញ្ហាដែលបានដោះស្រាយរួចហើយក្នុងឆ្នាំ ២០០០ គឺជា"ចេតនារារាំងដល់កិច្ចដំណើរការនីតិវិធី")។ ដូច្នេះ រឿងក្ដីបច្ចុប្បន្ននេះមានលក្ខណៈខុសប្លែកពីគេ ដោយសារតែ សំណើផ្ទាល់មាត់របស់មេធាវីការពារក្ដីមិនដូនទៅនឹងការតវ៉ាក្ដីឡើងវិញស្ដីពីការប៉ះពាល់សិទ្ធិដែលអង្គជំនុំជម្រះសាលាដំបូងមិនបានដោះស្រាយបញ្ហានេះឱ្យបានច្បាស់លាស់ និងជាក់លាក់ក្នុងពេលសវនាការ និងដោយសារតែភាពច្រំដែរនៃសំណើនេះពុំសូវមានលក្ខណៈខ្លាំងខ្លា។

[72] ប្រតិចារឹក, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២, ឯកសារ E1/40.1, ទំព័រ ៤ (បន្ទាត់ ៩-១២)។

[73] ប្រតិចារឹក, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២, ឯកសារ E1/40.1, ទំព័រ ៤ (បន្ទាត់ ៩-១២)។

[74] សេចក្ដីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ២៣។

[75] សារណាតប, កថាខណ្ឌ ៧-១២។

[76] សេចក្ដីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ២៣, ផ្នែក ៥.២។

ចំណុចនេះ ជាការចាំបាច់ដែលសេចក្តីសម្រេចមួយតាមផ្លូវតុលាការត្រូវចាត់ការលើបញ្ហាអង្គច្បាប់មួយ ដែលស្ថិតនៅចំពោះមុខខ្លួនឲ្យបានច្បាស់លាស់[77]។ ហេតុដូច្នេះ សេចក្តីសម្រេចតាមផ្លូវតុលាការគួរគប្បីមានផ្នែកមួយដែលមានអានុភាព (" ខ សម្រាប់អនុម័តច្បាប់" ឬ "ផ្នែកសម្រេចសេចក្តី") ដែលដោះស្រាយចំពោះអង្គសេចក្តី ហើយ/ឬ បញ្ហានីតិវិធី ដោយបង្កើត កែប្រែ បដិសេធចោល ឬទទួលយកនូវទំនាក់ទំនងដែលសំអាងលើច្បាប់ ដែលមានជាប់ពាក់ព័ន្ធទៅនឹងភាគីនានា។ លើសពីនេះទៀត ជាទម្លាប់អនុវត្តដ៏ខ្ជាប់ខ្ជួនរបស់ អ.វ.ត.ក ដែលសេចក្តីសម្រេចដែលបើកផ្លូវប្តឹងសាទុក្ខ ដោយអនុលោមតាមវិធានផ្ទៃក្នុង ត្រូវចេញជាលាយលក្ខណ៍អក្សរ។ ការអនុវត្តន៍នេះ ទោះបីជាមិនបានតម្រូវដោយច្បាប់ក៏ដោយ ក៏បានផ្តល់នូវភាពច្បាស់លាស់ និងតម្លាភាពនៃកិច្ចដំណើរការនីតិវិធីដូចដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ហើយនិងអាចផ្តល់ឱ្យមានដំណើរការពិនិត្យមើលឡើងវិញប្រកបដោយប្រសិទ្ធភាព[78]។ ជាងនេះទៀត ដូចដែល

---

[77] ដើម្បីភាពច្បាស់លាស់ដ៏ចាំបាច់នៃកិច្ចដំណើរការរបស់តុលាការ, *សូមមើល* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ និងដីកាលេខ D250/3/2 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ ស្តីពីភាពអាចទទួលយកបាននូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, "យោបល់របស់ចៅក្រមប្រាក់ គឹមសាន និងចៅក្រម Rowan Downing ទាក់ទងនឹងភាពមិនអាចទទួលយកបានដែលត្រូវបានប្រកាសជាសាធារណៈចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានអនុញ្ញាត", អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១០, ឯកសារលេខ D250/3/2/1/5, កថាខណ្ឌ ១៣ ("សវនាការប្រកបដោយយុត្តិធម៌ ឬការសម្រេចពីបញ្ហាណាមួយនោះ នឹងត្រូវជាប់ពាក់ពន្ធ័មិនត្រឹមតែសិទ្ធិដឹងពីសំណុំរឿងដែលខ្លួនត្រូវឆ្លើយ និងសិទ្ធិទទួលបានការជំនុំជម្រះប៉ុណ្ណោះទេ ថែមទាំងសិទ្ធិទទួលបានភាពយុត្តិធម៌នៃដំណើរការនីតិវិធី។ ភាពយុត្តិធម៌នៃដំណើរការនីតិវិធីក្នុងន័យនេះ ត្រូវរួមបញ្ចូលដំណើរការនីតិវិធីប្រកបដោយតម្លាភាព និងស្របច្បាប់ ដែលសិទ្ធិ និងកាតព្វកិច្ច ត្រូវបានផ្តល់ជូន សម្តែងចេញ និងអនុវត្តដោយត្រឹមត្រូវ។ ក្នុងន័យនេះ មានការសង្ឃឹមទុកយ៉ាងច្បាស់លាស់ថា បញ្ហាមួយនឹងត្រូវបានដោះស្រាយដោយជាក់លាក់ ពិតប្រាកដ និងសមស្រប")។ *សូមមើលផងដែរ* សាលដីកាលេខ F28, ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ៤៨២ ដល់ ៤៨៣, និង ៥០១ (ការអះអាងយ៉ាងច្បាស់លាស់ចំពោះកាតព្វកិច្ចរបស់តុលាការក្នុងការដោះស្រាយលើស្ថានភាពដែលធ្វើឱ្យមានការភាន់ច្រឡំផ្នែកនីតិវិធីដើម្បីផ្តល់ភាពយុត្តិធម៌)។

[78] តាមក្របខ័ណ្ឌគតិយុត្តរបស់ *អ.វ.ត.ក* សេចក្តីសម្រេចដែលមានកង្វះទម្រង់ជាលាយលក្ខណ៍អក្សរ លើកលែងតែសាលក្រមពុំបានបណ្តាលឱ្យមានមោឃភាពឡើយ។ ប៉ុន្តែ ភាពស្មុគស្មាញនៃបញ្ហាដែលបានដោះស្រាយដោយ អ.វ.ត.ក មានន័យថាមានការតវ៉ាក្តីផ្ទាល់មាត់តិចតួច ដែលពុំបានដាក់ជាលាយលក្ខណ៍អក្សរ។ នៅចំពោះមុខរឿងក្តីនេះ ពុំមានសេចក្តីសម្រេចណាមួយដែលបើកផ្លូវឱ្យប្តឹងសាទុក្ខនោះ ត្រូវបានចេញដោយផ្ទាល់មាត់ដែរ។ នៅតុលាការ ICTY និង ICTR, ការសម្រេចជាទម្រង់ផ្ទាល់មាត់ ត្រូវបានអនុញ្ញាតយ៉ាងពិសេស តាមវិធាននៃនីតិវិធី និងភស្តុតាង។ *សូមមើល* វិធាននៃនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY (RPE), វិធាន ៧៧ (K) (សេចក្តីសម្រេចស្តីពីការប្រមាថតុលាការអាចចេញដោយផ្ទាល់មាត់បាន)។ វិធាននៃ



E.C.C.C * C.E.T.C. SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME

អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងក្នុងឱកាសខុសៗគ្នាថា រាល់សេចក្តីសម្រេចតាមផ្លូវតុលាការទាំងអស់ មិនថា ជាសេចក្តីសម្រេចផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរឡើយ ត្រូវតែប្រកាន់ខ្ជាប់នូវកាតព្វកិច្ចរបស់តុលាការក្នុងការផ្តល់សំអាងហេតុគ្រប់គ្រាន់ ចំពោះសេចក្តីសម្រេចទាំងនោះ ដែលជាផលនៃការគោរពសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌[79]។ ជាការពិតណាស់ សិទ្ធិទទួលបានសេចក្តីសម្រេចដែលមានសំអាងពេញលេញ គឺជាផ្នែកមួយនៃសិទ្ធិទទួលបានការជំនុំជម្រះ[80]។ ជាការសន្និដ្ឋាន នៅពេលដែលតុលាការបានចេញសេចក្តីសម្រេចមួយ សេចក្តីសម្រេចនោះគួរគប្បីសំអាងលើទម្រង់ និងខ្លឹមសារនៃទង្វើ ជាជាងការចេញសេចក្តីសម្រេចដោយសំអាងលើ "ការបកស្រាយដ៏សមហេតុផលបំផុតនៃកំណត់

---

នីតិវិធី និងភស្តុតាងរបស់តុលាការ ICTY (RPE), វិធាន ១៥ *ស្ទួន* (D),(F) (សេចក្តីសម្រេចទាក់ទងទៅនឹងបញ្ហាថាតើត្រូវបន្តកិច្ចដំណើរការនីតិវិធីជាមួយនឹងចៅក្រមជំនួសដោយពុំមានការយល់ព្រមពីជនជាប់ចោទនោះ អាចចេញដោយផ្ទាល់មាត់បាន)។ វិធាននៃនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY (RPE), វិធាន ៥៤ *ស្ទួន* (C)(ii) (សេចក្តីសម្រេចទាក់ទងនឹងការបដិសេធចោលលើសំណើ *ជាបឋម* និងសេចក្តីសម្រេចទាក់ទងនឹងការចេញដីការឱ្យបង្កើតឯកសារដោយមិនបានផ្តល់ការជូនដំណឹងដល់រដ្ឋ ឬឱកាសជំនុំជម្រះ អាចចេញដោយផ្ទាល់មាត់បាន)។ វិធាននៃនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY (RPE), វិធាន ៦៥ (D) (សេចក្តីសម្រេចទាក់ទងនឹងការដោះលែងដោយបណ្តោះអាសន្ន អាចចេញដោយផ្ទាល់មាត់បាន)។ *សូមមើល* លក្ខខណ្ឌតម្រូវនៃទម្រង់, សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបានលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតស្តីពីការរំលោភនូវការសម្ងាត់នៃកិច្ចស៊ើបសួររបស់តុលាការ, ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៩, ឯកសារលេខ D138/1/8, កថាខណ្ឌ ៣៩, និង ៤៤ (អះអាងថា លិខិតរបស់សហចៅក្រមស៊ើបអង្កេតមិនមែនជាដីកាទេតាមអត្ថន័យនៃវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ)។

[79] សេចក្តីសម្រេចលើសំណើសុំដោះលែងបន្ទាន់របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១,ឯកសារ E50, កថាខណ្ឌ ២៣-២៧ និងយុត្តិសាស្ត្រដែលបានយោងជាមួយនោះ។

[80] អ្នកនិពន្ធ Stefan Treschel, ចំណងជើងថា *សិទ្ធិមនុស្សនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ (Human Rights in Criminal Proceedings)*, សារពត៌មានរបស់សាកលវិទ្យាល័យ Oxford, ឆ្នាំ ២០០៥, ទំព័រ ១០៤ ("តុល្យភាពតទល់នៃកំលាំង និងគោលការណ៍ចំពោះមុខនៃនីតិវិធី អាចឱ្យភាគីបញ្ចេញទស្សនទានចំពោះអង្គហេតុ និងអង្គច្បាប់ និងលើកឡើងនូវទឡ្ហីករណ៍ដែលខ្លួនជឿថាចាំបាច់ក្នុងការធ្វើឱ្យស្ថានប័នដែលជាអ្នកធ្វើសេចក្តីសម្រេច ធ្វើការសម្រេចដោយគាំទ្រខ្លួន។ ប៉ុន្តែ លក្ខខណ្ឌតម្រូវនេះ មិនអាចធានាបាននូវការចាប់អារម្មណ៍ពីស្ថាប័ននេះទេ។ ប្រាកដណាស់ ពុំមានលទ្ធភាពផ្ទៀងផ្ទាត់ដោយផ្ទាល់ថាតើ មានអ្នកដែលបានស្តាប់ ឬយល់នូវអ្វីដែលបាននិយាយ ឬថាតើឯកសារនេះមានគេចាប់អារម្មណ៍ដែរ ឬទេ។ [...] អានុភាពនៃមាត្រា ៦ កថាខណ្ឌ ១ បានដាក់ឱ្យ"តុលាការព្រហ្មទណ្ឌ" ទទួលភារកិច្ចធ្វើការពិនិត្យលើសារណា ទឡ្ហីករណ៍ និងភស្តុតាង [illegible] ដោយភាគី")។

ហេតុសវនាការ" ដូចជាខ្លឹមសារជាក់ស្តែងដែលសហព្រះរាជអាជ្ញាបានលើកឡើងនោះទេ[81]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ចម្លើយរបស់អង្គជំនុំជម្រះសាលាដំបូងតបទៅនឹងសំណើនានារបស់មេធាវីការពារក្តី រួមទាំងសេចក្តីសម្រេចដោយផ្ទាល់មាត់ ពុំស្របជាមួយទម្លាប់អនុវត្តន៍ និងគោលការណ៍ជាមូលដ្ឋាន និងអាចមានការភ័ន្តច្រឡំអំពីលក្ខណៈគតិយុត្តិ និងផលវិបាកនៃសេចក្តីសម្រេចទាំងនោះ។

26. ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះដែលទទួលបានសំណើ ត្រូវពិនិត្យទៅលើការចោទប្រកាន់ ត្រូវវាយតម្លៃលើបញ្ហាថាតើ ជាអប្បបរមា មានសំអាងដែលអាចជឿបានថា អំពើណាមួយដែលមានចែងក្នុងវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង អាចត្រូវបានប្រព្រឹត្តឡើង និងត្រូវសម្រេចធ្វើសកម្មភាពសមស្រប ប្រសិនបើមាន ដោយអនុលោមតាមវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះតុលាការកំពូល បានកត់សម្គាល់ឃើញថា សំណើផ្ទាល់មាត់លើកទីមួយ ពុំត្រូវបានចាត់ទុកជាសំណើសុំដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ឡើយ។ ចំពោះបញ្ហានេះ សេចក្តីសម្រេចដោយផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង ពុំបានសំអាងលើមូលដ្ឋានផ្លូវច្បាប់ឡើយ។ ប៉ុន្តែអ្វីដែលសំខាន់បំផុតនោះ សេចក្តីសម្រេចមួយនេះ ពុំបានពន្យល់ ថាតើការចោទប្រកាន់របស់មេធាវីការពារក្តី បានអនុលោមតាមវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង ដែរ ឬយ៉ាងណា ដែលបទដ្ឋាននៃការបង្ហាញភស្តុតាង ត្រូវបានប្រើប្រាស់នៅក្នុងការពិនិត្យមើលការចោទប្រកាន់ទាំងនោះ ហើយថាតើ សំណើផ្ទាល់មាត់លើកទីមួយ ត្រូវបានទទួលយក ឬត្រូវបានបដិសេធចោល។ អាស្រ័យហេតុនេះ សេចក្តីសម្រេចដោយផ្ទាល់មាត់ហាក់ដូចជាពុំមែនជាចំណាត់ការតាមផ្លូវតុលាការលើបញ្ហាអង្គសេចក្តី ឬបញ្ហានីតិវិធីណាមួយនៅក្រោមអំណាចសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ ផ្ទុយទៅវិញ សេចក្តីសម្រេចផ្ទាល់មាត់នេះ គឺជាការប្រកាសមួយដែលពុំមានអំណាចតាមផ្លូវច្បាប់ ហើយពុំមានសំអាងហេតុ។ ផ្អែកលើកំណត់ហេតុទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលពុំទាន់ប្រាកដឡើយថា តើមុនពេលនៃការដាក់សំណើជាលាយលក្ខណ៍អក្សរ ក្របខ័ណ្ឌគតិយុត្តិ ដូចមានចែងក្នុងវិធាន ៣៥ វិធានផ្ទៃក្នុង ត្រូវបានពិនិត្យពិចារណាពាក់ព័ន្ធនឹងប្រសាសន៍របស់លោកនាយករដ្ឋមន្ត្រី ដែរ ឬយ៉ាងណា។ គួរឱ្យកត់សម្គាល់ផងដែរ អង្គជំនុំជម្រះសាលាដំបូង ពុំបានឆ្លើយតប ទៅនឹងការបញ្ជាក់របស់មេធាវីការពារក្តីដែលថា សេចក្តីសម្រេចដោយផ្ទាល់មាត់នេះ បិទផ្លូវបណ្តឹងសាទុក្ខភ្លាមៗ ដោយកាន់តែដាក់មន្ទិលទៅលើចរិត

[81] សារណាតប, កថាខណ្ឌ ១០។

លក្ខណៈផ្នែកតិយុត្តិនៃសេចក្តីសម្រេចដោយផ្ទាល់មាត់នេះ។ ហេតុដូច្នេះ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងមានចេតនាអនុវត្តចំណាត់ការដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង នៅពេលប្រកាសសេចក្តីសម្រេចដោយផ្ទាល់មាត់របស់ខ្លួនក៏ដោយ ក៏ចេតនានេះ ពុំបានស្តែងឱ្យឃើញដូចសព្វមួយដងឡើយ។

27. បន្ថែមទៅលើការមិនអនុវត្តតាមទម្រង់ជាលាយលក្ខណ៍អក្សរ និងធ្វើឱ្យភាគីមានការភាន់ច្រឡំ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា សេចក្តីសម្រេចដោយផ្ទាល់មាត់ដែលបានធ្វើដាច់ដោយឡែកពុំស្របទាំងស្រុងជាមួយសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានសេចក្តីសម្រេច ដែលមានសំអាងហេតុឡើយ។ ហេតុដូច្នេះ សេចក្តីសម្រេចដែលរងការជំទាស់ ផ្តល់សំណងចំពោះការរំលោភបំពាននេះ និងដូចដែលមេធាវីការពារក្តីបានទទួលស្គាល់[82] ជនជាប់ចោទពុំរងព្យសនកម្មណាមួយលើផ្នែកនៃការទទួលបានសេចក្តីសម្រេចមួយដែលមានសំអាងហេតុឡើយ។

28. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញទៀតថា សំណើជាលាយលក្ខណ៍អក្សរ ពុំគប្បីត្រូវបានចាត់ទុកថាមិនអាចឱ្យទទួលយកបានឡើយនៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់នោះ។ ដោយមិនរាប់បញ្ចូលនូវភាពច្រំដែលនោះ សំណើនេះ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងដោះស្រាយឱ្យបានច្បាស់លាស់ពីដំបូង ដែលភាពស្រពេចស្រពិលនេះជាប់ពាក់ព័ន្ធទៅនឹងសំណើផ្ទាល់មាត់លើកទីមួយ ។ អង្គជំនុំជម្រះសាលាដំបូង ពុំបានបញ្ជាក់ពីគុណវឌ្ឍិនៃសំណើជាលាយលក្ខណ៍អក្សរថាជា "បណ្តឹងសាទុក្ខក្លែងភេទ" ឡើយ[83]។ ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូង មានហេតុផលអាចឱ្យជឿដូច្នេះ សំណើជាលាយលក្ខណ៍អក្សរ ត្រូវបានការចំណាត់ដូចជាៈ អង្គជំនុំជម្រះសាលាដំបូង គប្បីបានបញ្ជូនសំណើនេះទៅកាន់អង្គជំនុំជម្រះតុលាការកំពូល ដើម្បីពិនិត្យពិចារណា។ ជាចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូល សង្កេតឃើញថា សេចក្តីសម្រេចដែលរងការជំទាស់នោះមិនត្រឹមតែ "ការរៀបរាប់លម្អិត"នៃសេចក្តីសម្រេចផ្ទាល់មាត់ ប៉ុណ្ណោះទេ ថែមទាំង រួមបញ្ចូលនូវ ការយល់ឃើញថ្មីដែលមានមិនមានក្នុសេចក្តីសម្រេចផ្ទាល់មាត់នោះ[84]។

---

[82] បណ្តឹងសាទុក្ខ, កថាខណ្ឌ ១៩។

[83] សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ២៣។

[84] *សូមមើលឧទាហរណ៍* សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣១ (ដែលក្នុងនោះ អង្គជំនុំជម្រះសាលាដំបូងលើកឡើងដោយច្បាស់លាស់ថា ខ្លួនបានចេញ ដោយសន្មតថា តាមរយៈសេចក្តីសម្រេចផ្ទាល់មាត់ "ការរំលឹកជាសាធារណៈ ដែល មានលក្ខណៈច្បាស់លាស់ (...) នូវការតម្រូវឱ្យមន្ត្រីជៀសវាងការធ្វើអត្ថាធិប្បាយដែលមានលក្ខណៈមិនសមស្របជាមួយនឹង *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង*

29. មានតែសេចក្តីសម្រេចដែលមានសំអាងហេតុប៉ុណ្ណោះ ទើបធ្វើឱ្យសិទ្ធិក្នុងការប្តឹងសាទុក្ខមានអត្ថន័យពេញលេញ។ ដោយហេតុថា សេចក្តីសម្រេចដែលមានសំអាងហេតុត្រឹមត្រូវលើសំណើសុំផ្ទាល់មាត់លើកដំបូង គឺជាសេចក្តីសម្រេចដែលត្រូវរងការជំទាស់ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា កាលបរិច្ឆេទសម្រាប់ការដាក់បណ្តឹងសាទុក្ខ ចាប់គិតពីថ្ងៃចេញសេចក្តីសម្រេចដែលរងការជំទាស់នេះមក។ អំណះអំណាងរបស់សហព្រះរាជអាជ្ញាដែលថា បណ្តឹងសាទុក្ខនេះត្រូវបានដាក់ក្រោយពេលកំណត់ គឺពុំមានមូលដ្ឋានត្រឹមត្រូវឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា បណ្តឹងសាទុក្ខនេះ អាចទទួលយកបានតាមវិធាន ៣៥(៦) នៃវិធានផ្ទៃក្នុង និងវិធាន ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុង ដែលដាក់ត្រឹមត្រូវតាមពេលកំណត់។

30. លើសពីនេះ អង្គជំនុំជម្រះសាលាដំបូង មិនបានកំណត់ចរិតនៃសេចក្តីសម្រេចផ្ទាល់មាត់នេះឱ្យបានត្រឹមត្រូវ។ ការភាន់ច្រឡំនេះ បណ្តាលឱ្យសំណើសុំជាលាយលក្ខណ៍អក្សរ មិនអាចទទួលយកបាន។ ជាលទ្ធផល សិទ្ធិទទួលបានការពិនិត្យលើបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ត្រូវបានរារាំង។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទឡ្ហីករណ៍ទីបីនៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ចង្អុលបង្ហាញយ៉ាងត្រឹមត្រូវអំពីកំហុសអង្គច្បាប់នៅក្នុងសេចក្តីសម្រេចដែលទទួលរងការជំទាស់នោះ។ កំហុសឆ្គងនេះ មោឃៈសេចក្តីសម្រេចនោះ ត្រង់ចំណុចដែលសេចក្តីសម្រេចនេះយល់ឃើញថា សំណើជាលាយលក្ខណ៍អក្សរនេះមិនអាចទទួលយកបានដោយសំអាងលើមូលដ្ឋាននៃ*អាជ្ញាអស់ជំនុំ*។

### ខ. វិសាលភាព និងភាពអាចអនុវត្តន៍នៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង

31. ដោយពិចារណាទៅលើភាពស្រពេចស្រពិលដែលកើតមានក្នុងការចេញសេចក្តីសម្រេចដែលរងការជំទាស់ អង្គជំនុំជម្រះតុលាការកំពូល ត្រូវដោះស្រាយវិសាលភាព និងភាពអាចអនុវត្តបាន*ដែលជាសេចក្តីបញ្ញាក់ដំបូង* នៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដែលចែងនៅក្នុងផ្នែកពាក់ព័ន្ធថា៖

**វិធាន ៣៥: ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ**

(វិសោធនកម្មថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៩)

១. អង្គជំនុំជម្រះវិសាមញ្ញអាចដាក់ទណ្ឌកម្ម ឬ បញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច

---

គោលការណ៍សន្មតថាឥតទោស"។ អង្គជំនុំជម្រះ មិនអាចយល់ឃើញ ឬបញ្ជាក់នៅក្នុងសេចក្តីសម្រេចផ្ទាល់មាត់នេះ[illegible] ណាមួយដូចនេះឡើយ)។

*សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង*

E.C.C.C. SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME

នូវជនណាម្នាក់ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដ ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ រួមទាំងបុគ្គលដែលមានចែងដូចខាងក្រោម:

ក-ផ្សាយចេញព័ត៌មានសម្ងាត់ ដោយរំលោភទៅនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ។

ខ-ដោយគ្មានមូលហេតុសមស្រប បុគ្គលដែលមិនគោរពតាមសេចក្ដីបង្គាប់ឱ្យចូលរួមក្នុងដំណើរការជម្រះក្ដី ឬ មិនផ្ដល់ឯកសារ ឬ ភស្ដុតាងផ្សេងទៀតឱ្យសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ។

គ-បំផ្លាញ ឬ កែក្លែងតាមមធ្យោបាយណាក៏ដោយលើឯកសារ វត្ថុតាង ឬ ភស្ដុតាងដទៃទៀតដែលស្ថិតក្នុងសំណុំរឿងរបស់អង្គជំនុំជម្រះវិសាមញ្ញ។

ឃ-គំរាមកំហែង បំភិតបំភ័យ បង្ករបួសស្នាម ឬ ផ្ដល់សំណូក ឬ ក៏ជ្រៀតជ្រែកលើសាក្សីណាម្នាក់ ឬ លើអ្នកដែលអាចក្លាយជាសាក្សីដែលកំពុងផ្ដល់ បានផ្ដល់ ឬ អាចផ្ដល់ភស្ដុតាងដល់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ។

ង-គំរាមកំហែង បំភិតបំភ័យ ឬសូកសំណូក ឬ ស្វែងរកវិធីគាបសង្កត់លើបុគ្គលដទៃទៀតក្នុងបំណងទប់ស្កាត់បុគ្គលនោះមិនឱ្យអនុវត្តតាមដីការបស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ។

ច-ជួយដោយចេតនាដើម្បីឱ្យជនត្រូវចោទ ឬជនជាប់ចោទរត់គេចពីអំណាចយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។ ឬ ញុះញង់ ឬ ប៉ុនប៉ងប្រព្រឹត្តិអំពើណាមួយដូចមានចែងខាងលើ។

២. នៅពេលដែលសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ មានហេតុផលជឿថា បុគ្គលណាម្នាក់អាចធ្លាប់បានប្រព្រឹត្តិអំពើណាមួយ ដូចចែងក្នុងអនុវិធាន ១ ខាងលើ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ អាច ៖

ក-ចាត់ការជាមួយបញ្ហានេះជាបន្ទាន់។

ខ-ដឹកនាំការស៊ើបសួរបន្ថែម ដើម្បីឱ្យដឹងប្រាកដថា តើមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់ការតាមនីតិវិធី ។ឬ

គ-បញ្ជូនបញ្ហានេះទៅឱ្យអាជ្ញាធរមានសមត្ថកិច្ច របស់ព្រះរាជាណាចក្រកម្ពុជា ឬ អង្គការសហប្រជាជាតិ។



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME * E.C.C.C * C.E.T.C *

[...]

៤. ច្បាប់កម្ពុជាជាធរមានត្រូវអនុវត្តចំពោះករណីទណ្ឌកម្មនីមួយៗ លើបុគ្គលណាម្នាក់ដែលត្រូវបានរកឃើញថាបានប្រព្រឹត្តអំពើណាមួយ ដូចមានចែងក្នុងអនុវិធាន ១។

32. ជាដំបូង យើងចាប់ផ្តើមដោយធ្វើការកត់សម្គាល់ថា ការប្រព្រឹត្តិដែលស្ថិតក្រោមវិសាលភាពនៃវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង អាច ប៉ុន្តែមិនចាំបាច់ ជាអំពើព្រហ្មទណ្ឌឡើយ[85]។ លើសពីនេះទៀត មិនដូចជាតុលាការអន្តរជាតិនានាដែលដំណើរការនៅក្រៅ ក្របខណ្ឌស្ថាប័នរបស់រដ្ឋ និងត្រូវតែអនុវត្តអំណាចរបស់ខ្លួនដើម្បីដាក់ទណ្ឌកម្មទៅលើការប្រមាថ ទៅលើតុលាការ ដោយផ្អែកទៅលើអំណាច[86]នៅក្នុងបរិបទច្បាប់ស៊ីវិល (civil law) និង តុលាការកូនកាត់ អ.វ.ត.ក វិធាន ៣៥

---

[85] សេចក្តីសម្រេចដែលរងការជំទាស់ ត្រង់ជើងទំព័រ ២៨ មានសេចក្តីបញ្ជាក់មួយដែលពិបាកយល់ ៖ "កិច្ចដំណើរការនីតិវិធីអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង គឺជាកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ទើបចំណុះឲ្យគោលការណ៍ធម្មតានៃ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ"។ អត្ថន័យនៃប្រយោគនេះ គឺមានលក្ខណៈមិនច្បាស់ ទោះបីជានៅក្នុងបរិបទក្តី។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងកម្រិតដែលគេអាចយល់ថា វិធាន ៣៥ នៃវិធានផ្ទៃក្នុង កំណត់អំពីបទឧក្រិដ្ឋ ឬផ្តល់អំណាចទៅឲ្យចៅក្រមដើម្បីកំណត់អំពីបទឧក្រិដ្ឋនោះ វាមិនត្រឹមត្រូវទេ។

[86] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E116/1/7 កថាខណ្ឌ ៣០ ជើងទំព័រ ៦៥ (ដែលយោងទៅលើឯកសារដូចខាងក្រោមនេះ ៖ របាយការណ៍របស់គណៈកម្មាធិការស្តីអំពីការប្រមាថតុលាការ, UK Cmnd. 5794 (1974) (ដែលត្រូវបានគេហៅថា "របាយការណ៍របស់គណៈកម្មាធិការ Phillimore") ទំព័រ ២ កថាខណ្ឌ ១ ("ច្បាប់ ទាក់ទិននឹងការប្រមាថតុលាការ បានអភិវឌ្ឍជាច្រើនទសវត្សរ៍មកហើយជាមធ្យោបាយមួយដែលតុលាការអាចយកមកអនុវត្តដើម្បីបង្ការ ឬដាក់ទណ្ឌកម្មដល់អំពើណាដែលមានចេតនារារាំង ធ្វើឲ្យប៉ះពាល់ ឬរំលោភលើកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ទាក់ទិនទៅនឹងករណីពិសេសមួយ ឬទូទៅ") ។ ទំព័រ ៧ កថាខណ្ឌ ១៤ (បែងចែកករណីនៃការប្រមាថជា "ការប្រមាថនៅក្នុងតុលាការ" និង "ការប្រមាថនៅក្រៅតុលាការ"។ ការប្រមាថនៅក្រៅតុលាការ រួមមានអំពើដែលទំនងជាជ្រៀតជ្រែកចូលក្នុងកិច្ចការតុលាការ ការសងសឹកទៅលើសាក្សី ឬភាគី ធ្វើឲ្យអាស្រូវដល់តុលាការ និងការមិនប្រតិបត្តិតាមសេចក្តីបង្គាប់របស់តុលាការ)។ *រឿងក្តី Johnson ទល់នឹង Grant* [1923] S.C. 789, ទំព័រ ៧៩០ ("បទល្មើស [ប្រមាថតុលាការ] រួមមាន នៅក្នុងការជ្រៀតជ្រែកចូលក្នុងកិច្ចការ រដ្ឋបាលរបស់តុលាការ នៅក្នុងការរារាំង និងការធ្វើឲ្យខូចដល់ដំណើរការយុត្តិធម៌ [...]។ វាមិនមែនជាសេចក្តីថ្លៃថ្នូររបស់តុលាការឡើយដែលត្រូវបានប្រមាថ...។ វាគឺជាភាពឧត្តមបំផុតនៃច្បាប់ដែលត្រូវបានជំទាស់តវ៉ា")។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Tadic*, IT-94-1-A-R77, "សាលដីកាលើការចោទប្រកាន់អំពីការប្រមាថប្រឆាំងនឹងអតីតមេធាវី Milan Vujin" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ១៥, ១៧ (យល់ឃើញថា ទោះបីជាទស្សនាទាននៃការប្រមាថតុលាការបានអភិវឌ្ឍជានិម្មិតកម្មនៃច្បាប់អង់គ្លូសាក់សុង (common law) យ៉ាងណាក៏ដោយ ក៏ប្រព័ន្ធច្បាប់ស៊ីវិល (civil law) ជាច្រើនសម្រេចបាននូវលទ្ធផលស្រដៀងគ្នា តាមរយៈ...



SUPREME COURT CHAMBER * E.C.C.C * C.E.T.C. * CHAMBRE DE LA COUR SUPRÊME

---

ដែលត្រូវបានកំណត់និយមន័យយ៉ាងចង្អៀតប្រឆាំងនឹងកិច្ចការរដ្ឋបាលរបស់តុលាការ) ជើងទំព័រ ១៦ (បង្ហាញថា របាយការណ៍របស់គណៈកម្មាធិការ Phillimore ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយជាការវាយតម្លៃយ៉ាង ត្រឹមត្រូវមួយ អំពីគោលបំណង និងវិសាលភាពច្បាប់នៃការប្រមាថតុលាការ))។ *សូមមើល ផងដែរ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Beqaj,* IT-03-66-T-R77, "សាលក្រមលើការចោទប្រកាន់អំពីការប្រមាថតុលាការ" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៥ កថាខណ្ឌ ៩។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Aleksovski,* សំណុំរឿងលេខ IT-95-14/1-AR77, "សាលដីកាលើបណ្តឹងសាទុក្ខរបស់ Anto Nobilo ប្រឆាំងនឹងការរកឃើញអំពីការប្រមាថតុលាការ" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០១ កថាខណ្ឌ ៣០ (ដកស្រង់ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Tadic,* "សាលក្រមលើការចោទប្រកាន់អំពីការប្រមាថតុលាការប្រឆាំងនឹងអតីតមេធាវី Milan Vujin" កថាខណ្ឌ ១៣)។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Milosevic,* សំណុំរឿងលេខ IT-02-54-A-R77.4, "សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំលើការប្រមាថដំណើរការនីតិវិធីរបស់ Kosta Bulatovic", អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៥ កថាខណ្ឌ ២១។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Blagojevic,* IT-02-60-T, "សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី ឯករាជ្យ របស់ Vidoje Blagojevic ណែនាំដល់ប្រធានរដ្ឋបាលឱ្យតែងតាំងសហមេធាវីនាំមុខថ្មី" អង្គជំនុំជម្រះសាលា ដំបូង ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០០៣ កថាខណ្ឌ ១១២ (បញ្ជាក់ថា វាគឺជាកាតព្វកិច្ចពេញលេញរបស់អង្គជំនុំជម្រះក្នុង ការធានានូវការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌ និងកិច្ចការរដ្ឋបាលដ៏ត្រឹមត្រូវរបស់តុលាការ ដោយពិចារណាចាត់ វិធានការណាមួយដើម្បី ធានាថា "យុត្តិធម៌មិនត្រឹមតែត្រូវសម្រេចឱ្យបានប៉ុណ្ណោះទេ ប៉ុន្តែត្រូវតែបង្ហាញឱ្យឃើញ ថាមានយុត្តិធម៌ផងដែរ")។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Rwamakuba,* សំណុំរឿងលេខ ICTR-98-44C-T, "សេចក្តីសម្រេចលើការ ផ្តល់សំណងសមស្រប" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៧។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Karemera និងជនដទៃទៀត,* សំណុំរឿងលេខ ICTR-98-44-PT, "សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើ Andre Rwamakuba និងការកែដីកាចោទប្រកាន់ មាត្រា ២០(៤) នៃលក្ខន្តិកៈ វិធាន ៨២(ខ) នៃវិធានស្តីពីនីតិវិធី និងភស្តុតាង" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០០៤ កថាខណ្ឌ ២២។ និង ៖ *រឿងក្តី Nuclear Tests* (ប្រទេសនូវែលសេឡង់ ទល់នឹង ប្រទេសបារាំង) សាលក្រម របាយការណ៍របស់ I.C.J. ឆ្នាំ ១៩៧៤ ទំព័រ ៤៦៣ កថាខណ្ឌ ២៣ ("តុលាការមានយុត្តាធិការពេញលេញ ដែលអាចឱ្យតុលាការចាត់វិធានការចាំបាច់ដើម្បី ធានាថា ការអនុវត្ត យុត្តាធិការរបស់ខ្លួនទៅលើអង្គសេចក្តី ប្រសិនបើត្រូវបានបង្កើតឡើង មិនត្រូវបានរារាំងឡើយ ហើយ [...] ថា តួនាទីផ្នែកតុលាការជាមូលដ្ឋានអាចត្រូវបានការពារ")។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Blaskic,* សំណុំរឿងលេខ IT-95-14, "សាលដីកាលើសំណើរបស់សាធារណរដ្ឋក្រូអាស៊ី សុំឱ្យពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង II ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៧" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៣៣, ៥៥ (ស្នើឡើងថា អំណាចពេញលេញមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងបេសកម្មដែលប្រគល់ទៅឱ្យតុលាការ និងមានគោលបំណងធានា ថា តួនាទីជាមូលដ្ឋានរបស់តុលាការត្រូវបានបំពេញឱ្យបានពេញលេញ)។ *សូមមើល ផងដែរ រឿងក្តី Barayagwiza ទល់នឹង រដ្ឋអាជ្ញា,* សំណុំរឿងលេខ ICTR-97-19-AR72, "សាលដីកា" អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៧៦ ("វាត្រូវបានគេទទួលស្គាល់ជាទូទៅថា តុលាការមានអំណាចត្រួតពិនិត្យដែលអាចត្រូវបាន យកទៅប្រើដើម្បីផលប្រយោជន៍យុត្តិធម៌ [...] ការប្រើប្រាស់អំណាចត្រួតពិនិត្យបែបនេះមានមុខងារបីយ៉ាង ៖ ដើម្បី ផ្តល់នូវសំណងចំពោះការរំលោភសិទ្ធិជនជាប់ចោទ ដើម្បីរារាំងកុំឱ្យមានការប្រព្រឹត្តិ...

*សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង*

SUPREME COURT CHAMBER CHAMBRE DE LA ... E.C.C.C * C.E.T.C

នៃវិធានផ្ទៃក្នុង ពុំមែនជាប្រភពតែមួយគត់គ្រប់គ្រាន់នៃការកំណត់បទល្មើសព្រហ្មទណ្ឌទេ ហើយ វិធាននេះក៏មិនបានប្រើប្រាស់អំណាច ក្នុងការកំណត់អំពើព្រហ្មទណ្ឌដោយផ្អែកមូលដ្ឋានពិសេស ឡើយ នៅពេលដែលទទួលបានបណ្តឹងស្តីពីបញ្ហានៃការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាល។ ដូច្នេះ ទោះបីជាវិធាន ៣៥ នៃវិធានផ្ទៃក្នុង ស្រដៀងទៅនឹងបទបញ្ញត្តិទាក់ទិននឹងការប្រមាថតុលាការ ដែលអាចត្រូវផ្តន្ទាទោសនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយសារអំពើដែលច្បាប់បានហាមឃាត់ក៏ដោយ[87] ក៏វិធាននេះមានលក្ខណៈខុសគ្នាយ៉ាងខ្លាំង និងមិនបានកំណត់នូវមូលដ្ឋាន *ពិសេស* (*sui generis*) សម្រាប់ដាក់ទណ្ឌកម្ម និងការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ[88]។

---

នៅពេលអនាគត និងដើម្បី លើកកម្ពស់នូវសុចរិតភាពនៃដំណើរការតុលាការ")។ *រឿងក្តី សហរដ្ឋអាមេរិក ទល់នឹង* Hasting តុលាការកំពូលសហរដ្ឋ អាមេរិក (ឆ្នាំ១៩៨៣) 461 U.S. 499 ទំព័រ *៥០៥-៥០៦*។ *រឿងក្តី Mesarosh ទល់នឹង សហរដ្ឋអាមេរិក* តុលាការកំពូល សហរដ្ឋអាមេរិក (ឆ្នាំ១៩៥៦) វ៉ុល ៣៥២ U.S. ទំព័រ ១ ទំព័រ ១៤ (ដែលនៅក្នុងរឿងក្តីនោះ តុលាការកំពូលសហរដ្ឋអាមេរិកបាន បញ្ជាក់អំពីយុត្តាធិការត្រួតពិនិត្យរបស់ខ្លួនទៅលើកិច្ចដំណើរការនីតិវិធីរបស់តុលាការសហព័ន្ធ "ដើម្បីឲ្យដឹងថា ទន្លេនៃយុត្តិធម៌មិនត្រូវបានបំពុល (the waters of justice are not polluted)"។ *រឿងក្តី* McNabb *ទល់នឹង សហរដ្ឋអាមេរិក* តុលាការកំពូលសហរដ្ឋអាមេរិក (ឆ្នាំ១៩៤៣) វ៉ុល ៣១៨ U.S. ទំព័រ ៣៣២ ៣៤០-៤១ ៣៤៧ (ដែលនៅក្នុងរឿងក្តីនោះ តុលាការកំពូលសហរដ្ឋអាមេរិក បានបញ្ជាក់អំពី "អំណាចត្រួតពិនិត្យរបស់ខ្លួនទៅលើកិច្ចការរដ្ឋបាលរបស់តុលាការព្រហ្មទណ្ឌ" ដែល "សំដៅទៅលើតួនាទីក្នុងការបង្កើត និងរក្សាបទដ្ឋានស្តីពីនីតិវិធី និងភស្តុតាង ប្រកបដោយអារ្យធម៌" ដោយសារតួនាទីរបស់តុលាការនេះជា "តុលាការមានអំណាចត្រួតពិនិត្យចុងក្រោយ")។

[87] *សូមមើល ឧទាហរណ៍* វិធាន ៧៧(ក) (ខ) នៃវិធានស្តីពីនីតិវិធី និងការដាក់ភស្តុតាងរបស់តុលាការ ICTY។

[88] សូម្បីតែនៅឯតុលាការ ICTY បញ្ហានេះមិនត្រូវបានទទួលយកជាទូទៅឡើយ។ អ្នកធ្វើអត្ថាធិប្បាយបានកត់សម្គាល់យ៉ាងល្អិតល្អន់ថា ការផ្អែករបស់តុលាការ ICTY លើលិទ្ធិច្បាប់នៃអំណាច ក្រៅពីវិធាននៃនីតិវិធី និងភស្តុតាង ឬ អ្វីៗដែលអាចបញ្ជាក់បានចេញពីអំណាចនេះ បានពង្រីកនូវអំណាចរបស់តុលាការនៃការដាក់ទោសការប្រមាថ ដែលរំលោភគោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែង(*nullum crimen sine lege*)។ *សូមមើល*អ្នកនិពន្ធ Michael Bohlander, "តុលាការព្រហ្មទណ្ឌអន្តរជាតិ និងអំណាចរបស់ខ្លួនក្នុងការដាក់ទណ្ឌកម្មលើការប្រមាថ និងការផ្តល់សក្ខីកម្មក្លែងក្លាយ", ចំណងជើងថា វេទិកាច្បាប់ព្រហ្មទណ្ឌ *Criminal Law Forum*, វ៉ុល ១២ (ឆ្នាំ ២០០១), ទំព័រ ១១, ១៧ (យល់ឃើញថា លើកលែងតែ តុលាការ ICTY និង ត្រង់កម្រិតណាមួយនោះ តុលាការ ICTR, "គ្មានតុលាការ ឬតុលាការព្រហ្មទណ្ឌដទៃទៀត យោងទៅលើបទប្បញ្ញត្តិស្តីពីការប្រមាថតុលាការ ដែលមានមូលដ្ឋានទៅលើគោលការណ៍នៃអំណាចនោះទេ" និង ជំទាស់ថា តុលាការ ICTY ដូចតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀតដែរ មានអំណាចដែលត្រឹមតែសបញ្ជាក់ តែមិនមានអំណាចជាសារវ័ន្តនេះទេ ដោយសារ អំណាចនេះ គឺជាលទ្ធិច្បាប់នៃលក្ខន្តិកៈ និងវិធាននៃនីតិវិធី និងភស្តុតាង។ Bohlander បានសន្និដ្ឋានថា "ការបង្កើត ជាក់ស្តែងនៃបទល្មើសព្រហ្មទណ្ឌ តាមវិធាននៃនីតិវិធី និងភស្តុតាង អាចជាប់ពាក់ព័ន្ធទៅនឹងបញ្ហាថាតើ បទល្មើសនេះចាំបាច់តាមលទ្ធិច្បាប់នៃអំណាចដែលអាចសបញ្ជាក់នោះដែរ ឬយ៉ាងណា") ។ Göran Sluiter, "តុលាការ ICTY និង បទល្មើសប្រឆាំងនឹងរដ្ឋបាលតុលាការ", *ព្រឹត្តប័ត្រនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ Journal of International Criminal Justice*, [illegible]



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME E.C.C.C * E.C.T.C

ពិតណាស់ វិធានផ្ទៃក្នុង ៣៥(៤) នៃវិធានផ្ទៃក្នុង ចែងយ៉ាងច្បាស់នូវការអនុវត្តច្បាប់កម្ពុជាទាក់ទិននឹងការដាក់ទណ្ឌកម្មលើអំពើនានាដែលមានចែងនៅក្នុងអនុវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង។ ដូច្នេះ ប្រសិនបើអំពើមួយចំនួនដែលមានចែងនៅក្នុងវិធាន ៣៥ នៃវិធានផ្ទៃក្នុង ឈានដល់កម្រិតមួយជាលក្ខណៈព្រហ្មទណ្ឌនោះ ច្បាប់ដែលអាចយកមកអនុវត្តបានពាក់ព័ន្ធនឹងអំពើដែលត្រូវបានហាមឃាត់ និង បុគ្គលដែលត្រូវទទួលខុសត្រូវ គឺច្បាប់កម្ពុជា[89]។ វាមានន័យទៀតថា ច្បាប់ព្រហ្មទណ្ឌកម្ពុជានៅតែ មានសុពលភាពគ្រប់គ្រងទៅលើបញ្ហានានា ដូចជាទម្រង់នៃការទទួលខុសត្រូវ និង ធាតុផ្សំនៃបទ ឧក្រិដ្ឋ។

33. យោងតាមការសង្កេតនេះ អង្គជំនុំជម្រះតុលាការកំពូលត្រូវតែសម្រេចនូវសារៈសំខាន់ នៃវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង ដែលមានលក្ខណៈជាបទដ្ឋាន។ ដូចដែល អ.វ.ត.ក បានកត់សម្គាល់កាលពីលើកមុនៗរួចហើយ[90] អនុវិធាននេះបញ្ជាក់ ដោយបានធ្វើការចង្អុលបង្ហាញ អំពីទម្រង់មួយចំនួន

---

២០០៤), ទំព័រ ៦៣៥ (លើកឡើងថា តាមទស្សនទាននៃសច្ចភាពផ្លូវច្បាប់ ការពង្រីកអំណាចនៃការដាក់ទណ្ឌកម្មនៃការប្រមាថរបស់តុលាការ ICTY ដើម្បីអនុវត្តទៅតាមទម្រង់នៃការប្រមាថ មិនស្ថិតក្នុងវិសាលភាពនៃបទប្បញ្ញត្តិនៃវិធាន ៧៧ នៅពេលដែលអនុវត្តតាមរយៈលទ្ធិច្បាប់នៃអំណាចជាក់ស្តែងនោះ មិន"មានលក្ខណៈសមស្របនោះទេ" ដោយសារតែ"ដោយផ្ទុយទៅនឹងបទឧក្រិដ្ឋសំខាន់ៗ, ពុំមានភស្តុតាងណាមួយបង្ហាញអំពីអត្ថិភាព និងខ្លឹមសារនៃការប្រព្រឹត្តបទល្មើសផ្នែកនីតិវិធី តាមច្បាប់អន្តរជាតិ ឧទាហរណ៍ក្នុងទម្រង់ជាសិទ្ធិសញ្ញាឡើយ") ។ កង្វះខាតនៃការទទួលយកអំណាចស្តីពីការប្រមាថដែលជាបទល្មើសព្រហ្មទណ្ឌរបស់តុលាការព្រហ្មទណ្ឌពិសេស អាចបង្ហាញឱ្យឃើញក្នុងរឿងក្តីប្រមាថតុលាការប្រឆាំងនឹង Florence Hartman នៅចំពោះមុខតុលាការ ICTY។ ក្នុងន័យនេះដែរ ក្រសួងការបរទេសបារាំងមិនអនុវត្តតាមដីកាចាប់ខ្លួនរបស់តុលាការ ICTY ប្រឆាំងនឹងអ្នកការសែត Florence Hartman ពីបទប្រមាថតុលាការ ដោយសារការប្រមាថនេះ មិនមែនជាឧក្រិដ្ឋកម្មសំខាន់។ អ្នកនាំពាក្យក្រសួងការបរទេសបានថ្លែងថា "កិច្ចព្រមព្រៀងរបស់បារាំងជាមួយតុលការ ICTY តម្រូវឱ្យបារាំងអនុវត្តនូវដីកាប្រឆាំងនឹងជនណាដែលត្រូវបានចោទប្រកាន់ពីបទ ឧក្រិដ្ឋធ្ងន់ធ្ងរ ប៉ុន្តែមិនមែនជាបទល្មើសប្រឆាំងនឹងតុលាការ ដូចជាបទល្មើសនៃការប្រមាថតុលាការ។ ដោយហេតុថា ការប្រមាថតុលាការដែលលោកស្រី Florence Hartman ទទួលរងការផ្តន្ទាទោះ មិនមែនជាបទឧក្រិដ្ឋធ្ងន់ធ្ងរឡើយ ដូចនេះ បារាំងគ្មានមូលដ្ឋានផ្លូវច្បាប់ដើម្បីសហការឡើយ"។ គេហទំព័រក្រសួងការបរទេសបារាំង ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១១, <http://www.diplomatie.gouv.fr/fr /enjeux-internationaux/justice-internationale/droit-penal-international/tpi-yougoslavie/actualites-19222/article/tpiy-condamnation-de-florence>។

[89] សូមមើល ឧទាហរណ៍ ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ មាត្រា ៣១៤ និងបទល្មើសនានាដែលកំណត់និយមន័យនៅក្នុងមាតិកាទី២ "ការប៉ះពាល់ដល់វិស័យយុត្តិធម៌" នៃគន្ថីទី៤។

[90] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង... បណ្តឹងជិតចិត្តលោកស្រីចៅក្រម Silvia Cartwright អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២...

*សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង*

SUPREME COURT CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE LA COUR SUPRÊME

នៃអំពើដែលអាចចាត់ជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាល។ អនុវិធាននេះមិនបានកំណត់អំពើដែលច្បាប់បានហាមឃាត់ឲ្យបានលម្អិតឡើយ ហើយអនុវិធាននេះក៏មិនកម្រិតត្រឹមតែវិសាលភាព ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជា[91]។ ការចែងដែលបើកចំហបែបនេះ បង្ហាញថាសញ្ញាណនៃការជ្រៀតជ្រែកនៅក្នុងវិធាន ៣៥ នៃវិធានផ្ទៃក្នុង មានលក្ខណៈទូលំទូលាយ ហើយអំពើនានាដែលស្ថិតនៅក្រោមវិធានផ្ទៃក្នុងនេះ អាចមាន ឬមិនមានលក្ខណៈព្រហ្មទណ្ឌ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ ដោយគាំទ្រលើការបញ្ជាក់របស់អង្គបុរេជំនុំជម្រះ អំពីទំនាក់ទំនងនៃមុខងាររវាងវិធាន ២១ និងវិធាន ៣៥ នៃវិធានផ្ទៃក្នុង[92]។ យ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូល បញ្ជាក់នេះថា វិធាន ២១ នៃវិធានផ្ទៃក្នុង ដែលចែងអំពីគោលការណ៍ទូទៅនៃការបកស្រាយ[93] ដូចដែលបានបញ្ជាក់រួចហើយនោះ មិនអាចយកមកប្រើដើម្បីពង្រីកវិសាលភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ក្នុងកម្រិតមួយដែលរំលោភទៅលើគោលការណ៍*គ្មានបទល្មើស បើគ្មានច្បាប់ចែង (nullum crimen sine lege)* នោះឡើយ។ ប៉ុន្តែ វិធាន ៣៥ នៃវិធានផ្ទៃក្នុង បើបកស្រាយផ្គួបគ្នាជាមួយនឹងវិធាន ២១ នៃវិធានផ្ទៃក្នុង បានរួមបញ្ចូល ទាំងបទ ល្មើស ប្រឆាំង

---

E137/5/1/3 កថាខណ្ឌ ១៨ (ដែលយោងទៅលើសេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្ដឹង ឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសេចក្ដីប្រកាស ព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១ ឯកសារ D14/1/3 កថាខណ្ឌ ២៧)។ សូមមើល ផងដែរ សេចក្ដីសម្រេចលើសំណើរបស់លោក អៀង សារី សុំឲ្យមានការ ស៊ើបអង្កេត អនុលោមតាមវិធាន ៣៥ ទៅលើសកម្មភាពនៃ [...] ទាក់ទិនទៅនឹងការប្រាស្រ័យទាក់ទងការងារជាមួយតែភាគីម្ខាង [...] ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១០ ឯកសារ លេខ ៣ (សម្ងាត់) កថាខណ្ឌ ២១ និង សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាសម្រេចលើសំណើលើកទីពីររបស់លោក នួន ជា សុំឲ្យបំពេញកិច្ចស៊ើបសួរ (វិធាន ៣៥) ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១០ ឯកសារ D384/5/2 (សម្ងាត់) កថាខណ្ឌ ៤៣-៤៤។

[91] យើងកត់សម្គាល់ឃើញថា សេចក្ដីសម្រេចដែលរងការជំទាស់ លើកឡើងនូវភាពចែកដាច់ពីគ្នានៃការឆ្លើយតបរបស់ អ.វ.ត.ក យោងតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង កថាខណ្ឌ ២០ ដល់ ២២ ប៉ុន្តែ ផ្ទុយទៅវិញផ្ដោតទៅលើភាពខុសគ្នានៅក្នុងបទដ្ឋានតម្រូវនៃការបង្ហាញភស្តុតាង។

[92] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខប្រឆាំងនឹងដីកាស្ដីពីសំណើទីពីររបស់ នួន ជា សុំបើកកិច្ចស៊ើបសួរតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះ ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១០ ឯកសារលេខ D384/5/2 (សម្ងាត់) កថាខណ្ឌ ៤៤ (ក្នុងបរិបទនៃការគាបសង្កត់ដែលត្រូវបានចោទប្រកាន់ ឱ្យដកហត្ថលេខាចេញពីដីកាចាត់តាំងឱ្យស៊ើបសួរជំនួស)។

[93] សេចក្ដីសម្រេចស្ដីពីបណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំដោះលែងជាបន្ទាន់ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E50/2/1/4 កថាខណ្ឌ ៣៩។

*សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង*

នឹងការជ្រៀតជ្រែកកិច្ចការរដ្ឋបាលតុលាការ (ដូចដែលបានកំណត់នៅក្នុងលក្ខន្តិកៈព្រហ្មទណ្ឌកម្ពុជា) និងបទល្មើសដែលមិនមែនជាបទព្រហ្មទណ្ឌប្រឆាំងនឹងរដ្ឋបាលតុលាការ។ ដោយពុំមានច្បាប់កម្ពុជាពាក់ព័ន្ធ នេះគឺស្ថិតនៅលើចៅក្រមរបស់ អ.វ.ត.ក និងអង្គជំនុំជម្រះជាអ្នកសម្រេចលើបទល្មើសទាំងនោះដែលមិនមែនជាបទព្រហ្មទណ្ឌ ដែលស្ថិតក្នុងវិសាលភាពនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង។

### *i. ធាតុផ្សំសត្យានុម័ត*

34. បញ្ញត្តិហាមឃាត់ជាក់លាក់នីមួយៗ ដែលមានចែងនៅក្នុងវិធាន ៣៥(១)(ក) ដល់ (ច) តម្រូវឱ្យមានកិច្ចខំប្រឹងប្រែងមួយ ដើម្បីបង្អាក់សិទ្ធិអំណាច ឬដំណើរការរបស់តុលាការ។ អនុកថាខណ្ឌ (ក) (ខ) និង (ង) គឺស្ដីពីការមិនអនុវត្តតាមដីការបស់តុលាការ។ អនុកថាខណ្ឌ (គ) និង (ឃ) ដោះស្រាយការជ្រៀតជ្រែកទៅលើការផ្ដល់ភស្តុតាង នៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការ។ អនុកថាខណ្ឌ (ច) ចែងអំពីការជួយទៅជនជាប់ចោទឱ្យរួចផុតពីយុត្តាធិការរបស់តុលាការ។ អនុលោមតាមវិធានក្នុង *ប្រភេទដូចគ្នា (ejusdem generis)* នៃការបកស្រាយច្បាប់ មានតែអំពើដែលស្រដៀងទៅនឹង មូលដ្ឋានផ្សេងៗដែលត្រូវបានរៀបរាប់ប៉ុណ្ណោះ ដែលត្រូវចាត់ទុកថាស្ថិតនៅក្នុងវិសាលភាពនៃ វិធាន ៣៥ នៃវិធានផ្ទៃក្នុង[94]។

35. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា សារៈសំខាន់របស់អំពើនៃការជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរដ្ឋបាលតុលាការជាក់លាក់ណាមួយ ដោយអនុលោមតាមវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង ត្រូវបានកំណត់ទៅតាមផលប៉ះពាល់អរូបី និងផលប៉ះពាល់ជាក់ស្តែងនៃអំពើនេះ។ ការជ្រៀតជ្រែកជាក់ស្តែងចូលទៅក្នុងកិច្ចដំណើរការនីតិវិធី មិនចាំបាច់ថា អំពើបែបនោះប៉ះពាល់ដល់ធម្មានុរូបភាពរបស់តុលាការជាមួយនឹងភាគីនានា និងសាធារណជនទូទៅទេ[95]។

---

[94] សេចក្តីសម្រេចលើបណ្តឹងសារទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីបណ្តឹងជិតចិត្តលោកស្រី Silvia Cartwright អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E137/5/1/3 កថាខណ្ឌ ១៩។

[95] *សូមមើល ឧទាហរណ៍ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Jović,* សំណុំរឿងលេខ IT-95-14, "សាលដីកា" អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៧ កថាខណ្ឌ ៣០ ("ការបំពានណាមួយទៅលើដីកា គឺមានលក្ខណៈជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរដ្ឋបាលតុលាការ សម្រាប់គោលបំណងនៃការផ្តន្ទាទោសចំពោះការប្រមាថ។ ពុំមានការតម្រូវឱ្យមាននូវភស្តុតាងបន្ថែម អំពីព្យសនកម្មទៅលើកិច្ចការរដ្ឋបាលតុលាការរបស់តុលាការអន្តរជាតិឡើយ")។ *សូមមើល ផងដែរ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង*

36. ជាពិសេស អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការសម្រេចរបស់តុលាការដែលមានកំហុស មិនមានលក្ខណៈគ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការបំពេញនូវបទដ្ឋាននៃវិធាន ៣៥ ឡើយ[96]។ អង្គជំនុំជម្រះបានយល់ឃើញបន្ថែមទៀតថា ទោះបីជាមានវិធានជាក់លាក់មួយចំនួនដោះស្រាយទៅលើប្តឹងជំទាស់ និងការដាក់វិន័យ ក៏ដោយ ជាគោលការណ៍ ចៅក្រម ឬមេធាវី យ៉ាងហោចណាស់ ក៏ត្រូវស្ថិតក្នុងវិសាលភាពនៃវិធាន ៣៥ ដែរ ប្រសិនបើ ការប្រព្រឹត្តដែលរងការចោទប្រកាន់នោះ ឈានដល់កម្រិតមួយនៃការជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ យោងតាមខ្លឹមសារនៃវិធាននេះ[97]។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងយល់ឃើញ នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ថា អំពើដែលមានចែងក្នុងវិធាន ៣៥ នៃវិធានផ្ទៃក្នុង រួមមាន"ការជះឥទ្ធិពលមិនត្រឹមត្រូវទៅលើចៅក្រមដែលទទួលបន្ទុករឿងក្តី"[98] ឬជា"ការប្រព្រឹត្តក្នុងវិធីមួយដែលគេយល់ថា ជាការប៉ុនប៉ងប្រើឥទ្ធិពលបែបនេះ"[99]។ ប្រហាក់ប្រហែលគ្នានេះដែរ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា "វិធាន ២១(១) នៃវិធានផ្ទៃក្នុង គឺតម្រូវឲ្យវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង គ្របដណ្តប់ទៅលើទង្វើនៃការគាបសង្កត់ ពីមជ្ឈដ្ឋានខាងក្រៅ មកលើចៅក្រមណាម្នាក់នៃ អ.វ.ត.ក ដោយក្នុងនោះរួមទាំង ទង្វើនៃការញុះញង់ និងការប៉ុនប៉ងផងដែរ"[100]។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា អំពើដែលប៉ះពាល់ដល់ឯករាជ្យភាព និងភាពអនាគតិរបស់ចៅក្រម ដូចជា ការគាបសង្កត់ គឺជាការជ្រៀតជ្រែកដែលត្រូវបានហាមឃាត់នៅក្នុងវិធាន ៣៥ (១) នៃ

---

*ក្តីរដ្ឋអាជ្ញា ទល់នឹង* *Marijačić* និង *Rebić*, សំណុំរឿងលេខ IT-95-14-R77.2-A, "សាលដីកា" អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ៤៤។

[96] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យជនជាប់ចោទមានវត្តមានក្នុងសវនាការ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១២ ឯកសារ E130/4/3, ទំព័រ ២។

[97] សេចក្តីសម្រេចលើបណ្តឹងសារទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី បណ្តឹងជំទាស់លោកស្រី Silvia Cartwright អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E137/5/1/3 កថាខណ្ឌ ១៤។

[98] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២០។

[99] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២១។

[100] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាសម្រេចលើសំណើលើកទីពីររបស់លោក នួន ជា សុំឲ្យបំពេញកិច្ចស៊ើបសួរ (វិធាន ៣៥) អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១០ ឯកសារ D384/5/2 (សម្ងាត់) កថាខណ្ឌ៤៤។ (នៅក្នុងបរិបទនៃការចោទប្រកាន់អំពីការគាបសង្កត់ឲ្យលុបបាត្តលេខាចេញពីដីកាចាត់ឲ្យស៊ើបសួរជំនួស)។

00847695



វិធានផ្ទៃក្នុង។ អំពើដែលត្រូវបានហាមឃាត់ដទៃទៀត អាចរួមបញ្ចូលទាំងការធ្វើឱ្យមានការរំខាននៅក្នុងបន្ទប់សវនាការ ការយាយីដល់មន្ត្រី និងបុគ្គលិករបស់តុលាការ និងការធ្វើឱ្យប៉ះពាល់ដល់ដំណើរការផ្នែកភស្តុភាររបស់តុលាការ ការបង្កើតនូវកាលៈទេសៈដែលប៉ះពាល់ដល់ការបង្ហាញឱ្យឃើញនូវឯករាជ្យភាព និងភាពអនាគតិរបស់តុលាការ។ ជាការកត់សម្គាល់ ការធ្វើឱ្យប៉ះពាល់ដល់ការបង្ហាញឱ្យឃើញនូវឯករាជ្យភាព និងភាពអនាគតិរបស់តុលាការ គឺជាការជ្រៀតជ្រែកដែលមិនគ្រាន់តែជា"ការបង្ហាញឱ្យឃើញនូវការជ្រៀតជ្រែក" នោះឡើយ[101]។

### *ii. ធាតុផ្សំអត្តនោម័ត*

37. យោងតាមវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង ចែងថា ការប្រព្រឹត្តដែលត្រូវបានបញ្ញត្តិហាមឃាត់ត្រូវតែមាន"ចេតនាពិតប្រាកដ"។ ការទទួលខុសត្រូវជាសត្យានុម័តមិនមានចែងនៅក្នុងវិធានផ្ទៃក្នុងឡើយ។ និយាយម្យ៉ាងទៀតថា ពុំមានការទទួលខុសត្រូវណាមួយតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងដែលផ្អែកលើអង្គហេតុជាក់ស្តែង និងដោយមិនគិតអំពីថាតើអំពើនោះអនុវត្តដោយមានចេតនាផ្ទាល់ ការព្រងើយកន្តើយ ឬការមិនដឹងអំពីលក្ខណៈ និង/ឬផលវិបាកនៃអំពើនោះទេ។ ជាការពិតជម្រើសផ្នែកនីតិវិធីដែលមាននៅតុលាការ ដោយអនុលោមតាមវិធាន ៣៥(២) នៃវិធានផ្ទៃក្នុងគឺសំដៅចំពោះ "បុគ្គលណាម្នាក់ ដែលប្រហែលជាធ្លាប់បានប្រព្រឹត្តិអំពើណាមួយដូចចែងក្នុងអនុវិធាន ១ នៃវិធានផ្ទៃក្នុង"។ ដូចគ្នានេះដែរ វិធាន ៣៥(៤) នៃវិធានផ្ទៃក្នុង លើកឡើងអំពី "ការអនុវត្តចំពោះករណីទណ្ឌកម្មនីមួយៗ លើបុគ្គលណាម្នាក់ ដែលត្រូវបានរកឃើញថា បានប្រព្រឹត្តអំពើណាមួយ ដូចមានចែងក្នុងអនុវិធាន ១ នៃវិធានផ្ទៃក្នុង"។ ដូច្នេះអនុលោមតាមអត្ថន័យសាមញ្ញនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង គឺត្រូវធ្វើឡើងក្នុងគោលបំណងផ្តល់ការឆ្លើយតបដើម្បីដាក់ទណ្ឌកម្ម គឺថា ជាការដាក់ទណ្ឌកម្ម ឬការបញ្ជូនទៅអាជ្ញាធរ ដែលមានសមត្ថកិច្ចទៅលើបុគ្គលណាមួយដែលត្រូវបានចាត់ទុកថា មានចេតនាជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ។

38. ច្បាប់កម្ពុជា ចែងអំពីទម្រង់នៃការជ្រៀតជ្រែក។ ដូច្នេះ លក្ខខណ្ឌតម្រូវនៃ*ធាតុផ្សំអត្តនោម័ត* មិនមែនជាមូលដ្ឋានគ្រប់គ្រាន់តែមួយនៅក្នុងវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង ទេ។ ផ្ទុយមកវិញ

---

[101] សេចក្តីសម្រេចលើបណ្តឹងសារទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី បណ្តឹងជិតចិត្តលោកស្រី Silvia Cartwright អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E137/5/1/3 កថាខណ្ឌ ២១។



E.C.C.C * C.E.T.C SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME

ដោយសារតែវិធាន ៣៥ នៃវិធានផ្ទៃក្នុងអនុវត្តចំពោះអំពើ ដែលមិនមែនជាបទព្រហ្មទណ្ឌធាតុផ្សំអត្តនោម័ត នៅតែត្រូវធ្វើការកំណត់ដដែល ដើម្បីធានានូវការការពារដែលការចែងហាមឃាត់កំណត់ឡើង។ នៅក្នុងករណីនេះ យើងយល់ថា លក្ខខណ្ឌធាតុផ្សំអត្តនោម័តជាក់ លាក់តាមការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ចំពោះការប្រមាថ តុលាការដែលជាបទព្រហ្មទណ្ឌ[102] មានលក្ខណៈតឹងរ៉ឹងខ្លាំងពេកសម្រាប់បទល្មើសផ្នែករដ្ឋបាល។ ជាការគ្រប់គ្រាន់ហើយក្នុងការបង្ហាញថា ការប្រព្រឹត្តិដែលជាការរំលោភបំពាន ត្រូវបានធ្វើដោយមានចេតនា មិនមែនដោយចៃដន្យទេ[103]។ យ៉ាងណាក៏ដោយ អំពើដែលខ្វះលក្ខខណ្ឌធាតុផ្សំអត្តនោម័ត*ជាបឋម* (*prima facie*) មិនស្ថិតនៅក្នុងវិសាលភាពនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុងឡើយ ដែលរារាំងការអនុវត្តដំណើរការនីតិវិធី ឬការអនុវត្តនូវការដាក់ទណ្ឌកម្មនោះ។ ផ្អែកលើសំអាងហេតុទាំងនេះ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា “ទោះបីជាសេចក្តីថ្លែងការណ៍[របស់លោកនាយករដ្ឋមន្ត្រី] ត្រូវបានធ្វើឡើងដោយគ្មានចេតនាអ្វីមួយ ឬមានក៏ដោយ [...] ហេតុដូច្នេះ អង្គជំនុំជម្រះអាចចាត់វិធានការណាមួយ ក្នុងចំណោមវិធានការនានាដូចមានចែងក្នុងវិធាន៣៥(២)នៃវិធានផ្ទៃក្នុង បើទោះបីជាសេចក្តីថ្លែង ការណ៍នេះមិនបណ្តាលឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្ម

---

[102] ដូចដែលមានចែងនៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ២២ ជើងទំព័រលេខ៣៣។

[103] *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Aleksovski,* សំណុំរឿងលេខ IT-95-14/1-AR77,“សាលដីកាលើបណ្តឹងសាទុក្ខរបស់ Anto Nobilo ប្រឆាំងនឹងការរកឃើញអំពីការប្រមាថតុលាការ” អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០១ កថាខណ្ឌ៥៤ (អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការICTY យល់ឃើញថា វាមានលក្ខណៈគ្រប់គ្រាន់ដែលបុគ្គលដែលត្រូវបានចោទប្រកាន់ “បានប្រព្រឹត្តដោយព្រងើយកន្តើយ” ទាក់ទិននឹង[ធាតុផ្សំសម្ភារៈនៃបទល្មើស])។ អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់ថា យុត្តាធិការខុទ្ទរណ៍របស់តុលាការICTYថ្មីៗលើបញ្ហានេះ មានលក្ខណៈខុសពីលក្ខខណ្ឌអត្តនោម័តជាក់លាក់ទេ។ *សូមមើល រឿងក្តីប្រឆាំងនឹង Florence Hartmann* , សំណុំរឿងលេខ IT-02-54-R77.5-A, “សាលដីកា” អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ ១២៨។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Radoslav Brdjanin, សំណុំរឿងលេខ IT-99-36-R77, “*ទាក់ទិននឹងការចោទប្រកាន់លើ* Milka Maglov - សេចក្តីសម្រេចលើសំណើសុំឱ្យមានការលើកលែងការចោទប្រកាន់អនុលោមតាមវិធាន ៩៨ ស្ទួន” ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៤ (“សេចក្តីសម្រេចលើរឿងក្តី *Maglov* អនុលោមតាមវិធាន ៩៨”) កថាខណ្ឌ ៤០ (“ការធ្វេសប្រហែសក្នុងការមិនបានបញ្ជាក់ថា តើ មានដីកាណាដែលមែនជាការប្រមាថតុលាការ។ ការប្រព្រឹត្តបែបនេះ អាចដោះស្រាយបានយ៉ាងគ្រប់គ្រាន់ និងសមស្របតាមវិធីនៃចំណាត់ការដាក់វិន័យ)។



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME * E.C.C.C * C.E.T.C

ទណ្ឌ ដោយអនុលោមតាមវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង ក៏ដោយ"[104] មានវិសាលភាពលើសពីអត្ថន័យសាមញ្ញនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុងទៅទៀត។

*iii. វិធីសាស្ត្រផ្នែកនីតិវិធី តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង*

39. វិធាន ៣៥(២) នៃវិធានផ្ទៃក្នុង ចែងអំពីមធ្យោបាយផ្នែកនីតិវិធី ដែលបើកផ្លូវឱ្យអង្គជំនុំជម្រះកំណត់ នៅពេលដែលមានហេតុផលអាចជឿជាក់ថា បុគ្គលមួយបានប្រព្រឹត្តការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ។ សកម្មភាពផ្អែកតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង គឺជាអំណាចឆន្ទានុសិទ្ធ[105]។ ដោយពិចារណាអំពីភាពខ្វះខាតនៃពេលវេលា និងជាពិសេសធនធានតិចតួចពេក អ.វ.ត.ក មិនទំនងជាធ្វើការកំណត់ការទទួលខុសត្រូវ និងការដាក់ទណ្ឌកម្មព្រហ្មទណ្ឌនោះទេ ប៉ុន្តែចំណាត់ការដែលអាចនឹងអនុវត្ត ក្នុងករណីមានការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ ដែលតាមការ ចោទប្រកាន់ជាបទព្រហ្មទណ្ឌ នឹងត្រូវបញ្ជូនករណីនេះទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចកម្ពុជា។ បន្ថែមពីលើនេះទៀត ។ ទោះជាមានមូលហេតុអាចជឿបានថាមានការជ្រៀតជ្រែកដែលត្រូវបានហាមឃាត់ អ.វ.ត.ក អាចនៅតែសម្រេចចិត្តដោយស្របច្បាប់ក្នុងការមិនស៊ើបអង្កេត និង/ឬដាក់ទណ្ឌកម្ម ក្នុង គោលបំណងទទួលបាននូវប្រសិទ្ធពល[106]។ ទោះបីជាយ៉ាងណាក៏ដោយ

---

[104] សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ២៩។

[105] ដូចដែលបានបង្ហាញឱ្យឃើញតាមរយៈការប្រើប្រាស់ពាក្យ "អាច" នៅក្នុងវិធាន៣៥(១) និង៣៥(២)នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង* Nsengimana, ICTR-01-69-A, "សាលដីកាលើបណ្ដឹងសាទុក្ខរបស់រដ្ឋអាជ្ញាប្រឆាំងលើសេចក្ដីសម្រេចទាក់ទិននឹងការទំនាក់ទំនងមិនត្រឹមត្រូវជាមួយនឹងសាក្សីនានារបស់រដ្ឋអាជ្ញា" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១០ កថាខណ្ឌ២២, ៣៩ (កត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធមិនចាប់ផ្ដើមដំណើរការនីតិវិធីស្ដីពីការប្រមាថតុលាការ ទោះបីជាមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីដំណើរការនីតិវិធី ហើយនៅក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូង មិនតម្រូវឱ្យរៀបរាប់អំពីការសម្រេចរបស់ខ្លួនទាក់ទិននឹងហេតុអ្វីបានជាការចាប់ផ្ដើមដំណើរការនីតិវិធីស្ដីពីការប្រមាថតុលាការ មិនមែនជាមធ្យោបាយមានប្រសិទ្ធិភាព និងប្រសិទ្ធិផល ជាពិសេសចាប់តាំងពីអង្គជំនុំជម្រះសាលាដំបូង ពិនិត្យយ៉ាងច្បាស់លើកត្តានានាដូចជា ការមិនមានព្យសនកម្មគ្រប់គ្រាន់ចំពោះតុលាការ និងការមិនមានភាពភ័យខ្លាចនិងការគំរាមកំហែង)។

[106] *រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង Brima និងជនដទៃទៀត*, សំណុំរឿងលេខ SCSL-04-16-T-373, "សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរួមគ្នារបស់មេធាវីការពារក្ដី ប្រឆាំងនឹងសេចក្ដីសម្រេចស្ដីពីរបាយការណ៍របស់មេធាវីឯករាជ អនុលោមតាមវិធាន ៧៧ (C)(iii) និង ៧៧ (D)", អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៥, កថាខណ្ឌ ១០-១១ (ដោយអនុវត្តនិងដកស្រង់ដោយមានការឯកភាព នូវយោបល់ស្រប និងដាច់ដោយឡែក របស់ចៅក្រម Hon។ ចៅក្រម Ayoola *ក្នុងរឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Brima និងជនដទៃទៀត*, សំណុំរឿងលេខ SCSL-04-16-AR77, "សេចក្ដីសម្រេចលើសបណ្ដឹង[illegible] *សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលា[illegible] សុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង*

00847698



អ្វីដែលមិនសមស្រប គឺការ ធ្វើសំអាងហេតុនៃការជ្រៀតជ្រែក ជាពិសេសក្នុងករណីព្រហ្មទណ្ឌ ដោយផ្អែកលើការបង្ហាញ ភ័ស្តុតាងបន្តិចបន្តួច ឬគ្មានទាល់តែសោះ ដើម្បីធ្វើជាយុត្តិកម្មចំពោះការខកខានក្នុងការអនុវត្តការដាក់ទណ្ឌកម្ម ដែលនេះគឺជាការធ្វើការសម្រេចទៅលើ "ពិរុទ្ធភាពដោយការសង្ស័យ"។ ទាក់ទិន នឹងករណីនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយមតិយោបល់របស់សហព្រះរាជអាជ្ញា ដែលបានលើកឡើងថ្មីៗនេះនៅក្នុងរឿងក្តីទាក់ទិននឹងវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដោយផ្អែកតាម ការលើកឡើងរបស់ព្រះរាជអាជ្ញា ការសម្រេចឲ្យបុគ្គលណាមួយមានពិរុទ្ធភាព ផ្អែកតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង តម្រូវឲ្យមានការបំពេញតាមបទដ្ឋាននៃការបង្ហាញភស្តុតាងខ្ពស់ជាង "មូលហេតុដែលអាចឲ្យជឿបាន"[107]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បន្ទុកក្នុងការបង្ហាញភស្តុតាងអំពីបទល្មើសដែលមិនមែនជាបទព្រហ្មទណ្ឌ អាចខុសៗគ្នា

---

មេធាវីការពារក្តី អនុលោមតាមវិធាន ៧៧ (J) ស្តីពីការដាក់វិធានការបណ្តោះអាសន្ន និងដីកា អនុលោមតាមវិធាន ៧៧ (C)(iii)", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៥ ដែលថា "តាមខ្លឹមសារនៃវិធាន ៧៧ (J) ដែលចែងថា: 'សេចក្តីសម្រេចណាមួយ ដែលចេញដោយចៅក្រមតែម្នាក់ ឬ អង្គជំនុំជម្រះសាលាដំបូង តាមវិធានេះ ត្រូវតែបើកផ្លូវឱ្យប្តឹងសាទុក្ខ', ជាការសមស្របក្នុងការពិចារណាអំពីអំណាចរបស់ចៅក្រម ឬ អង្គជំនុំជម្រះសាលាដំបូង តាមវិធាន ៧៧ (C)។ ដោយហេតុថា អំណាចដែលប្រើដោយចៅក្រម ឬអង្គជំនុំជម្រះសាលាដំបូង អាចនិយាយបានថា គឺជាលទ្ធផលនៃសេចក្តីសម្រេចឱ្យប្រើអំណាចនេះ ដូចនេះ អាចនិយាយបានថា ការប្រើអំណាចនេះ គឺបង្ហាញថាជា'សេចក្តីសម្រេច'។ ប៉ុន្តែ មិនអាចនិយាយថា សេចក្តីសម្រេចនេះ ជាសេចក្តីសម្រេចរបស់តុលាការនោះទេ។ គឺជាសេចក្តីសម្រេចផ្នែកប្រតិបត្តិ ហើយមិនមែនជាសេចក្តីសម្រេច ដែលអាស្រ័យលើជម្លោះណាមួយ ឬលើដំណោះស្រាយនៃអង្គហេតុ ឬបញ្ហាដែលជំទាស់គ្នានោះទេ។ ជម្រើសដែលមាននៅក្នុងវិធាន ៧៧ (c) (ii) ឬ (iii) ត្រូវបានកំណត់ដោយច្បាប់ និងដោយភាពងាយស្រួលផ្នែករដ្ឋបាល និងភាពសមរម្យ")។

[107] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សំណើរបស់ នួន ជា អនុលោមតាមវិធាន៣៥ សុំឲ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹង ហោ ណាំហុង" ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E219/2 កថាខណ្ឌ ៨ ("សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា កាលណាចំណាត់ការបន្ទាន់នោះមានជាប់ទាក់ទងនឹងការកំណត់ពិរុទ្ធភាព [...] នោះបទដ្ឋានភ័ស្តុតាងគឺចាំបាច់ត្រូវតែមានលក្ខណៈខ្ពស់ជាង")។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ជំហររបស់អង្គបុរេជំនុំជម្រះកាន់តែទៅឆ្ងាយថែមៈ សូមមើលផងដែរ សាលដីកាលើទីពីរលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឲ្យកោះហៅសាក្សីអង្គបុរេជំនុំជម្រះ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១០ ឯកសារD314/1/12 កថាខណ្ឌ៣៦ ("បទដ្ឋាននៃការបង្ហាញភ័ស្តុតាងឲ្យហួសពីវិមតិសង្ស័យ ត្រូវតែបំពេញ មុននឹងអនុវត្តនូវការដាក់ទណ្ឌកម្មនានាទៅលើបុគ្គលដែលបានរំលោភបំពានលើវិធាន៣៥(១)នៃវិធានផ្ទៃក្នុង")។ ទោះបីជាយ៉ាងណាក៏ដោយ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ មិនបានបង្ហាញច្បាស់ថាតើអង្គជំនុំជម្រះសំដៅលើគ្រប់ប្រភេទទាំងអស់នៃការដាក់ទណ្ឌកម្ម ឬគ្រាន់តែផ្តោតចំពោះការដាក់ទណ្ឌផ្នែកព្រហ្មទណ្ឌប៉ុណ្ណោះ។

00847699



រវាងតុល្យភាពនៃភវនីយភាព និងការបង្ហាញថាហួសពីវិមតិសង្ស័យ ដែលផ្អែកលើវិធានការ ឬទណ្ឌកម្មដែលមាន។

40. នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់នោះ អង្គជំនុំជម្រះសាលាដំបូង មានមូលហេតុអាចជឿជាក់ថា មានការជ្រៀតជ្រែក ប៉ុន្តែ បានបដិសេធមិនធ្វើការស៊ើបសួរបន្ថែម ដោយយល់ឃើញថា ភ័ស្តុតាងមានមិនគ្រប់គ្រាន់ទៅវិញ[108]។ យើងយល់ឃើញថា វិធីសាស្ត្រនេះពុំមានលក្ខណៈសមស្របឡើយ។

41. ជាពិសេស អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការដោះស្រាយបញ្ហាដោយប្រើនីតិវិធីសង្ខេប ដូចការប្រមើលមើលនៅក្នុងវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង ត្រូវប្រើនីតិវិធីសាមញ្ញមួយសម្រាប់ធ្វើការសម្រេច។ វិធាននេះមិនបានអនុញ្ញាតឱ្យសម្រេចដោយសេរី ដោយផ្អែកតាមភស្តុតាងកម្រិតទាបនោះទេ។ តាមទ្រឹស្តី នីតិវិធីសង្ខេប បានរួមបញ្ចូលនូវការកំណត់អង្គហេតុនានា ដោយយោងទៅតាមបទដ្ឋានហួសពីវិមតិសង្ស័យ។ ឧទាហរណ៍ អំពើដែលត្រូវបានដោះស្រាយដោយសមស្រប រួមមានអំពើដែលដឹងជាសាធារណៈ ដោយសារតែចរិតលក្ខណៈនៃអំពើទាំងនោះ អំពើដែលត្រូវបានថតនៅក្នុងវីដេអូរបស់តុលាការ អំពើដែលបានប្រព្រឹត្តឡើងតាមរយៈឯកសារយថាភូត ឬដោយមានការទទួលស្គាល់។

42. វិធាន ៣៥ នៃវិធានផ្ទៃក្នុងមានការរៀបរាប់លម្អិតតិចតួចទាក់ទិននឹងនីតិវិធីអនុលោមតាមអនុវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នីតិវិធីសម្រាប់បង្ហាញពីការទទួលខុសត្រូវ ជាបទល្មើសព្រហ្មទណ្ឌ ឬជាបទល្មើសរដ្ឋបាលក្តី គួរតែអនុវត្តតាមលក្ខខណ្ឌមូលដ្ឋាននៃភាពយុត្តិធម៌។ បទដ្ឋាននៃការបង្ហាញភ័ស្តុតាងសមស្រប គឺជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវនេះ។ បន្ថែមពីលើនេះ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ដោយផ្អែកតាមនីតិវិធីដែលមានចែងនៅក្នុងវិធាន ៧៧(ច) "អង្គជំនុំជម្រះ *តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* អាចចាប់ផ្តើមដំណើរការនីតិវិធី ដោយត្រូវកោះហៅបុគ្គល ណាមួយឱ្យមកឆ្លើយចំពោះការចោទប្រកាន់ប្រឆាំងលើរូបគាត់ នៅពេលដែលអង្គជំនុំជម្រះមានហេតុផលជឿជាក់ថា គាត់បានប្រមាថតុលាការ" [109]។ "អង្គជំនុំជម្រះដែលជារដ្ឋអាជ្ញាផង និងចៅក្រមផង ដែលទាក់ទិននឹងបទចោទនៃការ

---

[108] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ៣០-៣១។

[109] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Aleksovski* , IT-95-14/1-AR77, "សាលដីកាលើបណ្តឹងសាទុក្ខរបស់ *AntoNobilo* ប្រឆាំងនឹងសំអាងហេតុស្តីពីការប្រមាថតុលាការ" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០១ កថាខណ្ឌ៥៥។

ប្រមាថ" ជាសញ្ញានៃភាពគ្រោះថ្នាក់ ហើយនៅក្នុងករណីបែបនោះ នីតិវិធី និងការការពារធម្មតាសម្រាប់ភាគីនានា អាចនឹងត្រូវបានគេមើលរំលង[110]។ ហេតុដូច្នេះ "ជាការសំខាន់ដែលថា នៅពេលអង្គជំនុំជម្រះចាប់ផ្តើមដំណើរការនីតិវិធីចំពោះការប្រមាថ អង្គជំនុំជម្រះត្រូវកំណត់ប្រភេទនៃបទចោទឱ្យបានច្បាស់តាំងពីដំណាក់កាលដំបូង ដោយសង្ឃឹមថា មានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយការធ្វើបែបនេះ វាផ្តល់ឱ្យភាគីនូវឱកាសពិភាក្សាវែកញែកនូវអ្វីដែលតម្រូវឱ្យបង្ហាញ។ មានតែវិធីនេះប៉ុណ្ណោះដែលអ្នកដែលគេចោទថាបានប្រមាថតុលាការ អាចទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌"[111]។

### *iv. ការដាក់ទណ្ឌកម្ម និងការបញ្ជូនតាមវិធាន ៣៥*

43. វិធាន ៣៥ នៃវិធានផ្ទៃក្នុង មិនបានចែងនូវវិធានការក្នុងការទប់ស្កាត់ ឬ ដាក់ទោសចំពោះអំពើដែលបានហាមឃាត់ ក្រៅតែពីដាក់ទណ្ឌកម្មតាមច្បាប់កម្ពុជា ឬបញ្ជូនទៅឱ្យអាជ្ញាធរមានសមត្ថកិច្ច។ សេចក្តីសម្រេចរងការជំទាស់ លើកឡើងនូវ "ការរំលឹកជាសាធារណៈនូវសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការសន្មតថាជាជនឥតទោស និងតម្រូវការឱ្យមន្ត្រីមិនត្រូវធ្វើអត្ថាធិប្បាយដែលមិនស្របជាមួយនឹងគោលការណ៍នៃការសន្មតថាជាជនឥតទោស"[112]។ អង្គជំនុំជម្រះសាលាដំបូង មិនបានបង្ហាញនូវមូលដ្ឋានផ្លូវច្បាប់ណាមួយចំពោះវិធានការនេះ។ លើសពីនេះទៀត ការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងលើបទដ្ឋាននៃការបង្ហាញភស្តុតាងទាក់ទងទៅនឹងវិធីសាស្ត្រផ្នែកនីតិវិធីទាំងនេះ ពុំបានបំភ្លឺបញ្ហានេះទេ[113]។

44. យោងតាមអត្ថន័យនៃវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង ការដាក់ទណ្ឌកម្ម ត្រូវតែកែសម្រួលទៅតាមបរិបទនៃ អ.វ.ត.ក។ ដើម្បីសម្រេចបានចំណុចនេះ ក្រៅពីអំពើព្រហ្មទណ្ឌដែលត្រូវបានគ្រប

---

[110] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Aleksovski* , IT-95-14/1-AR77, "សាលដីកាលើបណ្តឹងសាទុក្ខរបស់ *AntoNobilo* ប្រឆាំងនឹងសំអាងហេតុស្តីពីការប្រមាថតុលាការ" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០១ កថាខណ្ឌ៥៦។

[111] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Aleksovski* , IT-95-14/1-AR77, "សាលដីកាលើបណ្តឹងសាទុក្ខរបស់ *AntoNobilo* ប្រឆាំងនឹងសំអាងហេតុស្តីពីការប្រមាថតុលាការ" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០១ កថាខណ្ឌ ៥៦។

[112] សេចក្តីសម្រេចរងការជំទាស់ កថាខណ្ឌ ៣១។

[113] សេចក្តីសម្រេចរងការជំទាស់ កថាខណ្ឌ ២០។ សូមមើលផង សេចក្តីសម្រេចលើ បណ្តឹងសាទុក្ខរបស់ នួន ជា និង អៀង សារីប្រឆាំងដីការបស់ សហចៅក្រមស៊ើបអង្កេតស្តីពីសំណើសុំកោះសាក្សី, អង្គបុរេជំនុំជម្រះ, ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D314/1/12 កថាខណ្ឌ ៣៦ ដល់ ៣៧។



SUPREME COURT CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE LA COUR SUPRÊME

ដណ្តប់ដោយច្បាប់កម្ពុជា ក្របខណ្ឌរបស់វិធាន ៣៥ នៃវិធានផ្ទៃក្នុង រួមមានអំណាច"ដើម្បីចាត់វិធានការចាំបាច់ ក្នុងការធានាសុចរិតភាពនៃដំណើរការនីតិវិធី ដែលជាចុងក្រោយរក្សានូវការគោរពភាពយុត្តិធម៌"[114]។ អំណាចនេះផ្តល់ជូនចំពោះតុលាការណា ដែលជាភារកិច្ចក្នុងនាមជាស្ថាប័នតុលាការ ហើយជាការ"ចាំបាច់ដើម្បីធានាថា ការអនុវត្តយុត្តាធិការរបស់តុលាការ ពុំត្រូវបានរារាំង ហើយមុខងារមូលដ្ឋានរបស់តុលាការត្រូវបានរក្សាការពារ"[115]។ ហេតុដូចនេះ ជាការសមហេតុផលក្នុងការបកស្រាយវិធាន ៣៥ នៃវិធានផ្ទៃក្នុង ថាអាចអនុវត្តបានចំពោះវិធានការកែតម្រូវទូលំទូលាយ ដែលជាលក្ខណៈរដ្ឋបាល។ ឧទា. វិធានការទាំងនេះរួមមាន ការព្រមាន ការជូនដំណឹងដល់អង្គភាពដាក់វិន័យ ការជូនដំណឹងដល់ថ្នាក់លើ ឬអាជ្ញាធរពាក់ព័ន្ធនឹងទណ្ឌិត ការបោះពុម្ពផ្សាយលទ្ធផលនៃដំណើរការនីតិវិធីនៅក្នុងសាព័ត៌មាន ឬផាកពិន័យរដ្ឋបាលដោយមានកម្រិត។ ការដាក់ទណ្ឌកម្មផ្នែករដ្ឋបាលនេះ មិនត្រូវបានបញ្ជាក់ឱ្យច្បាស់នៅក្នុងវិធានផ្ទៃក្នុងទេ។ នៅក្នុងករណីណាក៏ដោយ ការដាក់ទណ្ឌកម្មផ្នែករដ្ឋបាលនេះ នៅតែត្រូវអនុវត្តតាមគោលការណ៍ជាមូលដ្ឋាននៃភាពចាំបាច់ និងគោលការណ៍សមាមាត្រ។

45. វិធាន ៣៥ នៃវិធានផ្ទៃក្នុង ជាចម្បង បង្កើតឡើងក្នុងគោលបំណង ដាក់វិធានការទណ្ឌកម្មដោយធ្វើឱ្យមានការញញើត។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញ

---

[114] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Beqaj*, IT-03-66-T-R77 "សាលក្រមលើការចោទប្រកាន់អំពីការប្រមាថតុលាការ" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ១៣។

[115] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Beqaj*, IT-03-66-T-R77 "សាលក្រមលើការចោទប្រកាន់អំពីការប្រមាថតុលាការ" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ៩។ *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Aleksovski,* IT-95-14/1-AR77,"សាលដីកាលើបណ្តឹងសាទុក្ខរបស់Anto Nobilo ប្រឆាំងនឹងសំអាងហេតុអំពីការប្រមាថតុលាការ" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០១ កថាខណ្ឌ៣០ (*ដកស្រង់ពី រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić*, IT-94-1-A-R77, "សាលដីកាលើការចោទប្រកាន់អំពីការប្រមាថតុលាការប្រឆាំងនឹងមេធាវីមុន Milan Vujin" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី៣១ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ១៣)។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milosevic*, IT-02-54-A-R77.4, "សាលដីកាលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំទាក់ទិននឹងដំណើរការនីតិវិធីអំពីការប្រមាថតុលាការរបស់Kosta Bulatovic" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៥ កថាខណ្ឌ២១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Rwamakuba,* ICTR-98-44C-T "សេចក្តីសម្រេចលើសំណាងសមស្រប" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ កថាខណ្ឌ៤៧។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Karemeraet. al.,* ICTR-98-44-PT, "សាលក្រមលើការបំបែកសំណុំរឿង André Rwamakuba និងការធ្វើវិសោធនកម្ម ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មាត្រា២០(៤)នៃលក្ខន្តិកៈ វិធាន៨២(ខ)នៃវិធាននីតិវិធីនិងភស្តុតាង" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ២២។

00847702



ថា វិធាន ៣៥ នៃវិធានផ្ទៃក្នុង ក៏បម្រើឱ្យគោលបំណងយ៉ាងសំខាន់ ក្នុងការធានានូវការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងប្រសិទ្ធភាពផងដែរ។ នៅត្រង់ចំណុចនេះ តួនាទីរបស់តុលាការ មិនមែនគ្រាន់តែដាក់ទណ្ឌកម្មចំពោះការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបញ្ឈប់ការ បន្តជ្រៀតជ្រែក និងរារាំងការជ្រៀតជ្រែកដែលអាចមានផងដែរ។ តួនាទីទាំងនេះកាន់តែមាន សារៈសំខាន់នៅពេលការជ្រៀតជ្រែកធ្វើឱ្យប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋាន ដូចជា សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌។ ហេតុដូច្នេះ វាសមហេតុផលក្នុងការបកស្រាយ *ពីទូលាយដល់ចង្អៀត* *(a majori ad minus)* ថា អ.វ.ត.ក អាចប្រើប្រាស់នីតិវិធីក្រោមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដើម្បីអនុវត្តមិនត្រឹមតែវិធានការទណ្ឌកម្ម*តាមន័យចង្អៀត* *(sensu strict)* (ការដាក់ទណ្ឌកម្ម) ប៉ុន្តែថែមទាំងវិធានការកែតម្រូវផ្សេងទៀត ដែលមិនមានលក្ខណៈដាក់ទណ្ឌកម្ម និងមិនតម្រូវឱ្យរកការទទួលខុសត្រូវ (អត្តនោម័ត) ដើម្បីធានាសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌។ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ការសម្រេចនេះ ជាការបង្ហាញនូវគោលជំហរមួយ ដែលបានអនុវត្តយ៉ាងច្បាស់លាស់នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់នោះ[116]។

46. អង្គជំនុំជម្រះតុលាការកំពូល នឹងវាយតម្លៃលើអង្គសេចក្តីនៃរឿងក្តីនេះ ដោយយោងតាមគោលការណ៍នានាដែលបានលើកឡើងខាងលើ។

### គ. អង្គសេចក្តី

#### *i. ពុំមានបញ្ហានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ*

47. អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងអង្គជំនុំជម្រះសាលាដំបូងថា បញ្ហានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ មិនអាចកើតមានឡើយក្នុងរឿងក្តីនេះ ប៉ុន្តែមានបំណងផ្តល់សំអាងមួយផ្សេងទៀត។ យោងតាមមាត្រា ៥២២ នៃក្រមព្រហ្មទណ្ឌកម្ពុជា ដែលជាច្បាប់មានការពាក់ព័ន្ធ

---

[116] សេចក្តីសម្រេចរងការជំទាស់ កថាខណ្ឌ ២៩ ("ប្រសិនបើសេចក្តីថ្លែងការណ៍ទាំងអស់នេះត្រូវបានរាយការណ៍ដោយត្រឹមត្រូវ សេចក្តីថ្លែងការណ៍នេះ មានលក្ខណៈមិនសមស្របទៅនឹងគោលការណ៍ នៃការសន្មតថាគ្មានទោស។ ដោយហេតុថា រឿងក្តីរបស់ នួន ជា បច្ចុប្បន្នកំពុងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយដោយមិនគិតពីចេតនាក្នុងការធ្វើសេចក្តីថ្លែងការណ៍នេះទេ អង្គជំនុំជម្រះពិចារណាឃើញថា សេចក្តីថ្លែងការណ៍នេះ ប្រថុយនឹងការបកស្រាយថាជាការប៉ុនប៉ងជះឥទ្ធិពលលើចៅក្រមដែលទទួលបន្ទុករឿងក្តីនេះ។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះអាចចាត់វិធានការណាមួយដែលមានចែងក្នុងវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង ដោយមិនគិតពីបញ្ហាថាតើ មានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌកើតចេញពីសេចក្តីថ្លែងការណ៍ទាំងនេះ ដែរ ឬយ៉ាងណា ដោយអនុលោមតាមវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង")។

នឹងបញ្ហានេះ ចំពោះការដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ សម្រាប់"បទផ្សព្វផ្សាយនូវការអត្ថាធិប្បាយ ដោយមានគោលដៅដើម្បីជះឥទ្ធិពលទៅលើស្ថាប័នតុលាការ" នេះជាការចាំបាច់ដែលថាចារីប្រព្រឹត្តដោយមានចេតនាជាក់លាក់"ដើម្បីជះឥទ្ធិពលទៅលើ សេចក្តីសម្រេចរបស់តុលាការ"។ តាមយោបល់របស់អង្គជំនុំជម្រះតុលាការកំពូល ខ្លឹមសារនៃសេចក្តីថ្លែងការណ៍ដែលរងការជំទាស់នោះ ព្រមទាំងបរិបទផង ដូចដែលបានរាយការណ៍ មិនបានផ្តល់មូលដ្ឋាន*បញ្ជាក់ជាដំបូង* សម្រាប់ការសន្និតពីចេតនាបែបនេះ និងការញុះញង់ដល់កិច្ចដំណើរការនីតិវិធីឡើង។

48. ដោយហេតុថា សេចក្តីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រី គឺប្រកាសដោយត្រង់ៗជាសាធារណៈនូវពិរុទ្ធភាពរបស់ជនជាប់ចោទ ប៉ុន្តែសេចក្តីថ្លែងការណ៍នេះ សំដៅទៅលើការពិតដែលថា ការជំនុំជម្រះកំពុងប្រព្រឹត្តទៅ[117] ហើយថា បុគ្គលណាមួយ"មិនគប្បីឆ្លើយតប ប៉ុន្តែទុកឱ្យតុលាការកាត់សេចក្តី"[118]។ សេចក្តីថ្លែងការណ៍ដូចគ្នានេះ ត្រូវបានសង្កត់ធ្ងន់ម្តងទៀតដោយនាយករដ្ឋមន្ត្រីដែលទទួលស្គាល់ថា "តុលាការអាច ធ្វើអ្វីតាមតែខ្លួនចង់"[119]។ លើសពីនេះទៀត ការប្រកាសដែលរងការជំទាស់នេះ បានលើកឡើងនៅប្រទេសវៀតណាម នៅក្នុងបទសម្ភាសទាក់ទងទៅនឹងការពិភាក្សាអំពីប្រវត្តិសាស្ត្រស្តីពីតួនាទីរបស់ប្រទេសវៀតណាម ក្នុងអំឡុងពេលការដួលរលំនៃរបបខ្មែរក្រហម។ បញ្ហាថាតើ វៀតណាមឈ្លានពាន ឬក៏ រំដោះកម្ពុជា។ សេចក្តីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រី មានការគាំទ្រចំពោះទស្សនៈនេះ[120] ហើយបានឆ្លើយតបទៅនឹងសំណួរស្តីអំពីបញ្ហាថាតើ លោកមិនបានស្របជាមួយនឹងជំហររបស់ជនជាប់ចោទ[121] ស្តីអំពីតួនាទីរបស់កងកំលាំងវៀតណាមក្នុងការផ្តួលរំលំកម្ពុជាប្រជាធិបតេយ្យ។ តាមការរាយការណ៍ លោកនាយក

---

[117] *សូមមើល*កថាខណ្ឌ ៦, *ដូចខាងលើ* ("នួន ជា ជាបុគ្គលមានតួនាទីសំខាន់ក្នុងរបប ប៉ុល ពត ដែលទទួលការជំនុំជម្រះកាលពីប៉ុន្មានសប្តាហ៍កន្លទៅ")។

[118] *សូមមើល*កថាខណ្ឌ ៦, *ដូចខាងលើ*។

[119] *សូមមើល*កថាខណ្ឌ ៧, *ដូចខាងលើ* ("សុន្ទរកថារបស់ខ្ញុំ [...] មិនបានជះឥទ្ធិពលដល់តុលាការបច្ចុប្បន្ននេះទេ។ តុលាការអាចធ្វើអ្វីៗដែលខ្លួនចង់ ប៉ុន្តែខ្ញុំមានសិទ្ធិថ្កោលទោសមេដឹកនាំខ្មែរក្រហម")។ *សូមមើលផងដែរ* សេចក្តីសម្រេចរងការជំទាស់ កថាខណ្ឌ ៣០ (នៅក្នុងសេចក្តីថ្លែងការណ៍នោះ ពេលអាចជាមួយនឹងការដកស្រង់នេះ មានន័យ "ស្រពិចស្រពិល")។

[120] *សូមមើល*កថាខណ្ឌ ៦, *ដូចខាងលើ* ("កងទ័ពស្ម័គ្រចិត្តវៀតណាម ជួយរំដោះប្រជាជនកម្ពុជាចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត [ហើយ សកម្មភាពរបស់ពួកគេនៅក្នុងកម្ពុជា] កើតចេញមកពីការស្នើសុំរបស់ប្រជាជនកម្ពុជា")។

[121] សេចក្តីសម្រេចរងការជំទាស់, ជើងទំព័រ ៣៥ (សំដៅលើសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ នៅពេលជំនុំជម្រះ ដែល ត្រូវបានចាត់ទុកថា ជាការចោទប្រកាន់ដល់ការឈ្លានពានរបស់វៀតណាមក្នុងឆ្នាំ ១៩៧០)។



E.C.C.C * C.E.T.C
SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME

រដ្ឋមន្ត្រីបានប្រកាសជាសាធារណៈថា សេចក្តីថ្លែងការណ៍របស់ នួន ជា គឺជា"ការកុហកដែលចេញពីមាត់ឃាតករ" ដែល"មិនទទួលស្គាល់នូវកំហុសរបស់ខ្លួនទេ តែបែរជានិយាយកុហកអំពីបញ្ហាកងទ័ពស្ម័គ្រចិត្តវៀតណាមទៅវិញ" ដើម្បី"សម្រាលអំពើបាបរបស់ខ្លួន"។ សេចក្តីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រី ហាក់ដូចជាមានបំណងបង្ខូចសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ ទាក់ទងនឹងការពិភាក្សាអំពីប្រវត្តិសាស្ត្រ។ ចំណុចនេះបានពង្រឹងបន្ថែមទៅលើយោបល់ថា "ការពិតវាផ្ទុយទៅនឹងអ្វីដែល នួន ជា បាននិយាយ"[122]។ ក្នុងបរិបទនេះ គឺក្នុងគោលបំណងដើម្បីបំពេញចិត្តសាធារណជនដែលអានសារពត៌មាននេះ។

49. ហេតុដូច្នេះ ការបង្ហាញឱ្យឃើញពីចេតនារបស់អ្នកនិយាយ គឺថា ១) ធ្វើឡើងនៅក្រៅប្រទេស ២) នៅក្នុងពេលពិភាក្សា ដែលពុំជាប់ពាក់ពន្ធ័ ជាចម្បង ទៅនឹងបញ្ហានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទនោះទេ ហើយ ៣) ការប្រើពាក្យសំដីដូចក្នុងគោលបំណងចំពោះអ្នកអានព័ត៌មានជាក់លាក់ណាមួយ ដូចដែលបានលើកឡើងខាងលើ។ អង្គជំនុំជម្រះតុលាការកំពូលមិនយល់ស្របចំពោះបញ្ហាដែលថា លោក នាយករដ្ឋមន្ត្រី មានចេតនាជាក់លាក់ក្នុងការជ្រៀតជ្រែកកិច្ចការរដ្ឋបាលតុលាការ។ អង្គជំនុំជម្រះពិចារណាបន្ថែមទៀតថា ពុំមានភាពទំនងទាល់តែសោះដែលថា ការបង្ហាញភស្តុតាងនៃចេតនាជាក់លាក់បែបនេះ ដូចជា ការទទួលស្គាល់នូវសេចក្តីថ្លែងការណ៍របស់ខ្លួន នឹងត្រូវយកមកធ្វើជាការផ្តួចផ្តើមកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ។ ដោយធ្វើការពិចារណារួមគ្នាជាមួយនឹងអភ័យឯកសិទ្ធិ បានបង្ហាញថា ពុំមានមូលដ្ឋានការផ្តួចផ្តើមកិច្ចស៊ើបអង្កេតតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ឡើយ។

50. ក្រៅពីតែពីការសំអាងទៅលើការជះឥទ្ធិពលលើចៅក្រមនៃ អ.វ.ត.ក ឬ ជំរុញសាធារណជនឱ្យជឿថា ជនជាប់ចោទមានពិរុទ្ធនោះ សេចក្តីថ្លែងការណ៍ដែលរងការជំទាស់នេះ គឺដោយសារកាលៈទេសៈមិនអំណោយផល និងជាយោបល់ផ្ទាល់ខ្លួន[123] ផ្គួបផ្សំជាមួយនឹងការជឿជាក់ថា "តុលាការ

---

[122] *សូមមើល*កថាខណ្ឌ ៦, *ដូចខាងលើ*។

[123] គប្បីកត់សម្គាល់ផងដែរថា ក្នុងន័យនេះ ទស្សនៈសាធារណៈជនកម្ពុជា ពេលបច្ចុប្បន្ន មិនអាចទទួលរងការប៉ះពាល់ដោយសេចក្តីប្រកាសបែបនេះទេ ទោះបីជាសេចក្តីថ្លែងការណ៍ដូចគ្នានេះ ត្រូវបានលើកឡើងដោយមន្ត្រីសាធារណៈក៏ដោយ រួមទាំងនាយករដ្ឋមន្ត្រី ចាប់តាំងពី ឆ្នាំ ១៩៨០ (*សូមមើល* អ្នកនិពន្ធ Steve Heder, "ការពិនិត្យឡើងវិញនូវការចចារនាំទៅរកការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា", ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១១, គេហទំព័រ http://www.cambodiatribunal.org/blog)។

00847705



អាចធ្វើអ្វីៗតាមដែលខ្លួនចង់ ប៉ុន្តែខ្ញុំមានសិទ្ធិថ្កោលទោសមេដឹកនាំខ្មែរក្រហម"[124]។ នៅពេលសន្មត់ថា សេចក្តីថ្លែងការណ៍លើកក្រោយនេះ សំដៅលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា សេរីភាពក្នុងការបញ្ចេញមតិជាប់ពាក់ពន្ធ័ទៅនឹងរឿងក្តីនេះ និងជាទូទៅ គឺជាការព្រួយបារម្ភមួយដ៏ត្រឹមត្រូវ នៅក្នុងបរិបទកម្ពុជា។ ប៉ុន្តែ ក្នុងន័យនេះ សិទ្ធិនេះត្រូវបានបកស្រាយពុំត្រឹមត្រូវៈ យោងតាមបទដ្ឋានអន្តរជាតិមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា និង[125]ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ[126] សេរីភាពក្នុងការបញ្ចេញមតិ គឺកម្រិតត្រឹមលក្ខខណ្ឌនៃច្បាប់ដែលចាំបាច់សម្រាប់ការពារ"សិទ្ធិរបស់អ្នកដទៃ"។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលរួមមានដូចជាសិទ្ធិសន្មត់ថា ជាជនឥតទោស[127] គឺជាសិទ្ធិមួយដែល បាន ធ្វើយុត្តិកម្មលើការកម្រិតសិទ្ធិក្នុងការបញ្ចេញមតិដោយសេរី មានភាពត្រឹមត្រូវ ជាពិសេសពាក់ពន្ធ័នឹងមន្ត្រីសាធារណៈ។

*ii. អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុស ក្នុងការដោះស្រាយចំពោះការរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងការសន្មតទុកជាមុនថាគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។*

51. នៅក្នុងផ្នែកខាងក្រោមនេះ អង្គជំនុំជម្រះតុលាការកំពូល ជាដំបូង ដោះស្រាយបញ្ហា ថាតើ មានការរំលោភសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែរ ឬយ៉ាងណា។ ទីពីរ អង្គជំនុំជម្រះតុលាការកំពូល ដោះស្រាយលើវិសាលភាពនៃកាតព្វកិច្ច របស់តុលាការព្រហ្មទណ្ឌ ដើម្បីធានាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី។ ចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលពិចារណា ថាតើកាតព្វកិច្ចបែបនេះត្រូវបានបំពេញត្រឹមត្រូវ ដោយអង្គជំនុំជម្រះសាលាដំបូងនៅក្រោមកាលៈទេសៈទាំងនេះ ដែរ ឬយ៉ាងណា។

52. ទោះបីជាការរំលោភសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ទំនងជាពុំត្រូវបានជំទាស់នៅក្នុងរឿងក្តីនេះក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលនៅតែពិចារណាឃើញថា ខ្លួនមានភាព

---

[124] *សូមមើល*ជើងទំព័រ ២១ ដល់ ២២, *ខាងលើ*។

[125] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ (១៩៩៣), អនុម័តដោយសភាធម្មនុញ្ញ និងចុះហត្ថលេខាដោយប្រធាន នៅថ្ងៃទី២១ ខែ កញ្ញា ឆ្នាំ ១៩៩៣ មាត្រា ៣១។

[126] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៤១ ។

[127] ធានាក្រោមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៨។

ចាំបាច់ត្រូវដោះស្រាយបញ្ហានេះ បើទោះជានេះគ្រាន់តែជាបញ្ហាទូទៅក៏ដោយ។ អនុលោមតាមមាត្រា ១២(២) និង មាត្រា ១៣(១) នៃកិច្ចព្រមព្រៀង មាត្រា ៣៣(ថ្មី) និងមាត្រា ៣៥(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលយោងដោយផ្ទាល់លើមាត្រា ១៤ និងមាត្រា ១៥ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិស្តីពីគោលការណ៍សច្ចធារណ៍នៃនិរទោស អាចយកមកអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក។ ដោយពិចារណាឃើញថាពុំមានយុត្តិសាស្ត្រកម្ពុជា ឬការអនុវត្តពាក់ព័ន្ធ ដូច្នេះយើងត្រូវស្វែងរកមើលបទដ្ឋានណែនាំនៅក្នុងកម្រិតអន្តរជាតិ។ ការជ្រៀតជ្រែករបស់រដ្ឋនៅក្នុងរឿងក្តីដែលព្រហ្មទណ្ឌនៅចំពោះមុខ តាមរយៈការថ្លែងសុន្ទរកថាជាសាធារណៈដោយមន្ត្រីរដ្ឋាភិបាលក្នុងពេលខ្លួនបំពេញភារកិច្ច ដើម្បីលូកលាន់នៅក្នុងរឿងក្តីព្រហ្មទណ្ឌដែលកំពុងរង់ចាំការធ្វើចំណាត់ការ គឺជាការរំលោភលើគោលការណ៍សច្ចធារណ៍នៃនិរទោស អនុលោមតាមយុត្តិសាស្ត្រនៃស្ថាប័នសិទ្ធិមនុស្ស និងប្រព័ន្ធតុលាការជាតិ។

53. គណៈកម្មាធិការសិទ្ធិមនុស្ស បានទទួលស្គាល់ថា គោលការណ៍សច្ចធារណ៍នៃនិរទោស ដូចមានចែងនៅក្នុងមាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រួមមាន "អាជ្ញាធរសាធារណៈទាំងអស់មានកាតព្វកិច្ច មិនត្រូវធ្វើបុរេវិនិច្ឆ័យលើលទ្ធផលនៃការជំនុំជម្រះ ពោលគឺ មិនត្រូវធ្វើសេចក្តីប្រកាសជាសាធារណៈបញ្ជាក់នូវពិរុទ្ធភាពរបស់ជនជាប់ចោទឡើយ"[128]។ ក្នុងការសម្រេចថាតើ រដ្ឋបានរំលោភលើគោលការណ៍សច្ចធារណ៍នៃនិរទោស ដែរ ឬយ៉ាងណានោះ គណៈកម្មាធិការសិទ្ធិមនុស្សពិចារណាលើ (i) វិសាលភាពគ្របដណ្តប់របស់សារព័ត៌មានស្តីអំពីសេចក្តីប្រកាសដែលមានលក្ខណៈបុរេវិនិច្ឆ័យ[129] (ii) ជម្រើសនៃការប្រើប្រាស់

---

[128] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ មតិយោបល់ទូទៅលេខ ៣២ - មាត្រា ១៤៖ សិទ្ធិសមភាពចំពោះមុខច្បាប់ និងចំពោះមុខសាលាក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ឯកសារ អ.ស.ប លេខ CCPR/C/GC/32 (ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧) កថាខណ្ឌ ៣០។ កាលពីលើកមុន៖ មតិយោបល់ទូទៅលេខ ១៣, មាត្រា ១៤០: សមភាពចំពោះមុខតុលាការ និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងសិទ្ធិទទួលបានសវនាការជាសាធារណៈដោយតុលាការឯករាជ្យមួយដែលបានបង្កើតដោយច្បាប់ (មាត្រា ១៤)។ ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ១៩៨៤។

[129] រឿងក្តី *Larrañaga ទល់នឹង ប្រទេសហ្វីលីពីន* គណៈកម្មាធិការសិទ្ធិមនុស្ស ទស្សនៈ ឯកសារ អ.ស.ប លេខ CCPR/C/87/D/1421/2005 លិខិតទំនាក់ទំនង 1421/2005 (ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៦) កថាខណ្ឌ ៧.៤ (ក្នុងករណីដែលមានរបាយការណ៍សារព័ត៌មានជាច្រើននៅមុនពេលចេញសាលក្រម ឬ សាលដីកា ដោយអំពាវនាវឲ្យដាក់ទោសប្រហារជីវិតលើចារីនៅពេលចេញសាលក្រម ឬ សាលដីកា)។ រឿងក្តី *Saidova ទល់នឹង ប្រទេសតាហ្ស៊ីគីស្ថាន* គណៈកម្មាធិការសិទ្ធិមនុស្ស ទស្សនៈ ឯកសារ អ.ស.ប លេខ CCPR/C/81/D/964/2001 លិខិតទំនាក់ទំនងលេខ 964/2001 (ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៤)

ពាក្យពេចន៍របស់មន្ត្រីសាធារណៈ[130] (iii) ថាតើសេចក្តីប្រកាសដែលមានលក្ខណៈបុរេវិនិច្ឆ័យទាំងនេះ ត្រូវបានចេញផ្សាយដដែលៗដែរ ឬយ៉ាងណា[131] និង (iv) ឋានៈរបស់បុគ្គលដែល

---

កថាខណ្ឌ ៣.៥ កថាខណ្ឌ ៦.៦ (ប្រព័ន្ធសារព័ត៌មានរបស់រដ្ឋ បានធ្វើយុទ្ធនាការសារព័ត៌មានយ៉ាងទូលំទូលាយ ជាហូរហែរមក ដែលវាមានផលអវិជ្ជមានយ៉ាងជាក់ច្បាស់លើគោលការណ៍សច្ចធារណ៍នៃនិរទោស)។ *សូមមើលជារួមលើរឿងក្តី* Mwamba *ទល់នឹង ប្រទេសស៊ីមបាវ៉េ* គណៈកម្មាធិការសិទ្ធិមនុស្ស ទស្សនៈ ឯកសារ អ.ស.ប លេខ CCPR/C/98/D/1520/2006 លិខិតទំនាក់ទំនងលេខ 1520/2006 (ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១០) កថាខណ្ឌ ២.៤ កថាខណ្ឌ ៦.៥ (ក្នុងករណីដែលប្រព័ន្ធសារព័ត៌មានបានចេញផ្សាយសេចក្តីប្រកាសជាច្រើន ដែលរំលោភលើគោលការណ៍សច្ចធារណ៍នៃនិរទោស)។ រឿងក្តី *Engo ទល់នឹង ប្រទេសកាមេរូន* គណៈកម្មាធិការសិទ្ធិមនុស្ស ទស្សនៈ ឯកសារ អ.ស.ប លេខ CCPR/C/96/D/1397/2005 លិខិតទំនាក់ទំនងលេខ 1397/2005 (ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩) កថាខណ្ឌ ៣.៦ កថាខណ្ឌ ៧.៦ (ក្នុងករណីដែលប្រព័ន្ធសារព័ត៌មានរបស់រដ្ឋបានធ្វើយុទ្ធនាការឃោសនាជាហូរហែរប្រឆាំងនឹងចារី)។ គណៈកម្មាធិការសិទ្ធិមនុស្ស រឿងក្តី *Grindin ទល់នឹង សហព័ន្ធរុស្ស៊ី* គណៈកម្មាធិការសិទ្ធិមនុស្ស ទស្សនៈ ឯកសារ អ.ស.ប លេខ CCPR/C/69/D/770/1997 លិខិតទំនាក់ទំនងលេខ 770/1997 (ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០០) កថាខណ្ឌ ៣.៥ (ក្នុងករណីដែលស្ថានីយវិទ្យុ និងសារព័ត៌មាន បានរាយការណ៍ថា ចារីគឺជាអ្នកចាប់រំលោភផ្លូវភេទ និងឃាតករមួយរូប ដែលគេបានស្គាល់)។

[130] រឿងក្តី *Saidova ទល់នឹង ប្រទេស តាហ្ស៊ីគីស្ថាន* កថាខណ្ឌ ៣.៥ (ក្នុងករណីដែលប្រព័ន្ធសារព័ត៌មានរបស់រដ្ឋ បានកំណត់ស្វាមីរបស់ចារី និងសហចារីថាជា "ឧក្រិដ្ឋជន" និង "ជនក្បាលរឹង"។ រឿងក្តី *Larrañaga ទល់នឹង ប្រទេសហ្វីលីពីន* កថាខណ្ឌ ៣.៤ កថាខណ្ឌ ៧.៤ (ក្នុងករណីដែលរដ្ឋលេខាធិការនៃប្រធានាធិបតី និងមន្ត្រីជាន់ខ្ពស់ផ្សេងទៀត បានលើកឡើងថា ជនជាប់ចោទគួរត្រូវកាត់ទោសប្រហារជីវិត)។

[131] រឿងក្តី *Larrañaga ទល់នឹង ប្រទេសហ្វីលីពីន* កថាខណ្ឌ ៣.៤ កថាខណ្ឌ ៧.៤។ រឿងក្តី *Engo ទល់នឹង ប្រទេសកាមេរូន* កថាខណ្ឌ ៧.៦ (ក្នុងករណីដែលប្រព័ន្ធសារព័ត៌មានរបស់រដ្ឋ បានចាត់ទុកម្តងហើយម្តងទៀតថា ចារីមានពិរុទ្ធ នៅមុនពេលជំនុំជម្រះ ហើយបានចេញផ្សាយអត្ថបទស្តីពីបញ្ហានេះ ដូច្នេះ វាជាការរំលោភលើគោលការណ៍សច្ចធារណ៍នៃនិរទោស)។ រឿងក្តី *Saidova ទល់នឹង ប្រទេសតាហ្ស៊ីគីស្ថាន* កថាខណ្ឌ ៦.៦ (ក្នុករណីដែលប្រព័ន្ធសារព័ត៌មានរបស់រដ្ឋបានធ្វើយុទ្ធនាការជាហូរហែរដែលធ្វើឲ្យប៉ះពាល់ដល់គោលការណ៍សច្ចធារណ៍នៃនិរទោស)។

ធ្វើសេចក្ដីប្រកាសនោះ[132]។ ការរំលោភសិទ្ធិទទួលបានសច្ចធារណ៍នៃនិរទោស ត្រូវទទួលទោស ដោយពុំគិតពីឋានៈតួនាទីរបស់មន្ត្រីរដ្ឋាភិបាលនោះឡើយ[133]។

54. *នៅក្នុងរឿងក្ដី* Gridin *ទល់នឹង សហព័ន្ធរុស្ស៊ី* ប្រធាននគរបាលបានប្រកាសថា លោក"មានភាពជាក់ច្បាស់ណាស់ថា [ជនជាប់ចោទ] គឺជាឃាតករ"[134]។ លើសពីនេះ មន្ត្រីស៊ើបអង្កេតមួយរូប បានប្រកាសអំពីពិរុទ្ធភាពរបស់ជនជាប់ចោទនៅក្នុងកិច្ចប្រជុំជាសាធារណៈ នៅមុនពេលធ្វើសវនាការ។ សេចក្ដីប្រកាសទាំងនេះបានផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ហើយបានបង្កឱ្យមានទស្សនៈយល់ឃើញអវិជ្ជមានយ៉ាងខ្លាំងពីសាធារណជន អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ដែលបានបង្ហាញឱ្យឃើញនៅក្នុងបរិយាកាសតានតឹងមួយនៅក្នុងសាលសវនាការ[135]។ គណៈកម្មាធិការសិទ្ធិមនុស្សយល់ឃើញថា មានការរំលោភគោលការណ៍សច្ចធារណ៍នៃនិរទោស ដោយហេតុថា មន្ត្រីពង្រឹងការអនុវត្តច្បាប់ជាន់ខ្ពស់ទាំងនេះ "ពុំបានអនុវត្តតាមលក្ខខណ្ឌហាមឃាត់ដែលមាត្រា ១៤ កថាខណ្ឌ ២ តម្រូវឱ្យខ្លួនគោរពតាម"[136]។ ម្យ៉ាងវិញទៀត ទោះបីជាជនជាប់ចោទបានធ្វើបណ្ដឹងសាទុក្ខចំពោះការប្រកាសទោសរបស់ខ្លួន ដោយសំអាងថា សិទ្ធិនេះត្រូវបានរំលោភក៏ដោយ ក៏តុលាការកំពូលនៃសហព័ន្ធរុស្ស៊ី ពុំបានសម្រេចលើបញ្ហានេះឱ្យបានជាក់លាក់ឡើយ[137]។

---

[132] រឿងក្ដី *Larrañaga ទល់នឹង ប្រទេសហ្វីលីពីន* កថាខណ្ឌ ៣.៤ កថាខណ្ឌ ៧.៤ (រដ្ឋលេខាធិការនៃប្រធានាធិបតី និងមន្ត្រីជាន់ខ្ពស់មួយរូប)។ រឿងក្ដី *Ashurov ទល់នឹង តាហ្ស៊ីគីស្ថាន* គណៈកម្មាធិការសិទ្ធិមនុស្ស ទស្សនៈ ឯកសារ អ.ស.ប លេខ CCPR/C/89/D/1348/2005 លិខិតទំនាក់ទំនង 1348/2005 (ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០០៧) កថាខណ្ឌ ៣.៤ (ចៅក្រមប្រធានអង្គជំនុំជម្រះ)។ រឿងក្ដី *Grindin ទល់នឹង សហព័ន្ធរុស្ស៊ី* កថាខណ្ឌ ៨.៣ (មន្ត្រីពង្រឹងការអនុវត្តច្បាប់ជាន់ខ្ពស់)។ រឿងក្ដី *Engo ទល់នឹង ប្រទេសកាមេរូន* កថាខណ្ឌ ៧.៦ (ប្រព័ន្ធសារព័ត៌មានរបស់រដ្ឋ)។ *រឿងក្ដី Saidova ទល់នឹង ប្រទេសតាហ្ស៊ីគីស្ថាន* កថាខណ្ឌ ៣.៥ និងកថាខណ្ឌ ៦.៦ (ប្រព័ន្ធសារព័ត៌មានរបស់រដ្ឋ)។

[133] រឿងក្ដី *Larrañaga ទល់នឹង ប្រទេសហ្វីលីពីន* គណៈកម្មាធិការសិទ្ធិមនុស្សនៃ អ.ស.ប (លិខិតទំនាក់ទំនង 1421/2005) ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ៣.៦។ រឿងក្ដី *សហរដ្ឋអាមេរិក ទល់នឹង Koubriti* 305F Supp.2nd ត្រង់ 742។

[134] *រឿងក្ដី Grindin ទល់នឹង សហព័ន្ធរុស្ស៊ី* គណៈកម្មាធិការសិទ្ធិមនុស្ស ទស្សនៈ ឯកសារ អ.ស.ប. លេខ CCPR/C/69/D/770/1997 លិខិតទំនាក់ទំនងលេខ 770/1997 (ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០០) កថាខណ្ឌ ៣.៥។

[135] រឿងក្ដី *Grindin ទល់នឹង សហព័ន្ធរុស្ស៊ី* កថាខណ្ឌ ៣.៥។

[136] រឿងក្ដី *Grindin ទល់នឹង សហព័ន្ធរុស្ស៊ី* កថាខណ្ឌ ៨.៣។

[137] រឿងក្ដី *Grindin ទល់នឹង សហព័ន្ធរុស្ស៊ី* កថាខណ្ឌ ៣.៥ និងកថាខណ្ឌ ៨.៣។

55. ដូចគ្នានេះដែរ គណៈកម្មាធិការសិទ្ធិមនុស្សបានរកឃើញការរំលោភគោលការណ៍សច្ចធារណ៍នៃនិរទោស ដែលមានរៀបរាប់នៅក្នុង*រឿងក្តី Larrañaga ទល់នឹង ប្រទេសហ្វីលីពីន* ដែលជនជាប់ចោទ បានចោទប្រកាន់ថា ក្រុមដែលមានអំណាចក្នុងសង្គម ដែលក្នុងនោះមានក្រុមមួយបានអំពាវនាវឲ្យសម្លាប់ជនជាប់ចោទ បាននាំឲ្យមានឥទ្ធិពលលើសាលាដំបូង និងតុលាការកំពូល[138]។ មានរបាយការណ៍អវិជ្ជមានរបស់សារព័ត៌មានផងដែរ ដែលត្រូវបានផ្សព្វផ្សាយនៅមុនពេលចេញសាលក្រម ឬ សាលដីកា ដែលជះឥទ្ធិពលដល់ចៅក្រម[139]។ ទាំងសាលាដំបូង និងតុលាការកំពូល ពុំបានសម្រេចលើបញ្ហានេះឲ្យបានសមស្របនោះទេ[140]។

56. នៅក្នុងរឿងក្តីដែលពុំពាក់ព័ន្ធនឹងសេចក្តីប្រកាសរបស់មន្ត្រីសាធារណៈវិញ យុទ្ធនាការផ្សព្វផ្សាយការប្រឆាំងពីសារព័ត៌មាននៅដំណាក់កាលមុនអង្គសេចក្តី ដែលចង្អុលដាក់លើការជួយគាំទ្រ និងការគ្រប់គ្រងរបស់រដ្ឋ ក៏អាចនាំឲ្យរដ្ឋជាអ្នកទទួលខុសត្រូវ លើការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផងដែរ ប្រសិនបើរដ្ឋពុំបានចាត់វិធានការកែតម្រូវស្ថានភាពនេះឡើងវិញទេនោះ។ នៅក្នុងរឿងក្តី *Marinich ទល់នឹង ប្រទេសបេឡារុស*[141] រដ្ឋដែលធ្វើចំណាត់ការលើរឿងក្តីនេះ ត្រូវបានគេរកឃើញថា បានរំលោភលើសិទ្ធិទទួលបានសច្ចធារណ៍នៃនិរទោសរបស់ជនជាប់ចោទ នៅពេលដែលប្រព័ន្ធទូរទស្សន៍ដែលគ្រប់គ្រងដោយរដ្ឋនេះ បានចាក់ផ្សាយវគ្គសួរចម្លើយជនជាប់ចោទរួមជាមួយនឹងមតិយោបល់បង្ហាញថា ជនជាប់ចោទមានពិរុទ្ធ[142]។ នៅក្នុងរឿងក្តី *Engo ទល់នឹង ប្រទេសកាមេរូន*[143] ប្រព័ន្ធសារព័ត៌មានរបស់រដ្ឋកាមេរូនបានធ្វើយុទ្ធនាការឃោសនាមួយប្រឆាំងនឹងជនជាប់ចោទនៅក្នុងអត្ថបទសារព័ត៌មាន ដោយបង្ហាញម្តងហើយម្តងទៀតថា ជនជាប់ចោទមានពិរុទ្ធ មុនពេលការជំនុំជម្រះក្តីលើជនជាប់ចោទរូបនេះ។ ទោះបីជាម្ចាស់បណ្តឹងបានសរសេរលិខិតច្រើនច្បាប់ទៅរដ្ឋអាជ្ញា ក្រសួងយុត្តិធម៌ និងនាយកគ្រប់គ្រងស្ថានីយវិទ្យុ និងទូរទស្សន៍នៃ

---

[138] រឿងក្តី *Larrañaga ទល់នឹង ប្រទេសហ្វីលីពីន* កថាខណ្ឌ ៣.៤។

[139] រឿងក្តី *Larrañaga ទល់នឹង ប្រទេសហ្វីលីពីន* កថាខណ្ឌ ៣.៤។

[140] រឿងក្តី *Larrañaga ទល់នឹង ប្រទេសហ្វីលីពីន* កថាខណ្ឌ ៧.៤។

[141] រឿងក្តី *Marinich ទល់នឹង ប្រទេសបេឡារុស* គណៈកម្មាធិការសិទ្ធិមនុស្ស ទស្សនៈ ឯកសារ អ.ស.ប លេខ CCPR/C/99/D/1502/2006 លិខិតទំនាក់ទំនង 1502/2006 (ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១០)។

[142] រឿងក្តី *Marinich ទល់នឹង ប្រទេសបេឡារុស* កថាខណ្ឌ ២.៤ កថាខណ្ឌ ១០.៦។

[143] *រឿងក្តី Engo ទល់នឹង ប្រទេសកាមេរូន* តុលាការស្តីសិទ្ធិមនុស្ស, ទស្សនៈ, U.N. Doc. CCPR/C/96/D/1397/2005 គណៈកម្មាធិការសិទ្ធិមនុស្សនៃ អ.ស.ប (លិខិតទំនាក់ទំនងលេខ 1397/2005) (ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៩)។



SUPREME COURT CHAMBER E.C.C.C.

ប្រទេសកាមេរូន ស្នើសុំឱ្យបញ្ឈប់ការផ្សព្វផ្សាយព័ត៌មានបែបនេះក៏ដោយ ក៏លិខិតទាំងនេះពុំទទួលបានការឆ្លើយតបមកវិញនោះទេ[144]។ រឿងក្តីផ្សេងទៀតស្រដៀងគ្នានេះបានបង្ហាញថា នៅពេលមាន "ការផ្សព្វផ្សាយក្តែងៗយ៉ាងទូលំទូលាយ និងអវិជ្ជមាន" ដោយប្រព័ន្ធសារព័ត៌មានជាតិក្រោមការដឹកនាំរបស់រដ្ឋប្រកាសថាជនជាប់ចោទជា "ឧក្រិដ្ឋជន" និង "ជនក្បាលរឹង" នោះសិទ្ធិទទួលបានសច្ចធារណ៍នៃនិរទោសត្រូវបានរំលោភបំពាន[145]។

57. អនុលោមទៅតាមអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស យោងតាមមាត្រា ១០ ដែលធានាសេរីភាពបញ្ចេញមតិ មន្ត្រីសាធារណៈពុំត្រូវបានរារាំងពីការផ្សព្វផ្សាយព័ត៌មានដល់សាធារណជន អំពីកិច្ចដំណើរការនីតិវិធី ឬ ពីការជំរុញឱ្យមានការជជែកវែកញែកជាសាធារណៈលើបញ្ហាស្តីពីផលប្រយោជន៍រួមឡើយ ប្រសិនបើការផ្សព្វផ្សាយ ឬការជំរុញបែបនេះធ្វើឡើងយ៉ាងប្រុងប្រយ័ត្ន ដោយមានការគោរពយ៉ាងពេញលេញលើគោលការណ៍សច្ចធារណ៍នៃនិរទោស[146]។ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សក៏បានសម្រេចថា មន្ត្រីសាធារណៈ[147] មិនត្រូវធ្វើសេចក្តីប្រកាសអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ នៅមុនពេលជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធតាមច្បាប់ឡើយ។ ដើម្បីថ្លឹងថ្លែងផលប្រយោជន៍ផ្ទុយគ្នាទាំងពីរនេះ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស បានបញ្ជាក់ធាតុផ្សំជាច្រើន

---

[144] *រឿងក្តី Engo ទល់នឹង ប្រទេសកាមេរូន* កថាខណ្ឌ ៣.៦ និងកថាខណ្ឌ ៧.៦។

[145] *រឿងក្តី Saidova ទល់នឹង ប្រទេសតាហ្ស៊ីគីស្ថាន* កថាខណ្ឌ ៦.៦។ *សូមមើលផងដែរ រឿងក្តី Kulov ទល់នឹង ប្រទេសតាហ្ស៊ីគីស្ថាន* តុលាការស្តីសិទ្ធិមនុស្ស, ទស្សនៈ, U.N. Doc. CCPR/C/96/D/1397/2005 គណៈកម្មាធិការសិទ្ធិមនុស្សនៃ អ.ស.ប (លិខិតទំនាក់ទំនងលេខ 1369/2005) ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៨.៧។

[146] *រឿងក្តី Konstas ទល់នឹង ប្រទេសក្រិក* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ពាក្យសុំលេខ 53466/07 ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១១ កថាខណ្ឌ ៣៤។ រឿងក្តី *Allenet de Ribemont ទល់នឹង ប្រទេសបារាំង* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ពាក្យសុំលេខ 15175/89 ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ កថាខណ្ឌ ៣៨។ រឿងក្តី *Fatullayev ទល់នឹង ប្រទេស អាស៊ែបៃហ្សង់* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ពាក្យសុំលេខ 40984/07 ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១០ កថាខណ្ឌ ១៥៩។

[147] អង្គជំនុំជម្រះនេះកត់សម្គាល់ឃើញថា យោងតាមយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សទាំងនេះ គោលការណ៍សច្ចធារណ៍និរទោស និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជារួម អាចរំលោភបំពានតាមរយៈអត្ថបទ ឬ សេចក្តីប្រកាសរបស់បុគ្គលឯកជន ដែលបានផ្សព្វផ្សាយនៅក្នុងសារព័ត៌មាន បង្កើតឡើងក្នុងគោលបំណងជះឥទ្ធិពលលើលទ្ធផលនៃកិច្ចដំណើរការនីតិវិធី ឬ ដើម្បីគ្រប់គ្រងលើជំហររបស់ចៅក្រមដែលកំពុងចាត់ការលើរឿងក្តី។ *សូមមើល* រឿងក្តី *Worm ទល់នឹង ប្រទេសអូទ្រីស* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ពាក្យសុំលេខ 83/1996/702/894 ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៥០ កថាខណ្ឌ ៥៤។

ដែលមានការវិវឌ្ឍថ្មីៗ ដើម្បីកំណត់ថាតើសេចក្តីប្រកាសមួយដែលធ្វើឡើងដោយមន្ត្រីសាធារណៈ បានជះឥទ្ធិពលលើចៅក្រម ដែលជំរុញឲ្យតុលាការមានភាពលម្អៀង និងបង្កបញ្ហាចោទលើគោលការណ៍សច្ចធារណ៍នៃនិរទោសដែរ ឬយ៉ាងណា។ កត្តាទាំងនេះរួមមានដូចតទៅ៖ (i) ជម្រើសនៃពាក្យពេចន៍នៅក្នុងសេចក្តីប្រកាសដែលប្រើប្រាស់ដោយមន្ត្រីសាធារណៈ ដូចជា តើសេចក្តីប្រកាសទាំងនេះរួមមានការចោទប្រកាន់លើភាពសង្ស័យ ឬ ការប្រកាសអំពីពិរុទ្ធភាពដែរ ឬយ៉ាងណា[148] (ii) បរិបទដែលសេចក្តីប្រកាសទាំងនេះបានធ្វើឡើង[149] (iii) ឋានៈរបស់បុគ្គលធ្វើសេចក្តីប្រកាស[150] (iv) ផលប្រយោជន៍សាធារណៈនៅក្នុងរឿងក្តីព្រហ្មទណ្ឌ[151] (v) ពេលវេលានៃការធ្វើសេចក្តីប្រកាសបើធៀបនឹងកិច្ចដំណើរការនីតិវិធី[152] និង (vi) ថាតើការជំនុំជម្រះនេះធ្វើឡើងនៅចំពោះមុខក្រុមប្រឹក្សាវិនិច្ឆ័យ ឬ ចៅក្រមវិជ្ជាជីវៈ[153]។

[148] រឿងក្តី *Mokhov ទល់នឹង ប្រទេសរុស្ស៊ី* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ពាក្យសុំលេខ 28145/04 ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១០ កថាខណ្ឌ ២៩។ រឿងក្តី *Shuvalov ទល់នឹង ប្រទេសអេស្តូនី* តុលាការសិទ្ធិមនុស្សអឺរ៉ុប សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ពាក្យសុំលេខ 39820/08 និងពាក្យសុំលេខ 14942/09 ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ៧៥។ រឿងក្តី *Konstas ទល់នឹង ប្រទេសក្រិក* កថាខណ្ឌ ៣៣។ រឿងក្តី *Daktaras ទល់នឹង ប្រទេសលីទុយអានី* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ពាក្យសុំលេខ 42095/98 ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០០ កថាខណ្ឌ ៤១។ រឿងក្តី *Fatullayev ទល់នឹង ប្រទេសអាហ្ស៊ែបៃហ្សង់* កថាខណ្ឌ ១៦០។

[149] រឿងក្តី *Butkevičius ទល់នឹង ប្រទេសលីទុយអានី* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ពាក្យសុំលេខ 48297/99 ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០២ កថាខណ្ឌ ៥០ (ក្នុងករណីដែលសេចក្តីប្រកាសត្រូវបានចេញផ្សាយនៅក្នុងបរិបទឯករាជ្យពីកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ ទោះបីជាយ៉ាងនេះក្តី កត្តានេះត្រូវថ្លឹងថ្លែងជាមួយនឹងជម្រើសនៃការប្រើប្រាស់ពាក្យពេចន៍ជាក់លាក់)។ រឿងក្តី *Daktaras ទល់នឹង ប្រទេសលីទុយអានី* កថាខណ្ឌ ៤៣។

[150] រឿងក្តី *Konstas ទល់នឹង ប្រទេសក្រិក* កថាខណ្ឌ ៤៣ (ក្នុងករណីដែលតុលាការសិទ្ធិមនុស្សអឺរ៉ុបបានពិចារណាលើមុខនាទីជាក់លាក់នៃរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ថាមានមុខនាទីនយោបាយ ដែលអនុវត្តការគ្រប់គ្រងលើអង្គការត្រឹមត្រូវមួយ នឹងមុខងាររបស់តុលាការ។ រឿងក្តី *Ergashev ទល់នឹង ប្រទេសរុស្ស៊ី* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ពាក្យសុំលេខ 12106/09 ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១១ កថាខណ្ឌ ១៧២។

[151] *សូមមើល* រឿងក្តី *Burzo ទល់នឹង រូម៉ានី* តុលាការសិទ្ធិមនុស្សអឺរ៉ុប សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ពាក្យសុំលេខ 75109/01 និងពាក្យសុំលេខ 12639/02 ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៩ កថាខណ្ឌ ១៦០។ រឿងក្តី *Tourancheau និង July ទល់នឹង ប្រទេសបារាំង* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ពាក្យសុំលេខ 53886/00 ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥ កថាខណ្ឌ ៧៤។

[152] រឿងក្តី *Butkevičius ទល់នឹង ប្រទេសលីទុយអានី* កថាខណ្ឌ ៥១ (អង្គជំនុំជម្រះយល់ឃើញថា វាមាន "សារៈសំខាន់ណាស់" ដែលនៅក្នុងដំណាក់កាលនីតិវិធីដំបូង សេចក្តីប្រកាសណាដែលអាចត្រូវបានបកស្រាយថាជាការបញ្ជាក់លើពិរុទ្ធភាពរបស់

*សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង*

00847712



58. តុលាការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស ("IACtHR") បានពឹងផ្អែកទៅលើគោលការណ៍ដែលបានកំណត់រួចរបស់តុលាការ ECtHR នៅពេលដែលខ្លួនធ្វើការសម្រេចថា រដ្ឋជាភាគីបានរំលោភទៅលើគោលការណ៍សច្ចធារណ៍នៃនិរទោស ដូចមានចែងក្នុងមាត្រា ៨(២) នៃអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស ("ACHR") ដោយធ្វើការបង្ហាញមុខជនជាប់ចោទ នៅចំពោះមុខប្រព័ន្ធផ្សព្វផ្សាយ ថាជាចារី មុនពេលដែលជនជាប់ចោទត្រូវបានប្រកាសថាមានទោស ចំពោះបទល្មើសដែលត្រូវបានចោទប្រកាន់[154]។ នៅក្នុងរឿងក្តីដដែលនេះ តុលាការ IACtHR បានបញ្ជាក់ច្បាស់ថា សិទ្ធិដែលមានជាធរមាន "តម្រូវថា រដ្ឋមិនត្រូវប្រកាសពិរុទ្ធភាពចំពោះបុគ្គលណាម្នាក់ក្រៅផ្លូវការ ឬក៏បញ្ចេញនូវទស្សនៈជាសាធារណៈដែលនាំឱ្យមានការបង្កើតនូវការយល់ឃើញជាសាធារណៈ" មុនពេលដែលមានការសម្រេចជាស្ថាពរចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយផ្អែកទៅលើច្បាប់នោះឡើយ[155]។ ការរំលោភប្រហាក់ប្រហែលគ្នានេះ ក៏ត្រូវបានរកឃើញផងដែរ ក្នុងករណីដែលមន្ត្រីរដ្ឋបាន "បណ្តើរ" ជនជាប់ចោទនៅចំពោះមុខប្រព័ន្ធផ្សព្វផ្សាយ ដោយឱ្យស្លៀកពាក់ "សម្លៀកបំពាក់

---

ជនសង្ស័យ មិនត្រូវលើកឡើងឡើយ)។ រឿងក្តី *Allenet de Ribemont ទល់នឹង ប្រទេសបារាំង* កថាខណ្ឌ ៣៧ (ដំណាក់កាលស៊ើបអង្កេតបឋម ត្រូវបានចាត់ទុកថាងាយនឹងធ្វើឱ្យមានការរំលោភលើគោលការណ៍សច្ចធារណ៍និរទោសណាស់ ក្នុងករណីដែលសេចក្តីប្រកាសដែលត្រូវបានជំទាស់នោះ បានធ្វើឡើងក្រោយពេលចាប់ខ្លួនម្ចាស់បណ្តឹងនេះ និងនៅមុនពេលចាប់ផ្តើមការស៊ើបអង្កេត។ សូមមើលផងដែរ រឿងក្តី *Konstas ទល់នឹង ប្រទេសក្រិក* កថាខណ្ឌ ៤៤ (ក្នុងករណីដែលការរំលោភសិទ្ធិមនុស្សត្រូវបានរកឃើញ ទោះបីជាមានគម្លាតពេលវេលាយ៉ាងច្រើន រវាងពេលវេលាធ្វើសេចក្តីប្រកាសដែលត្រូវបានជំទាស់ និងពេលវេលាចេញសេចក្តីសម្រេចរបស់តុលាការក៏ដោយ)។ ដូច្នេះ ពេលវេលានៅពេលធ្វើសេចក្តីប្រកាស ទំនងជាត្រូវបានគេមើលឃើញថាជាកត្តាសំខាន់មួយ។ ប៉ុន្តែ គោលការណ៍សច្ចធារណ៍នៃនិរទោសត្រូវតែគោរពនៅក្នុងពេលនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌទាំងមូល។

[153] *សូមមើល* រឿងក្តី *Burzo ទល់នឹង ប្រទេសរូម៉ានី* កថាខណ្ឌ ១៦៦។ រឿងក្តី *Craxi ទល់នឹង ប្រទេសអ៊ីតាលី* តុលាការសិទ្ធិមនុស្សអឺរ៉ុប សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ពាក្យសុំលេខ 34896/97 ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០២ កថាខណ្ឌ ១០៤ (បានលើកឡើងថា នៅក្នុងការជំនុំជម្រះដែលមានក្រុមប្រឹក្សាជំនុំជម្រះ ចៅក្រមវិជ្ជាជីវៈមានបទពិសោធន៍ និងការបណ្តុះបណ្តាលដើម្បីកុំឱ្យទទួលឥទ្ធិពលពីការលើកឡើងពីខាងក្រៅ)។ រឿងក្តី *Ensslin Baader និង Raspe ទល់នឹង សាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់* សេចក្តីសម្រេចរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ពាក្យសុំលេខ 7572/76 ពាក្យសុំលេខ 7586/76 និងពាក្យសុំលេខ 7587/76 ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ១៩៧៨ កថាខណ្ឌ ១៥ (បានលើកឡើងថា ក្រុមប្រឹក្សាវិនិច្ឆ័យ តាមធម្មជាតិទំនងជាងាយរងនូវឥទ្ធិពលណាស់)។

[154] សំណុំរឿង *Lori Berenson-Mejia តទល់នឹង ប្រទេសប៉េរូ*, IACtHR, សាលក្រម (អង្គសេចក្តី ការទូរទាត់សំណង និងចំណាយនានា) ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤ កថាខណ្ឌ ១៥៨ ដល់ ១៦១។

[155] សំណុំរឿង *Lori Berenson-Mejia តទល់នឹង ប្រទេសប៉េរូ* កថាខណ្ឌ ១៦០។

បែបប្រមាថមើលងាយ” ថាជាចារីនៃអំពើក្បត់ជាតិ[156]។ ប្រហាក់ប្រហែលគ្នានេះ គណៈកម្មាការអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ បានរកឃើញនូវការរំលោភទៅលើគោលការណ៍សច្ចធារណ៍នៃនិរទោស ដែលជាប់ពាក់ព័ន្ធទៅនឹងការប្រកាសពិរុទ្ធភាពជាសាធារណៈ ដោយ “មន្ត្រីរដ្ឋាភិបាលថ្នាក់ខ្ពស់”[157] ព្រមទាំង “ការផ្សព្វផ្សាយជាសាធារណៈ មុនការជំនុំជម្រះយ៉ាងគគ្រឹកគគ្រេង”[158] ដែលរៀបចំឡើងដោយរដ្ឋ ក្នុងពេលដែលរឿងក្តីកំពុងដំណើរការ។

59. អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញា[159] បានទាញការចាប់អារម្មណ៍ទៅលើយុត្តិសាស្ត្ររបស់តុលាការកំពូលសហរដ្ឋអាមេរិក ដែលមានឈ្មោះថា *Tenney ទល់នឹង Brandhove* ដើម្បីបង្ហាញពីសារៈសំខាន់នៃសិទ្ធិបញ្ចេញមតិដោយសេរីជំរិញបញ្ហានយោបាយ[160]។ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា នៅក្នុងយុត្តិសាស្ត្ររបស់សហរដ្ឋអាមេរិក លទ្ធិច្បាប់ស្តីពីការបញ្ចេញមតិរបស់រដ្ឋាភិបាលមានស្របទៅនឹងគោលការណ៍ដែលថាស្ថាប័នរដ្ឋាភិបាលមានសិទ្ធិនិយាយនូវអ្វីដែលខ្លួនចង់និយាយ[161]។ រដ្ឋាភិបាលក៏មានសិទ្ធិ “និយាយ

---

[156] សំណុំរឿង *Cantoral Benavides តទល់នឹង ប្រទេស ប៉េរូ* សេរី គ លេខ ៦៩ សាលក្រមលើអង្គសេចក្តី (IACtHR) ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០០ ត្រង់កថាខណ្ឌ ១១៩ ដល់ ១២១។

[157] *ការិយាល័យច្បាប់* Ghazi Suleiman *តទល់នឹងប្រទេស ស៊ូដង់*, គណៈកម្មាធិការអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន (ឯកសារទាក់ទង លេខ ២២២/៩៨ និង ២២២៩/៩៩) ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ៥៤ ដល់ ៥៦ និង ៦៧។

[158] *រឿងក្តី* Media Rights Agenda *តទល់នឹងប្រទេស នីហ្សេរីយ៉ា*, គណៈកម្មាការអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាពលរដ្ឋ (ឯកសារទាក់ទង លេខ ២២៤/៩៨) ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០០០ កថាខណ្ឌ ៤៧ និង ៤៨។

[159] សារណាតបរបស់សហព្រះរាជអាជ្ញា ទៅនឹងពាក្យសុំរបស់នួន ជា ដែលស្នើឲ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹងនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១២ E176/1 កថាខណ្ឌ ១៥(គ)។

[160] *រឿងក្តី* Tenney *ទល់នឹង* Brandhove, តុលាការកំពូលសហរដ្ឋអាមេរិក (១៩៥១), 341 US 367, 371 (ពាក់ព័ន្ធទៅនឹងការជំទាស់ដោយមិនជោគជ័យទៅលើភាពស្របច្បាប់នៃដំណើរការស៊ើបអង្កេត និងស្វែងរកភស្តុតាង ដែលធ្វើឡើងដោយស្ថាប័ននីតិបញ្ញត្តិ ដែលមិនជាប់ទាក់ទងទៅនឹងសិទ្ធិមួយចំនួនដែលធានាដោយធម្មនុញ្ញរបស់សហព័ន្ធ)។

[161] *រឿងក្តី* Rust *ទល់នឹង* Sullivan, តុលាការកំពូលនៃសហរដ្ឋអាមេរិក(១៩៩១), 500 U.S. 173 (1991), ត្រូវបានបកស្រាយនៅក្នុង Rosenberger *ទល់នឹង* Rector and Visitors of Univ. of Va., តុលាការកំពូលនៃសហរដ្ឋអាមេរិក(១៩៩៥), 515 U.S. 819, 833 (1995); *Garcetti តទល់នឹង* Ceballos, តុលាការកំពូលនៃសហរដ្ឋអាមេរិក(១៩៩៩), 547 U.S. 410, 421-22; *សហរដ្ឋអាមេរិក ទល់នឹង* American Library Ass'n, តុលាការកំពូលនៃសហរដ្ឋអាមេរិក(២០០៣), 539 U.S. 194 (2003); *Nurre ទល់នឹង* Whitehead, តុលាការកំពូលនៃសហរដ្ឋអាមេរិក(២០១០), 130 S.Ct. 1937។

តាងនាមឲ្យខ្លួនឯង"[162] ព្រមទាំងមានសិទ្ធិជ្រើសរើសនូវទស្សនៈដែលខ្លួនចង់បញ្ចេញផងដែរ[163]។ ទោះបីជាយ៉ាងណាក៏ដោយ រឿងក្តីនានាបានបង្ហាញត្រង់ចំណុចដោយផ្ទាល់ថា គោលការណ៍បញ្ចេញមតិដោយសេរី មិនបានរំលោភទៅលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងមិនលម្អៀងនោះឡើយ[164]។ ពិតណាស់ គោលការណ៍សច្ចធារណ៍នៃនិរទោស បានហាមឃាត់មន្ត្រី និងស្ថាប័នរដ្ឋាភិបាល មិនឲ្យនិយាយអ្វីដែលប្រឆាំងនឹងជនសង្ស័យ នៅក្នុងការជំនុំជម្រះព្រហ្មទណ្ឌដែលកំពុងតែចាត់ការនោះទេ[165]។ *នៅក្នុងរឿងក្តី Sheppard ទល់នឹង Maxwell*, ដែលជារឿងក្តីមួយពាក់ព័ន្ធយ៉ាងខ្លាំងជាមួយការផ្សព្វផ្សាយជាសាធារណៈតាមប្រព័ន្ធព័ត៌មាន ព្រមទាំងតាមសេចក្តីថ្លែងការណ៍ដោយមានបុរេវិនិច្ឆ័យរបស់មន្ត្រីរដ្ឋាភិបាល ពាក់ព័ន្ធទៅនឹងពិរុទ្ធភាពរបស់ជនជាប់ចោទនោះ តុលាការកំពូលរបស់សហរដ្ឋអាមេរិកបានសម្រេចថា ទោះបីជា "សេរីភាពក្នុងការពិភាក្សាគួរត្រូវបានផ្តល់ឲ្យក្នុងទ្រង់ទ្រាយធំបំផុត ដែលស្របជាមួយនឹងរដ្ឋបាលតុលាការដែលយុត្តិធម៌ និងត្រឹមត្រូវក៏ដោយ ក៏សេរីភាពនេះមិនគួរត្រូវបានអនុញ្ញាតរហូតដល់អាចកែប្រែការជំនុំ

---

[162] *រឿងក្តី Pleasant Grove City ទល់នឹង Summum*, តុលាការកំពូលនៃសហរដ្ឋអាមេរិក(២០០៩), 555 U.S. 460, 468។

[163] *រឿងក្តី Summum*, 555 U.S. 460, 468។

[164] *សូមមើលឧទាហរណ៍ សហរដ្ឋអាមេរិក ទល់នឹង Koubriti*, Federal District Court, Eastern District of Michigan (2003), 305 F. Supp.2d 723, 760 (ទទួលស្គាល់ថាទោះបីជាតុលាការមិនមានតួនាទី ក្នុងការជម្រាបទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ពីការរៀបចំការិយាល័យរបស់ខ្លួន ដើម្បីធ្វើឲ្យមានតុល្យភាពនៅក្នុងតួនាទីទ្វេររបស់ខ្លួន ជារដ្ឋអាជ្ញាផង និងជាប្រធានផ្នែកនីតិប្រតិបត្តិដែលមានតួនាទីក្នុងការជម្រាបដល់សាធារណជនផងនោះក៏ដោយ ក៏ពិតជាគ្មានអ្វីដែលត្រូវឆ្ងល់នោះឡើយដែលថា តុលាការមានតួនាទីក្នុងការ "ធានាថាជនជាប់ចោទដែលត្រូវបង្ហាញខ្លួននៅចំពោះមុខតុលាការ មានសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ស្របតាមរដ្ឋធម្មនុញ្ញ ហើយតុលាការត្រូវចេញដីកាដែលការពារសិទ្ធិទាំងអស់នេះ និងត្រូវពិនិត្យមើលថាដីការបស់ខ្លួនត្រូវបានគោរពតាម")។

[165] *រឿងក្តី Koubriti*, 305 F. Supp.2d ត្រង់ 758 (យល់ឃើញថា ខ្លួន "ត្រូវតែបញ្ជាក់ដដែលៗ" ថា មតិយោបល់របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៅក្នុងពេលដំណើរការការជំនុំជម្រះ ដែលថា សក្ខីកម្មរបស់សាក្សីសំខាន់មួយរូបមាន "តម្លៃយ៉ាងសំខាន់" ចំពោះរដ្ឋាភិបាល "គឺជាការបញ្ចេញមតិដែលមិនសមស្រប ហើយអាចថាខុសទៀតផង"។ ហើយ ៧៦០ ("ទោះបីជាយើងមិនឃើញមានការជំទាស់ទៅនឹងសេចក្តីថ្លែងការណ៍ដែលបង្ហាញពីគោលនយោបាយរបស់ក្រសួង និងមិនឃើញមានសេចក្តីថ្លែងការណ៍អង្គហេតុពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីកន្លងមក ក្នុងលក្ខណៈជារបាយការណ៍ក៏ដោយ ក៏នៅក្នុងទីនេះ នៅក្នុងសេចក្តីថ្លែងការណ៍របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ដែលកំពុងបន្ត ឬអាចនឹងចាប់ផ្តើមនោះ គេគួរតែដកចេញនូវអំណះអំណាងអង្គហេតុនានា ដែលអាចបង្កើតឲ្យមាននូវអាកប្បកិរិយាផ្ទុយគ្នា នៅក្នុងទស្សនៈសាធារណជន ពាក់ព័ន្ធទៅនឹងអំពើដែលរងការចោទប្រកាន់របស់ជនជាប់ចោទនៅក្នុងកិច្ចដំណើរការនីតិវិធី[illegible] នេះ") ដកស្រង់ចេញពី ABA Comm. on Prof'l Ethics and Grievances, Formal Op. 199 (1940)។

ជម្រះឱ្យខុសពីគោលបំណង ក្នុងការវិនិច្ឆ័យទៅលើការខ្វែងយោបល់នានា ដោយគោរពតាមនីតិវិធីច្បាប់ ដែលផ្អែកលើភស្តុតាងដែលបានទទួលនៅក្នុងតុលាការជាសាធារណៈនោះឡើយ[166]។

60. ជាចុងបញ្ចប់ យើងការកត់សម្គាល់ឃើញថា ប្រភពទីពីរ បានពិចារណាឃើញថា ការកំណត់ចរិតលក្ខណៈជាសាធារណៈរបស់អតីតប្រធានាធិបតី Bush និងអតីតរដ្ឋលេខាធិការនៃក្រសួងការពារជាតិ Donald Rumsfeld អំពីអ្នកជាប់ឃុំឃាំងនៅ Guantanamo Bay ថា "ជាមនុស្សអាក្រក់" "ពួកគេជាឃាតករ" និង"ពួកគេជាភេរវជនក្បាលរឹង និងមានការបណ្តុះបណ្តាលយ៉ាងត្រឹមត្រូវ" "ដូចនឹងការធ្វើអត្ថាធិប្បាយ ដែលជាការរំលោភគោលការណ៍សច្ចធារណ៍នៃនិរទោស នៅក្នុងបរិបទដទៃ"[167]។ "ជាការពិបាកក្នុងការប្រមើលមើល ថាតើគោលការណ៍សច្ចធារណ៍នៃនិរទោសនេះ អាចត្រូវថែរក្សាបានដោយរបៀបណា បើបុគ្គលតែមួយដែលបានបង្កើតនូវប្រព័ន្ធគណៈកម្មាធិការនេះ ដែលបានតែងតាំងបុគ្គលិកសម្រាប់គណៈកម្មាធិការនេះ ហើយដែលដើរតួនាទីក្នុងដំណើរការត្រួតពិនិត្យ បែរជាចេញនូវសេចក្តីថ្លែងការណ៍បែបនេះ"[168]។

61. ស្របទៅតាមយុត្តិសាស្ត្រដែលបានពិភាក្សាខាងលើ សេចក្តីថ្លែងការណ៍របស់មន្ត្រីសាធារណៈដែលប្រកាសអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ មិនស្របទៅនឹងគោការណ៍សច្ចធារណ៍នៃនិរទោសឡើយ។

62. ដើម្បីដោះស្រាយចំពោះការរំលោភសិទ្ធិនេះ ដោយសំអាងលើដំណោះស្រាយដែលបានផ្តល់ដោយតុលាការស្តីពីសិទ្ធិមនុស្ស មេធាវីការពារក្តីបានស្នើសុំសំណងជាថវិកា ឬការបន្ធូរបន្ថយទោស ចំណែកឯសហព្រះរាជអាជ្ញាបានលើកឡើងករណីថា "ការស្នើសុំឱ្យបកស្រាយច្បាប់" របស់អង្គជំនុំជម្រះសាលាដំបូង គឺគ្រប់គ្រាន់ហើយ[169]។ អង្គជំនុំជម្រះតុលាការកំពូលលើកឡើងសាជាថ្មីថា ដោយហេតុថា "យុត្តិសាស្ត្ររបស់ស្ថាប័នសិទ្ធិមនុស្សនៅកម្រិតតំបន់នានា ស្តីអំពីការផ្តល់សំណង

[166] *រឿងក្តី Sheppard ទល់នឹង Maxwell,* តុលាការកំពូលសហរដ្ឋអាមេរិក (1966), 384 U.S. 333, 350-51

[167] James G. Stewart, អំពើរបស់គណៈកម្មាធិការយោធា គឺមិនស្របគ្នាជាមួយអនុសញ្ញាទីក្រុងហ្សឺណែវ (The Military Commissions Act's Inconsistency with the Geneva Conventions): An Overview, 5 J. Int'l Crim. Just. 26, 30-31 (2007)

[168] McCormack, T. និង Avril McDonald, ឯកសារប្រចាំឆ្នាំ នៃច្បាប់មនុស្សធម៌អន្តរជាតិ (*Yearbook of International Humanitarian Law) – 2003,* លេខ. 6, (2003), ទំព័រ 420-421។

[169] សារណាតប កថាខណ្ឌ ២៣-២៨។ បណ្តឹងសាទុក្ខ កថាខណ្ឌ ១៣, ១៧ (ដកស្រង់ពីបណ្តឹងជាលាយលក្ខណ៍អក្សរ កថាខណ្ឌ ១៥, ២១-២៣)។

ដល់ជនរងគ្រោះ អាចធ្វើជាឯកសារមូលដ្ឋានគួរឱ្យជឿបានពាក់ព័ន្ធនឹងខ្លឹមសារនៃសិទ្ធិទទួលបានសំណងចំពោះព្យសនកម្មដែលបុគ្គលទាំងឡាយបានទទួលរង”[170] ដោយសារតែអាណត្តិខុសគ្នាទើប“កិច្ចដំណើរការនីតិវិធីនៅចំពោះមុខស្ថាប័នសិទ្ធិមនុស្សនៅកម្រិតតំបន់ទាំងនេះ មានលក្ខណៈខុសៗគ្នាពីនីតិវិធីជំនុំជម្រះក្នុងរឿងព្រហ្មទណ្ឌនានា ទាក់ទងទៅនឹងគោលនយោបាយ ក្របខ័ណ្ឌបច្ចេកទេសច្បាប់ និងវិធាននៃការបកស្រាយ”[171]។ ក្នុងការពិចារណាលើសំណងដែលមាននៅក្នុងករណីនៃការរំលោភបំពានលើសច្ចធារណ៍នៃនិរទោសរបស់ជនជាប់ចោទ តុលាការស្តីពីសិទ្ធិមនុស្សមានអំណាចទៅលើរដ្ឋ ដែលមានជម្លោះទាក់ទងនឹងការប្រព្រឹត្តរបស់អាជ្ញាធរសាធារណៈទាំងមូល និងអាចផ្តល់អនុសាសន៍អំពីវិធានការ ដែលត្រូវអនុវត្តដោយបរិធានរបស់រដ្ឋទាំងមូល។ ទោះជាយ៉ាងណាក៏ដោយ តុលាការព្រហ្មទណ្ឌ ខ្លួនឯងក៏ ជាអាជ្ញាធរសាធារណៈផងដែរ។ ដូច្នេះ តុលាការនេះ ឆ្លើយតបទៅនឹងការប្រព្រឹត្តរបស់អាជ្ញាធរសាធារណៈផ្សេងទៀត តាមភាពចាំបាច់ ដែលខ្លួនត្រូវធ្វើការការជំនុំជម្រះប្រកបដោយភាពយុត្តិធម៌។ វិធានការដែលតុលាការព្រហ្មទណ្ឌមាន គឺអាស្រ័យលើគោលបំណងដ៏តូចចង្អៀតនេះ។ បន្ថែមពីលើនេះ ដោយសារតែ *វិធីអនុវត្ត (modus operandi)* របស់ពួកគេ ដែលអាចតម្រូវឱ្យប្រើប្រាស់ ឱ្យអស់លទ្ធភាពនូវសំណងកម្រិតជាតិដែលមាន និងត្រូវតែអនុវត្តដោយផ្អែកតាមនីតិវិធីកម្រិតអន្តរជាតិ ដែលមានលក្ខណៈស្មុគស្មាញនោះ ទើបតុលាការស្តីពីសិទ្ធិមនុស្សនេះ ស្ថិតនៅទីកន្លែងឆ្ងាយ និងរយៈពេលវេលាពីរឿងក្តីនៃការរំលោភសិទ្ធិនោះ។ ហេតុដូច្នេះ សំណងដែលផ្តល់ឱ្យដោយស្ថាប័នទាំងនេះ អាចមានលក្ខណៈខុសគ្នាពីសំណងដែលមាននៅតុលាការព្រហ្មទណ្ឌក្នុងស្រុក[172]។ ដូច្នេះ នេះមិនមែនជាសំណងដែលបាន

---

[170] សាលដីកា ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៦៥២។

[171] *ដូចជើងទំព័រខាងលើ។*

[172] “នៅពេលណាក៏ដោយដែលអាចកើតមាន” ការរំលោភបំពានលើសិទ្ធិមនុស្ស គឺតម្រូវឱ្យមានគោលការណ៍ដែលសងសំណងពេញលេញឱ្យបានដូចស្ថានភាពដើម (*restitution in integrum*)។ នៅពេលដែលមិនអាចផ្តល់សំណងឱ្យវិញបាន តុលាការអន្តរជាតិបានវាយតម្លៃលើវិធានការផ្សេងទៀតដែលគ្រប់គ្រាន់ ដើម្បីជួសជុលផលវិបាកនៃការទទួលរងការរំលោភបំពាន ការផ្តល់ឱ្យនូវសំណង ការបន្ធូរបន្ថយការដាក់ទណ្ឌកម្ម និងការដោះលែងមុនកាលកំណត់ និងការបោះពុម្ពផ្សាយសេចក្តីថ្លែងសុំអភ័យទោស និងសេចក្តីសម្រេចរបស់ស្ថាប័នសិទ្ធិមនុស្ស ដើម្បីរារាំងការរំលោភបំពាននាពេលអនាគត សូមមើលឧទាហរណ៍. *Villagrán Moralesនិងអ្នកផ្សេងទៀត ទល់នឹង Guatemala* តុលាការ IACtHR សាលក្រម (សំណង និងតម្លៃ) ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០១ កថាខណ្ឌ៦០។ *រឿងក្តី Tibi ទល់នឹង Ecuador* តុលាការ IACtHR សាលក្រម (អញ្ញត្រកម្ម អង្គសេចក្តី សំណង និងតម្លៃ) ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ ២២៤។

ផ្តល់ដោយតុលាការស្តីពីសិទ្ធិមនុស្សដែលពាក់ព័ន្ធនៅទីនេះទេ ប៉ុន្តែគឺជាវិធានការផ្តល់សំណងដែលធ្វើឡើងដោយតុលាការព្រហ្មទណ្ឌក្នុងស្រុក និងត្រូវពិនិត្យឡើងវិញដោយតុលាការស្តីពីសិទ្ធិមនុស្ស។

63. អាស្រ័យហេតុនេះ តួនាទីបន្ទាន់របស់តុលាការព្រហ្មទណ្ឌនៅក្នុងរឿងក្តីបច្ចុប្បន្ននេះ គឺដើម្បីធានាថាការជំនុំជម្រះមិនត្រូវបានប្រឡាក់ប្រឡូកដោយការធ្វើឱ្យខូចប្រយោជន៍ណាមួយ ដែលបង្កឡើងដោយការបំភ័ន្តសាធារណមតិទេ។ ផ្អែកតាមតុលាការ ECHR "ការខកខានតូចតាច" របស់តុលាការ ដើម្បីទប់ទល់នឹងអានុភាពនៃការខូចប្រយោជន៍ដែលអាចមានណាមួយ គឺគ្រប់គ្រាន់សម្រាប់ពញ្ញាក់តុលាការឱ្យទទួលខុសត្រូវក្រោមអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស[173]។ ប្រហាក់ប្រហែលគ្នាដែរ នៅក្នុង*រឿងក្តី Gridin ទល់នឹង សហព័ន្ធរុស្ស៊ី និង រឿងក្តី Larrañaga ទល់នឹង ហ្វីលីពីន*[174] តុលាការស្តីពីសិទ្ធិមនុស្សបានរកឃើញថា ការរំលោភបំពានលើគោលការណ៍សច្ចធារណ៍នៃនិរទោសត្រូវបានរកឃើញ នៅពេលដែលតុលាការឧទ្ធរណ៍ថ្នាក់ជាតិ មិនបានដោះស្រាយឱ្យបានច្បាស់លាស់លើបញ្ហាដែលមន្ត្រីសាធារណៈ បានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍ដែលរៀបរាប់ថា អ្នកដាក់ពាក្យសុំមានកំហុស[175]។ ផ្ទុយមកវិញ ប្រសិនបើស្ថាប័នឧទ្ធរណ៍កម្រិតជាតិបានពិនិត្យមើល និងវិភាគ ថាតើមានការប៉ះពាល់ពីសាធារណៈដល់ការជំនុំជម្រះដែរ ឬយ៉ាងណានោះ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR) ទំនងជាមិនបានរកឃើញការរំលោភបំពាននៃការការពារជនជាប់ចោទ ដែលអនុលោមតាមមាត្រា ៦ នោះទេ[176]។

---

[173] David Harris *និងអ្នកផ្សេងទៀត ច្បាប់ទាក់ទងនឹងអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស* Oxford University Press បោះពុម្ពលើកទីពីរ ឆ្នាំ២០០៩ ទំព័រ២៦៦ (កត់សម្គាល់ឃើញថា ការចូលរួមរបស់រដ្ឋនៅក្នុងការបង្កើតនូវការផ្សាយជាសាធារណៈ មិនមែនជាធាតុផ្សំចាំបាច់ ហើយការខកខានរបស់តុលាការមួយ ដែលជា"ស្ថានប័នរដ្ឋ"មួយ ដើម្បីទប់ទល់នឹងអនុភាពការខូចប្រយោជន៍នៃការផ្សាយជាសាធារណៈបែបនោះ គួរតែចាត់ទុកថាគ្រប់គ្រាន់ក្នុងការរកឃើញការរំលោភបំពានក្រោមអនុសញ្ញា)។

[174] *សូមមើល*កថាខណ្ឌ ២២៤ *ខាងលើ*។

[175] *រឿងក្តី Gridin តទល់នឹង សហភាពសូវៀត* កថាខណ្ឌ៨.៣។ *សូមមើលផងដែរ Mwamba តទល់នឹង Zambia* កថាខណ្ឌ ៦.៥ (ការរំលោភបំពានលើសច្ចធារណ៍នៃនិរទោស ត្រូវបានរកឃើញដោយផ្អែកលើមូលដ្ឋាននៃ "ការខកខានរបស់ភាគីរដ្ឋក្នុងការជំទាស់" នឹងការសោកស្តាយរបស់អ្នកដាក់ពាក្យសុំដែលថា សិទ្ធិរបស់គាត់ ត្រូវបានរំលោភបំពានដោយសេចក្តីថ្លែងការណ៍អំពីកំហុស ដែលធ្វើឡើងដោយមន្ត្រីសាធារណៈនៅក្នុងសាព័ត៌មាន)។

[176] David Harris *និងអ្នកផ្សេងទៀត ច្បាប់ទាក់ទងនឹងអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស* ទំព័រ២៦៦ និង ECmHR *X v. UK* No. 3860/68 30 CD 70, 1969 (ទោះបីជានៅក្នុងចំណុចនេះ តុលាការឧទ្ធរណ៍ បានពិចារណាពិសេសចំពោះបណ្តឹងរបស់អ្នកប្តឹង...)



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME E.C.C.C * C.E.T.C

64. ជាការពិត នេះគឺជា តួនាទីរបស់តុលាការ ក្នុងការទប់ស្កាត់ការរំលោភបំពានដំណើរការនីតិវិធីតាមរយៈការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីអន្តរាគមន៍ នៅពេលភាពព្រងើយកន្តើយ អាចបណ្តាលឱ្យមានការរំលោភសិទ្ធិនោះ[177]។ រឿងក្តីផ្សេងទៀត បញ្ជាក់ថា ការអន្តរាគមន៍របស់តុលាការអាចគ្រប់គ្រាន់ក្នុងការរក្សាការជំនុំជម្រះប្រកបដោយយុត្តិធម៌ ប្រឆាំងនឹងការជះឥទ្ធិពលខាងក្រៅដរាបណាវិការៈនេះ មិនអាក្រក់ខ្លាំងពេកដែលមិនអាចធ្វើឱ្យមានការជំនុំជម្រះប្រកបដោយយុត្តិធម៌។ ទាក់ទិននឹងអានុភាពនៃការបំភ័ន្តសាធារណមតិ ដែលកើតឡើងតាមរយៈការផ្សព្វផ្សាយតាមសាព័ត៌មាននៅក្នុងដំណើរការនីតិវិធីរបស់គណៈវិនិច្ឆ័យលើអង្គហេតុ តុលាការ ECtHR តម្កល់សំអាងហេតុរបស់តុលាការថ្នាក់ជាតិដែលយល់ឃើញថា ការណែនាំរបស់ចៅក្រមមួយរូបដល់គណៈវិនិច្ឆ័យលើអង្គហេតុ មិនឱ្យយកមតិយោបល់ខាងក្រៅជាបានការនោះ គឺគ្រប់គ្រាន់ក្នុងការការពារគោលការណ៍សច្ចធារណ៍នៃនិរទោស[178]។ *នៅក្នុងរឿងក្តី Adolf ទល់នឹង ប្រទេសអូទ្រីស* តុលាការ ECtHR យល់ឃើញថា មិនមានការរំលោភបំពានលើសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដោយរួមបញ្ចូលទាំងគោលការណ៍សច្ចធារណ៍នៃនិរទោស ដោយសារតែតុលាការកំពូលថ្នាក់ជាតិ បានកែតម្រូវសំអាងហេតុរបស់តុលាការថ្នាក់ក្រោមដែលមានវិការៈ[179]។ ភាពយុត្តិធម៌នៃដំណើរការនីតិវិធី ត្រូវបានវាយតម្លៃនៅក្នុងគ្រប់ករណីទាំងអស់។

---

ពាក្យសុំដែលមានការប្រកាសជាសាធារណៈអំពីការធ្វើឱ្យខូចប្រយោជន៍ ដែលទាក់ទិននឹងរឿងក្តីរបស់គាត់ និងរកឃើញថាមិនមានហានីយភ័យពិតប្រាកដដែលថា គណៈវិនិច្ឆ័យលើអង្គហេតុ ទទួលរងឥទ្ធិពលដោយការផ្សាយជាសាធារណៈនោះ")។

[177] សូមមើលឧទាហរណ៍ R តទល់នឹង *Horseferry Road Magistrates Court*, [១៩៩៣] ១ A.C. ៤២, ទំព័រ ១២ (មតិយោបល់របស់ Lord Griffiths អំពាវនាវឱ្យតុលាការទទួលយកការទទួលខុសត្រូវរបស់ខ្លួន "ដើម្បីរក្សានូវវិធានច្បាប់ដែលប្រកាន់យកឆន្ទៈដើម្បីត្រួតពិនិត្យសកម្មភាពប្រតិបត្តិ និងបដិសេធមិនឱ្យមានឥរិយាបថ ដែលគម្រាមកំហែងដល់សិទ្ធិមនុស្សជាមូលដ្ឋានផង ឬវិធានច្បាប់ផងដែរ")។

[178] *រឿងក្តី Noye តទល់នឹង ចក្រភពអង់គ្លេស* តុលាការ ECtHR សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ សំណុំរឿងលេខ 4491/02 ថ្ងៃទី២១ ខែមករា ឆ្នាំ២០០៣ ទំព័រ១១។

[179] *រឿងក្តី Adolf តទល់នឹង ប្រទេសអូទ្រីស* តុលាការ ECtHR សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ សំណុំរឿងលេខ8269/78 ថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៨២ កថាខណ្ឌ៤០។ *សូមមើលផងដែរ រឿងក្តី Fedorenko តទល់នឹង ប្រទេសរុស្ស៊ី* តុលាការ ECtHR សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ សំណុំរឿងលេខ 39602/05 ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ៩១-៩២ (នៅពេលរកឃើញការរំលោភបំពានលើសច្ចធារណ៍នៃនិរទោស អង្គជំនុំជម្រះអង្កេតឃើញថា តុលាការឧទ្ធរណ៍មិនមានបំណងកែតម្រូវឱ្យបានត្រឹមត្រូវចំពោះសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមដែលមានវិការៈនោះទេ)។

65. ការដាក់ទណ្ឌកម្មចំពោះការប្រមាថតុលាការ និងការព្រមាន ត្រូវបានប្រើប្រាស់ចំពោះមន្ត្រីនៅក្នុងប្រព័ន្ធយុត្តិធម៌ ដែលរំលោភលើគោលការណ៍សច្ចធារនិរទោសនេះ។ នៅក្នុងរឿងក្តីថ្មីៗនេះ ដែលទាក់ទិននឹងការប្រព្រឹត្តរបស់រដ្ឋអាជ្ញារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICC បានសម្រេចថា "[ឥរិយាបថ] មិនសមរម្យយ៉ាងច្បាស់ក្នុងការពិចារណាសច្ចធារណ៍នៃនិរទោស"[180] ក្នុងចំណោមចំណុចផ្សេងៗទៀត អាចតម្រូវឱ្យប្រើប្រាស់ "វិធានការសំណងផ្សេងៗដើម្បីដោះស្រាយចំពោះព្យសនកម្មណាមួយ ដែលធ្វើឡើងដោយសេចក្តីថ្លែងការណ៍របស់គាត់"[181] ដោយរួមបញ្ចូលទាំងការចេញលិខិតជាផ្លូវការរំឭកអំពីកាតព្វកិច្ចរបស់គាត់ ឬការព្រមានរបស់តុលាការ។ នៅក្នុង *រឿងក្តី សហរដ្ឋអាមេរិក ទល់នឹង Koubriti* អគ្គមេធាវី បានរំលោភបំពានលើសេចក្តីបង្គាប់របស់តុលាការ ដែលមានគោលបំណងហាមឃាត់ភាគីមិនឱ្យផ្សព្វផ្សាយព័ត៌មានណាមួយជាសាធារណៈ ដែលព័ត៌មាននោះ មានភវនីយភាពសមហេតុផលអំពីការជ្រៀតជ្រែកដល់ការជំនុំជម្រះប្រកបដោយភាពយុត្តិធម៌។ នៅក្នុងការសម្រេចយកចំណាត់ការសមស្របណាមួយ តុលាការបានអង្កេតឃើញថា ទោះបីជាតួនាទីជាន់ខ្ពស់របស់អ្នកផ្សព្វផ្សាយព័ត៌មាន បានធ្វើឱ្យដំណើរការនីតិវិធីអំពីការប្រមាថតុលាការដែលជាបទព្រហ្មទណ្ឌ "មានលក្ខណៈកាន់តែស្មុគស្មាញខ្លាំង" ដោយសារតែការពាក់ព័ន្ធនឹងរដ្ឋធម្មនុញ្ញអំពីការបែងចែកអំណាច "តួនាទី និងកិច្ចស៊ើបសួររបស់តុលាការ គឺនៅដដែល និងមិនអាចអនុវត្តទៅតាមតួនាទីរបស់បុគ្គលដែលពាក់ព័ន្ធនោះទេ"[182]។ ក្រៅតែពីអំពើដោយចេតនា ឬគោលបំណងជាក់ស្តែង ការរំលោភបំពានត្រូវបានរកឃើញថាជា "អំពើអចេតនា" នៅពេលពិចារណាលើការសុំអភ័យទោសរបស់មន្ត្រីជាន់ខ្ពស់រូបនេះមកកាន់តុលាការ និងមេធាវី សេចក្តីថ្លែងការណ៍ និងកាលៈទេសៈនៅជុំវិញ[183]។ ជាពិសេស សេចក្តីថ្លែងការណ៍របស់អគ្គមេធាវី មានគោលបំណងស្របច្បាប់ក្នុងការជូនដំណឹងដល់សាធារណជនអំពី "ការវិវត្តន៍ចុងក្រោយបំផុតនៃសង្គ្រាមប្រឆាំង

---

[180] *ស្ថានការណ៍នៅ Libyan Arab Jamahiriya រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Saif Al-Islam Gaddafi និង Abdullah Al-Senussi*, សំណុំរឿងលេខ ICC-01/11-01/11 OA 3 "សេចក្តីសម្រេចលើសំណើប្តឹងដិតចិត្តរដ្ឋអាជ្ញា" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១២ កថាខណ្ឌ៣៣។

[181] *ដូចខាងលើដែរ* កថាខណ្ឌ៣៥។

[182] *រឿងក្តី Koubriti*, 305 F. Supp. 2d at 742 ។

[183] *រឿងក្តី Koubriti*, 305 F. Supp. 2d at 748 ។

នឹងភេរវកម្ម"[184] និងមិនមានលក្ខណៈអុជអាលជាក់ស្តែង ឬរៀបចំដើម្បីទាញយកការចាប់អារម្មណ៍នោះទេ[185]។ ដោយពិចារណាឃើញថា "លទ្ធភាពនៃការរំលោភសិទ្ធិ" "ពិតជាមានផ្អែកតាមកាលៈទេសៈទាំងនេះ" តុលាការ "បានព្រមានជាផ្លូវការ និងជាសាធារណៈ" លើអគ្គមេធាវី ដោយសារតែការប្រព្រឹត្តរបស់គាត់[186]។

66. សំណងដែលសំខាន់បំផុតចំពោះការរំលោភគោលការណ៍សច្ចធារណ៍និរទោស គឺត្រូវផ្អាកកិច្ចដំណើរការនីតិវិធី ឬបង្វិលសំណុំរឿងទៅវិញ ដើម្បីឱ្យធ្វើការជំនុំជម្រះសារជាថ្មី។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា វិធានការណ៍បែបនេះត្រូវបានអនុវត្តតែក្នុងករណីពិសេស គឺនៅក្នុងការជំនុំជម្រះដែលពាក់ព័ន្ធនឹងក្រុមគណៈវិនិច្ឆ័យតែប៉ុណ្ណោះ[187]។ នៅក្នុងចក្រភពអង់គ្លេស ទោះបីជា "ការថ្លែងជាសាធារណៈ ដែលឥតឈប់ឈរ ទូលំទូលាយ ទាក់ទងនឹងអារម្មណ៍ និង បោកបញ្ឆោត" អាចធ្វើឱ្យការដាក់ពិរុទ្ធភាព "មានភាពមិនសុវត្ថិភាព" នៅក្នុងការគណៈវិនិច្ឆ័យ[188]

---

[184] *រឿងក្តី Koubriti*, 305 F. Supp. 2d at 748 ។

[185] *រឿងក្តី Koubriti*, 305 F. Supp. 2d at 752 ។

[186] *រឿងក្តី Koubriti*, 305 F. Supp. 2d at 764-765 ។

[187] *រឿងក្តី Jespers ទល់នឹង Belgium*, សំណុំរឿងលេខ 8403/78, សេចក្តីសម្រេចរបស់គណៈកម្មាធិការថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៨០, សេចក្តីសម្រេច និងរបាយការណ៍ (DR) លេខ ២២, ទំព័រ ១០០ (ដែលបានបញ្ជាក់ថា នៅក្នុងករណីដែលគណៈវិនិច្ឆ័យបង្ហាញជាសាធារណៈ សំណើសុំការជំនុំជម្រះឡើងវិញ នៅចំពោះអង្គជំនុំជម្រះផ្សេងទៀត គឺជាសំណងដែលតម្រូវឱ្យធ្វើ); *រឿងក្តី Marshall ទល់នឹង United States*, តុលាការកំពូលនៃសហរដ្ឋអាមេរិក (ឆ្នាំ ១៩៥៩), លេខ 360 U.S. 310 (ដែលតុលាការកំពូលអាមេរិក ផ្តល់ការជំនុំជម្រះថ្មីមួយដល់ជនជាប់ចោទ បន្ទាប់ពីយល់ឃើញថា គណៈវិនិច្ឆ័យបានបង្ហាញជាសាធារណៈទៅឱ្យសារព័ត៌មាន គឺជាការបង្ហាញពីពិរុទ្ធភាពរបស់ជនជាប់ចោទមុនពេលជំនុំជម្រះក្តី –ភស្តុតាងមិនអាចទទួលយកបានពេលជំនុំជម្រះ– គឺជាការរំលោភសិទ្ធិ); *រឿងក្តី Boodram ទល់នឹង Attorney-General of Trinidad and Tobago* [1996] A.C. 842, 855 (នៅពេលដែលគណៈវិនិច្ឆ័យបានកត់សម្គាល់ឃើញថា "វេទិកាសមស្របសម្រាប់ ពាក្យបណ្តឹងស្តីអំពីការផ្សាយជាសាធារណៈ គឺជាតុលាការដំបូង", ដោយសារចៅក្រមនឹងវាយតម្លៃ "ថាតើ វិធានការដូចជាការព្រមាន និងសេចក្តីណែនាំ ដល់គណៈវិនិច្ឆ័យ ការជំទាស់ដែលមានលក្ខណៈចាប់បង្ខំ និងការចំពោះមូលហេតុនេះ នឹងអាចឱ្យគណៈវិនិច្ឆ័យ សម្រេចសាលក្រមដោយគ្មានក្តីកង្វល់ ឬ ថាតើ ក្នុងករណីពិសេស ការផ្អាកជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍នូវបណ្តឹងអាជ្ញា គឺជាដំណោះស្រាយតែមួយគត់ ដែរ ឬយ៉ាងណា")។

[188] រឿងក្តី *R ទល់នឹង Hamza*, [2006] EWCA Crim 2918, កថាខណ្ឌ ៨៩, ដកស្រង់ចេញពី *រឿងក្តី R ទល់នឹង. Taylor និង Taylor*, [1994] 98 Cr App R, ទំព័រ ៣៦១ , និង យោងទៅលើរឿងក្តី *R ទល់នឹង. McCann*, [1991] 92 Cr App R 239 (តុលាការឧទ្ធរណ៍សម្រេចការផ្តាក់ដែលបានបង្គាប់ បន្ទាប់ពីមន្ត្រីសាធារណៈ ប្រដូចការប្រើសិទ្ធិរបស់ជនជាប់ចោទ ក្នុងភាពស្ងៀម)។

ក៏ដោយ ក្រុមប្រឹក្សាផ្តល់យោបល់បានសម្រេចថា នៅក្នុងការធ្វើសេចក្តីបែបនេះ កាលៈទេសៈទាំងអស់ ជាដំបូង ត្រូវតែបានធ្វើការ[189] ដោយរួមបញ្ចូលពេលវេលា និងការធ្វើចរាចរនៃការផ្សព្វផ្សាយនេះ[190], "យុត្តិធម៌ដើម្បីផលប្រយោជន៍សាធារណៈ និងឃើញថា បានធ្វើឡើង"[191] និងសុវត្ថិភាពនៃកិច្ចដំណើរការនីតិវិធីដោយផ្ទាល់[192]។ ចុងក្រោយ "នេះគឺជា អានុភាពនៃការផ្សព្វផ្សាយ (...) ស្តីអំពីចិត្តគំនិតរបស់គណៈវិនិច្ឆ័យនៅពេលជំនុំជម្រះ"[193], "អានុភាពនៃការស្តាប់ដែលអូសបន្លាយយ៉ាងយូរ ទៅលើភស្តុតាងនៅក្នុងសំណុំរឿងនេះ"[194] និងការព្រមានគ្រប់គ្រាន់ និងសេចក្តីណែនាំដែលបានផ្តល់ដោយចៅក្រមជំនុំជម្រះដែលមានបទពិសោធន៍ និងឥតលំអៀង[195] ក្នុងការធានាថា គណៈវិនិច្ឆ័យ លើកលែងតែក្នុងករណីពិសេសបំផុត នឹង "កែប្រែនូវព័ត៌មាន ដែលថា ខ្លួនមិនមាន

---

ឆ្លើយសំណួរ ជាមួយនឹងពិរុទ្ធភាព ដែលបានផ្សាយតាមទូរទស្សន៍ និងវិទ្យុ ក្នុងអំឡុងពេលធ្វើសេចក្តីថ្លែងការណ៍បិទការដេញដោល)។

[189] រឿងក្តី Montgomery & Ors *ទល់នឹង* Her Majesty's Advocate and The Advocate General for Scotland, [2000] UKHL D1, ទំព័រ ៣៨។ ក្នុងរឿងក្តីនេះ ក្រុមប្រឹក្សាផ្តល់យោបល់ ពិចារណាលើយុទ្ធនាការផ្សព្វផ្សាយដែលនៅតែបន្តដោយអនុញ្ញាតឱ្យមានការបញ្ចេញមតិរបស់ចៅក្រមជំនុំជម្រះ ថា ម្ចាស់បណ្តឹងឧទ្ធរណ៍ គប្បីទទួលរងការចោទប្រកាន់ ហើយពាក់ព័ន្ធនឹងបទល្មើសដូចគ្នាដែរ ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្រោយមក បានទទួលរងការចោទប្រកាន់។ យោបល់នេះ ត្រូវបានលើកឡើងក្នុងពេលជំនុំជម្រះ ដែលបណ្តាលឱ្យមានការដោះលែងជនដទៃទៀតដែលរងការចោទប្រកាន់ពីបទមនុស្សឃាត ដូចគ្នាទៅនឹងម្ចាស់បណ្តឹងឧទ្ធរណ៍ដែលក្រោយមកទទួលរងការចោទប្រកាន់។ ក្រុមប្រឹក្សាផ្តល់យោបល់បានសម្រេចថា ពុំមានការរំលោភលើនីតិវិធីណាមួយឡើយ ដូច្នេះពុំមានហេតុផលក្នុងការផ្អាកសំណុំរឿង និងបដិសេធបណ្តឹងឧទ្ធរណ៍ឡើយ។ *ដូចខាងលើ* ទំព័រ ២ និង ១០។

[190] *រឿងក្តី* Montgomery, ទំព័រ ៤០។

[191] *រឿងក្តី* Montgomery, ទំព័រ ៣៨។

[192] *រឿងក្តី* Montgomery, ទំព័រ៤០។

[193] *រឿងក្តី* Montgomery, ទំព័រ ៣១។

[194] *រឿងក្តី* Montgomery, ទំព័រ ៣៨, យោងលើ *រឿងក្តី* Attorney General *ទល់នឹង* MGN Ltd [1997] 1 All E.R. 456, p. 461B។

[195] *រឿងក្តី* Montgomery, ទំព័រ ៤០។ ("អានុភាពនៃការព្រមានណាមួយ ឬ សេចក្តីណែនាំដែលទំនងជាមាន ដែលបានផ្តល់ទៅឱ្យគណៈវិនិច្ឆ័យដោយចៅក្រមជំនុំជម្រះ ដោយយោងទៅលើកាលៈទេសៈនៃការជំនុំជម្រះ គឺជាបញ្ហាធ្ងន់ធ្ងរ នៅក្នុងរឿងក្តីជាច្រើន")។

សិទ្ធិក្នុងការពិចារណានោះ"[196]។ ទំនុកចិត្តដែលគណៈវិនិច្ឆ័យបានណែនាំយ៉ាងសមស្រប និង "ដោយយោងទៅលើសម្បថរបស់ពួកគេ" នឹងផ្តល់នូវ"សាលក្រមមួយយ៉ាងពិតៗ",[197] ជាក់ច្បាស់ណាស់ រួមចំណែកក្នុងកម្រិតយ៉ាងធំដល់តុលាការដែលមានសមាសភាពចៅក្រមដែលមានវិជ្ជាជីវៈពិតប្រាកដ។ ដូច្នេះ ដូចដែលបានសម្រេចដោយតុលាការ ECtHR, ចៅក្រមវិជ្ជាជីវៈ ត្រូវបានសន្មតថា មិនទទួលរងឥទ្ធិពលពីការផ្សព្វផ្សាយជាសាធារណៈ ដែលមានលក្ខណៈអវិជ្ជមាននោះទេ ជាពិសេសក្នុងករណីដែលមិនមានសញ្ញាបង្ហាញពីឥទ្ធិពលបែបនេះ នៅក្នុងការវាយតម្លៃជារួមទៅលើភាពយុត្តិធម៌នៅក្នុងកិច្ចដំណើរការនីតិវិធី[198]។

67. ជាចុងក្រោយ តុលាការកំពូលកត់សម្គាល់ឃើញថា នៅក្នុង*រឿងក្តីរវាង សហរដ្ឋអាមេរិក ទល់នឹង Bakker* [199] សាលាឧទ្ធរណ៍ Fourth Circuit បានពិចារណាទៅលើប្រភពនៃការផ្សព្វផ្សាយជាសាធារណៈមុនពេលជំនុំជម្រះ។ ជនជាប់ចោទ ដែលជាសាសនទូតផ្សព្វផ្សាយព្រះគម្ពី តាមទូរទស្សន៍ ហើយដែលត្រូវបានចោទប្រកាន់ពីបទក្លែងបន្លំនោះ បានប្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចរបស់សាលាដំបូង ដែលបានបដិសេធសំណើសុំផ្លាស់ប្តូរទីកន្លែងជំនុំជម្រះរបស់ខ្លួន ដោយជនជាប់ចោទបានចោទប្រកាន់ថា ការបដិសេធនេះ បានរំលោភទៅលើសិទ្ធិទទួលបានការជំនុំជម្រះពីគណៈវិនិច្ឆ័យដែលមិនលម្អៀង ដោយសារតែដំណើរការនីតិវិធីរឿងក្តីរបស់គាត់មានការផ្សព្វផ្សាយ "យ៉ាងទូលំទូលាយ គ្រប់ទីកន្លែងក្នុងពេលថ្មីៗនេះ" ហើយ "មានលក្ខណៈពិសពុល"[200]។ សាលាឧទ្ធរណ៍ Fourth Circuit បានរកឃើញថា ជនជាប់ចោទគឺជាប្រភពដែលនាំឱ្យមានការផ្សព្វផ្សាយជាសាធារណៈបែបនេះ ដោយជនជាប់ចោទបាន "ចូលរួមក្នុងយុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយ

---

[196] *រឿងក្តី Montgomery*, ទំព័រ ៤១, ដកស្រង់ការយល់ស្របរបស់តុលាកាកំពូលនៃប្រទេសកាណាដា ក្នុង*រឿងក្តី R. ទល់នឹង Vermette*, (1988) 50 D.L.R. (4th) 385, ទំព័រ ៣៩២។

[197] *រឿងក្តី Montgomery*, ទំព័រ ៤១, ដកស្រង់ការយល់ស្របរបស់ តុលាការជាន់ខ្ពស់របស់ អូស្ត្រាលីក្នុង*រឿងក្តី The Queen ទល់នឹង Glennon*, (1992) 173 C.L.R. 592, ទំព័រ ៦០៣ និង តុលាការជាន់ខ្ពស់របស់ប្រទេសអៀរឡង់ ក្នុងរឿងក្តី *Z ទល់នឹង Director of Public Prosecutions*, [1994] 2 I.R. 476, ទំព័រ ៤៩០។

[198] *សូមជើងទំព័រ ១៥២ ខាងលើ*។ *សូមមើលផងដែរ រឿងក្តី Priebke ទល់នឹង ប្រទេសអ៊ីតាលី* លេខ ៤៨៧៩៩/៩៩ Hudoc ២០០១ (ដែលលើកឡើងថា"Contrairement aux membres d'un jury, ces derniers disposent normalement d'une expérience et d'une formation leur permettant d'écarter toute suggestion extérieure au process")។

[199] *រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Bakker*។ សាលាឧទ្ធរណ៍សហរដ្ឋអាមេរិក, Fourth Circuit (1991), 925 F. 2d 728។

[200] *រឿងក្តី Bakker*, 925 F. 2d at 732។



E.C.C.C. SUPREME COURT CHAMBER

ដែលបានគ្រោងទុកយ៉ាងប្រុងប្រយ័ត្ន”[201] ទាំងមុន និងក្រោយមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលយុទ្ធនាការនេះធ្វើឡើងដើម្បីគាំទ្រដល់ការអះអាងពីភាពគ្មានទោសរបស់ជននេះ ព្រមទាំងដើម្បីបង្កើននូវការផ្សព្វផ្សាយជាសាធារណៈ អំពីការរៀបចំរចនាសម្ព័ន្ធថ្មីរបស់ស្ថានីយទូរទស្សន៍សាសនាគ្រីស្ទរបស់គាត់។ តុលាការបានសម្រេចថា ជនជាប់ចោទ មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់តាមទំនើងចិត្តនូវប្រព័ន្ធតុលាការព្រហ្មទណ្ឌ តាមរយៈការបង្កើតនូវការផ្សព្វផ្សាយជាសាធារណៈ ដែលបន្ទាប់មកត្រូវបានប្រើប្រាសដើម្បីគាំទ្រអំណះអំណាងដែលថា ការផ្សព្វផ្សាយជាសាធរណៈ គប្បីឈានដល់ការសន្មតទុកជាមុនអំពីព្យសនកម្មនេះ[202]។

68. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អ្នកធ្វើសេចក្ដីថ្លែងការណ៍កាន់តួនាទីមួយដែលមានឥទ្ធិពលបំផុតនៅក្នុងប្រទេស ហើយសេចក្ដីថ្លែងការណ៍របស់គាត់ធ្វើឡើងតំណាលគ្នានឹងកិច្ចដំណើរការនីតិវិធី។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទង្វើបែបនេះមាន*សក្ដានុពល*បង្កព្យសនកម្មទៅលើសិទ្ធិទទួលបានការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ និងបង្កផលប៉ះពាល់ដល់ឯករាជ្យភាពរបស់តុលាការនេះ។ សេចក្ដីថ្លែងការណ៍បែបនេះ គួរតែជៀសវាងទាំងអស់គ្នា។ មានន័យថា ដោយផ្ទុយទៅនឹងអ្វីដែលមេធាវីការពារក្ដីហាក់បីដូចជាគាំទ្រនោះ[203] ខ្លឹមសារនៃសកម្មភាពកែតម្រូវរបស់ អ.វ.ត.ក គឺមិនមែនដើម្បីដាក់ទណ្ឌកម្ម ឬក្រៅពីនេះ ធ្វើឱ្យអាម៉ាស់ដល់លោកនាយករដ្ឋមន្ត្រីនោះទេ ប៉ុន្តែ ដើម្បីបញ្ជាក់ថា ពុំមានការរំលោភសិទ្ធិណាមួយត្រូវបានបង្កឡើងដោយកិច្ចដំណើរការជំនុំជម្រះក្ដីនោះ។ ការជំនុំជម្រះនេះត្រូវបានប្រព្រឹត្តឡើងតែនៅចំពោះមុខចៅក្រមវិជ្ជាជីវៈ ដែលទំនងជាទទួលរងឥទ្ធិពលតិចជាងក្រុមប្រឹក្សាជំនុំជម្រះ និងអ្នកវាយតម្លៃដែលមិនមានវិជ្ជាជីវៈខាងច្បាប់។ កិច្ចដំណើរការនីតិវិធីស្ដីពីការបង្ហាញភស្ដុតាងនេះ កំពង់ប្រព្រឹត្តទៅ ដោយទុកលទ្ធភាពក្នុងការបង្ហាញ ឬបដិសេធអង្គហេតុដែលពាក់ព័ន្ធ។ លើសពីនេះទៅទៀត ពាក់ព័ន្ធទៅនឹងប្រភពនៃសេចក្ដីថ្លែងការណ៍ជាសាធារណៈនេះ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា សេចក្ដីថ្លែងការណ៍ដំបូងរបស់នាយករដ្ឋមន្ត្រី គឺធ្វើឡើងនៅក្នុងសារព័ត៌មានវៀតណាម។ សេចក្ដីថ្លែងការណ៍នេះ មិនមែនជាការអុជអាលចំៗ ឬក៏ត្រូវបានរៀបចំឡើងដើម្បីទាក់ទាញចំណាប់អារម្មណ៍នោះទេ។ ការផ្សព្វផ្សាយជាបន្តបន្ទាប់ មកទៀតគឺមិនមែនជាការ

---

[201] *រឿងក្ដី Bakker*, 925 F. 2d at 733។

[202] *រឿងក្ដី Bakker*, 925 F. 2d at 733។

[203] បណ្ដឹងសាទុក្ខ កថាខណ្ឌ ១៥ ដល់ ១៧។

ឃោសនាខ្លាំងៗតាមសារព័ត៌មាន ក្នុងគោលបំណងដើម្បីរារាំងដល់ការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌នោះទេ។ តែផ្ទុយទៅវិញ ការដែលមានការផ្សព្វផ្សាយទូលំទូលាយក្រោយៗមកទៀត និងមានប្រតិកម្មនៅប្រទេសកម្ពុជានោះ ជាចម្បង គឺដោយសារការប្រឹងប្រែងរបស់ក្រុមមេធាវីការពារក្តី ដើម្បីធ្វើឱ្យលេចធ្លោនូវការសោកសង្រេងរបស់ខ្លួនទៅវិញ[204]។

69. ចំពោះហេតុផលខាងលើនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជាការសមស្របហើយ ចំពោះការលើកឡើងជាសាធារណៈអំពីគោលការណ៍សច្ចធារណ៍និរទោស និងចំពោះការអះអាងដែលថា ខ្លួន នឹងមិនពិចារណាចំពោះការធ្វើអត្ថាធិប្បាយជាសាធារណៈណាមួយ ដែលពាក់ព័ន្ធនឹងពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពរបស់ជនជាប់ចោទណាម្នាក់ឡើយ។ ដោយបដិសេធ(យ៉ាងជាក់ច្បាស់) មិនអនុវត្តនូវវិធានការដែលបានស្នើឡើងដោយមេធាវីការពារក្តី ដែលជាការព្រមាននោះ អង្គជំនុំជម្រះសាលាដំបូង មិនមានកំហុសអង្គច្បាប់ដែលនាំឱ្យសេចក្តីសម្រេចមោឃៈនោះទេ និងមិនមានកំហុសក្នុងការអនុវត្តឆន្ទានុសិទ្ធិ ដែលបណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខនោះដែរ។ ដោយពិចារណាឃើញថា ខ្លឹមសារនៅក្នុងកថាខណ្ឌ ៣១ នៃសេចក្តីសម្រេចដែលរងការជំទាស់ មិនត្រូវបានប្រកាសនៅក្នុងសវនាការសាធារណៈ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់អំពីសិទ្ធិរបស់ជនជាប់ចោទដែលត្រូវបានសន្មតទុកជាមុនថាគ្មានទោស និងតម្រូវការឱ្យមន្ត្រីសាធារណៈទាំងឡាយជៀសវាងការធ្វើអត្ថាធិប្បាយ ដែលមិនស្របនឹងសច្ចធារណ៍នេះ ដោយ

---

[204] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ក្រុមមេធាវីការពារក្តីបានរំលោភលើបទប្បញ្ញត្តិរបស់ អ.វ.ត.ក ស្តីពីភាពសម្ងាត់នៃឯកសារ ដោយហេតុថា កាលពីថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ *កាសែតភ្នំពេញប៉ុស្តិ៍*បានដកស្រង់សម្តីត្រង់ផ្នែកខ្លះនៃបណ្តឹងសាទុក្ខនេះដោយមានពាក្យពេចន៍ដូចគ្នាបេះបិទតែម្តង ទោះបីជាបណ្តឹងសាទុក្ខនេះមិនទាន់ត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅមុនថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ ក៏ដោយ។ អត្ថបទរបស់ Bridget Di Certo "ចៅក្រមនៅសាលាក្តីខ្មែរក្រហមត្រូវបានស្នើសុំឱ្យស្តីបន្ទោសលោក ហ៊ុន សែន" *កាសែតភ្នំពេញប៉ុស្តិ៍* ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ http://www.phnompenhpost.com/index.php/KRTalk/krt-judges-called-on-to-reproach-hun-sen.html។ បើគេមិនបានផ្តល់បណ្តឹងសាទុក្ខនេះទៅឱ្យអ្នកសារព័ត៌មាននៅមុនកាលបរិច្ឆេទផ្សព្វផ្សាយទេ អត្ថបទ*កាសែតភ្នំពេញប៉ុស្តិ៍* មិនអាចដកស្រង់សម្តីដោយផ្ទាល់ពីផ្នែកខ្លះនៃបណ្តឹងសាទុក្ខនេះបានទេ ... ។ សូមមើលផងដែរ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E116/1/7 ត្រង់កថាខណ្ឌ ៣៧ និងផ្នែកសេចក្តីសម្រេច (ដែលអង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីព្រមានមួយដល់ក្រុមមេធាវីការពារក្តី មិនឱ្យលាតត្រដាងដោយគ្មានការអនុញ្ញាតជាបន្តទៅទៀត អំពីព័ត៌មានដែលត្រូវបានធ្វើចំណាត់ថ្នាក់រួចហើយ។

យោងទៅលើមូលហេតុថា ការធ្វើអត្ថាធិប្បាយបែបនេះ ប្រសិនបើប្រព្រឹត្តសាជាថ្មី អាចធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌។

## VII. ផ្នែកសេចក្តីសម្រេច

**យោងតាមសំអាងហេតុខាងលើនេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេច៖**

**ប្រកាសថា** បណ្តឹងសាទុក្ខនេះអាចទទួលយកបានតាមទម្រង់ច្បាប់។

**បដិសេធ** បណ្តឹងសាទុក្ខនេះលើអង្គសេចក្តី។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ីម**